សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ ធ្នូ ឆ្នាំ ២០១៨

# លីអាហូណា



**អំណោយទានដ៏ផ្អែមល្ហែមដែលបាន ផ្ដល់ឲ្យនៅបុណ្យគ្រីស្ទម៉ាស់ ទំព័រ ១៤**

សារលិខិតចុងក្រោយរបស់អ្នកផ្សព្វផ្សាយសាសនា ទំព័រ ១៨

ការរីកចម្រើនឆ្ពោះទៅរកសក្ដានុពលនៃភាពជាព្រះរបស់យើង ទំព័រ ២០

របៀបស្វែងរកព្រះយេស៊ូវគ្រីស្ទនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ទំព័រ ៣២

ថ្មីនៅខែមករា

សូមទន្ទឹងរង់ចាំ **ផ្នែករបស់កុមារ** ដាច់ដោយឡែក ។

សាសនាចក្រ
នៅទីនេះ

# ទីក្រុង ឡា ប៉ាស
# ប្រទេសបូលីវី





ភ្នំអ៊ីលីម៉ានីគ្របដណ្ដប់ដោយព្រិលបង្កើតបានជាទេសភាពដ៏ស្រស់ស្អាតសម្រាប់រយៈកម្ពស់ដ៏ខ្ពស់ ផ្ទះដែលសង់ពីឥដ្ឋក្រហមនៃទីក្រុង ឡា ប៉ាស ដែលជារឿយៗត្រូវបានចាត់ទុកថា ជាមជ្ឈមណ្ឌលរដ្ឋបាលនៃប្រទេសបូលីវី ដោយសារតែមានការិយាល័យមន្ត្រីរដ្ឋាភិបាលជាច្រើនមានទីតាំងនៅទីនោះ ។

ពួកអ្នកផ្សព្វផ្សាយសាសនាផ្សព្វផ្សាយនៅក្នុងបេសកកម្មអែនដេស បានទៅដល់ប្រទេសបូលីវីនៅក្នុងខែវិច្ឆិកា ឆ្នាំ ១៩៦៤ ហើយបានជួបប្រជុំដោយមានគ្នា ១៩ នាក់បានចូលរួម ។ ពួកគេបានជ្រមុជទឹក និងធ្វើពិធីបញ្ជាក់ដល់អ្នកប្រែចិត្តជឿដំបូងគេម្នាក់នៅរយៈពេលមួយខែក្រោយមក ។ សព្វថ្ងៃនេះ សមាជិកភាពសាសនាចក្រនៅក្នុងប្រទេសបូលីវីបានកើនដល់ ២០៣,០០០ នាក់ ដោយមានក្រុមជំនុំ ២៥៥ និងមានបេសកកម្មចំនួន ៥ ។ ព្រះវិហារបរិសុទ្ធដែលជិតបំផុតគឺនៅក្នុងទីក្រុងកូឆាប៉ាមបា ដែលមានចម្ងាយ ២៣៣ គីឡូម៉ែត្រ ហើយជិះឡានរយៈពេលប្រាំពីរម៉ោងពីទីក្រុង ឡា ប៉ាស ។

សាសនាចក្រនៅក្នុងប្រទេសបូលីវីមានគេស្គាល់ច្រើនដោយសារគម្រោងសប្បុរសធម៌សហគមន៍ រួមមានការបរិច្ចាគរទេះជនពិការ និងគ្រឿងបរិក្ខារពេទ្យសម្រាប់ទារក, ការចូលរួមក្នុងការបរិច្ចាគឈាម, ការគាំទ្រផ្នែកកសិកម្ម, ការដាំដំណាំតាមផ្ទះ និងការប្រឹងប្រែងអភិវឌ្ឍភូមិសង្កាត់ ព្រមទាំងការរៀបចំជំនួយសង្គ្រោះនៅក្នុងគ្រាអាសន្ន ។

- ពួកបរិសុទ្ធថ្ងៃចុងក្រោយនៅតំបន់នៃទីក្រុង ឡា ប៉ាស ដ៏ធំជួបប្រជុំគ្នានៅក្នុងទីតាំង ៤០ កន្លែងផ្សេងៗគ្នា ។
- ភាគច្រើនបំផុតពួកគេនិយាយភាសាអេស្ប៉ាញ ប៉ុន្តែក៏មានអ្នកនិយាយភាសាឆេក, អេមម៉ារ៉ា ឬ ហ្គោរ៉ានី ។
- ពួកអ្នកផ្សព្វផ្សាយសាសនាពេញម៉ោងដំបូងគេមកពីប្រទេសបូលីវីត្រូវបានហៅនៅក្នុងឆ្នាំ ១៩៦៧ ។
- ខែ ធ្នូ ឆ្នាំ ២០១៤ គឺជាខួបទី ៥០ ឆ្នាំនៃសាសនាចក្រនៅក្នុងប្រទេសបូលីវី ។ សមាជិកនៅទីក្រុង ឡា ប៉ាស បានប្រារព្ធពិធីជាសហគមន៍មួយនៅក្នុងខែមករាឆ្នាំ ២០១៥ ។



លីអាហូណា ខែ ធ្នូ ឆ្នាំ ២០១៨

# « តើអ្នកចង់ឲ្យ**ពួកយើង**ធ្វើអ្វី ? »

នៅពេលក្រុមបង្កើតកម្មវិធីសិក្សានៃសាសនាចក្រ បានសួរសមាជិកដើម្បីល្បងមើលពីកម្មវិធីសិក្សាថ្មីឆ្នាំ ២០១៩ *ចូរមកតាមខ្ញុំ* យើងបានឮសំណួរនេះម្ដងហើយម្ដងទៀត ជាមួយនឹងការផ្ដល់មតិដូចនេះថា ៖ « នៅគ្រាដំបូង ខ្ញុំបានគិតថា ‹ កម្មវិធីនេះយ៉ាប់ណាស់ ! › ខ្ញុំមិនច្បាស់ថា វានឹងដំណើរការឬអត់នោះទេ » ។ ប៉ុន្តែកង្វល់ពេលដែលបានឮដំបូងទាំងនេះត្រូវបានផ្លាស់ប្ដូរបន្តិចម្ដងៗ ដោយការបញ្ជាក់ថា « ការសិក្សាព្រះគម្ពីររបស់យើងបានផ្លាស់ប្ដូរទាំងស្រុង » ឬ « វាពិតជាដំណើរការមែន ! »

ហេតុអ្វីបទពិសោធន៍របស់ពួកគេសំខាន់ចំពោះអ្នក ? ដោយសារកម្មវិធីសិក្សាថ្មីនេះគឺសម្រាប់អ្នក និងគ្រួសារអ្នកនៅក្នុងផ្ទះរបស់អ្នក ហើយពុំមែនគ្រាន់តែសម្រាប់គ្រូបង្រៀនរបស់អ្នកនៅព្រះវិហារតែប៉ុណ្ណោះទេ ។

ការផ្ដល់យោបល់មកពីគណៈប្រធានទីមួយ នោះច្បាប់ចេញផ្សាយនាខែនេះពិនិត្យមើលគោលការណ៍នានាដែលបង្កប់នៅក្នុងកម្មវិធីដ៏ថ្មីស្រឡាងនេះនៃ *ចូរមកតាមខ្ញុំ*—ដែលកើតឡើងភ្លាមបន្ទាប់ពីកំណែកម្មវិធីសិក្សារបស់យុវវ័យត្រូវបានណែនាំនៅក្នុងឆ្នាំ ២០១៣ *ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ* ក្នុងឆ្នាំ ២០១៦ និង កម្មវិធីសិក្សាថ្នាក់បព្វជិតភាពមិលគីស្សាដែក និងថ្នាក់សមាគមសង្គ្រោះបានចាប់ផ្ដើមនៅក្នុងឆ្នាំ ២០១៨ ។

ចាប់ពីទំព័រទី ២០ ទៅ អែលឌើរ ដៃប្រ៊ី អ័រ ហូឡិន ដែលបានផ្ដល់ការណែនាំដល់កិច្ចការនៃការបង្កើតកម្មវិធីសិក្សានេះ ផ្ដល់ការយល់ដឹងថា ប្រសិនបើបានអនុវត្តវា នោះវាអាចផ្លាស់ប្ដូរយើងក្នុងរបៀបមួយដ៏អស្ចារ្យ និងអស់កល្ប ។ វាពុំមែនគ្រាន់តែជាកម្មវិធីសិក្សាប៉ុណ្ណោះទេ វាថែមទាំងជាវិធីសាស្ត្រមួយក្នុងការរៀនសូត្រ និងការរស់នៅតាមដំណឹងល្អប្រចាំថ្ងៃ ។

នៅពេលខ្ញុំបានមើលពួកព្យាការី អ្នកមើលឆុត និង អ្នកទទួលវិវរណៈដឹកនាំការបង្កើតនៃកម្មវិធីថ្មីនេះដែលផ្ដោតយកចិត្តទុកដាក់លើគេហដ្ឋាន និងដែលគាំទ្រដោយសាសនាចក្រ នោះខ្ញុំមានការអស្ចារ្យក្នុងចិត្តអំពីរបៀបដែលកម្មវិធីនេះត្រូវនឹងចលនារបស់សាសនាចក្រដែលឆ្ពោះទៅរកវិធីសាស្ត្រគ្រប់គ្រងតិចតួចដើម្បីរស់នៅតាមដំណឹងល្អ អញ្ជើញយើងឲ្យទទួលខុសត្រូវកាន់តែខ្លាំងឡើងចំពោះការរីកចម្រើនខាងវិញ្ញាណផ្ទាល់ខ្លួនរបស់យើង ។ នៅពេលយើងធ្វើដូច្នេះ ដោយនាំភាពសុខសាន្តមកក្នុងជីវិតរបស់យើង និងសេចក្ដីល្អដល់ពិភពលោក នោះខ្ញុំជឿជាក់ថា យើងនឹងទទួលពន្លឺ និងសេចក្ដីពិតកាន់តែច្រើនឡើង ហើយសមត្ថភាពរបស់យើងដើម្បីធ្វើតាមព្រះយេស៊ូវគ្រីស្ទ និងបោះបង់សេចក្ដីអាក្រក់នឹងកើនឡើង ( សូមមើល គ. និង ស. ៩៣:២៩–៤០ ) ។



*ម៉ៃខល ម៉ាកហ្គលប៊ី*
*នាយកបង្កើតកម្មវិធីសិក្សា*

## អត្ថបទពិសេសៗ


៨ **គោលការណ៍នៃការងារបម្រើ ៖ ទំនាក់ទំនងដែលបង្ហាញថាអ្នកយកចិត្តទុកដាក់**
រៀនអំពីរបៀបមួយចំនួនដែលអ្នកអាចបង្ហាញសេចក្ដីស្រឡាញ់របស់អ្នកដល់អ្នកដែលអ្នកផ្ដល់ការងារបានបម្រើ ។

១៤ **អំណោយនៃសេចក្ដីសុខសាន្តរបស់ព្រះអង្គសង្គ្រោះ**
*ដោយអែលឌើរ អិល វិតនី ក្លេតុន*
ព្រះយេស៊ូវគ្រីស្ទបានបង្រៀនយើងអំពីរបៀបស្វែងរកភាពសុខសាន្តនៅក្នុងគ្រានៃក្ដីអំពល់ ។

២០ **ការធ្វើឲ្យជីវិតរបស់អ្នកក្លាយជាដំណើរដ៏បំផុសគំនិតនៃការរីកចម្រើនផ្ទាល់ខ្លួន**
*ដោយអែលឌើរ ដៃប្រ៊ី អ័រ ហូឡិន*
កម្មវិធីសិក្សាថ្មី *ចូរមកតាមខ្ញុំ* អាចជួយយើងឲ្យរីកចម្រើនឆ្ពោះទៅកាន់សក្ដានុពលនៃភាពជាព្រះរបស់យើង ។

៣២ **« យើងជាព្រះដ៏ជាព្រះ » ៖ និមិត្តសញ្ញានៃព្រះគ្រីស្ទនៅក្នុងព្រះគម្ពីរសញ្ញាចាស់**
*ដោយ ស្ទីហ្វិន ភី ចាន*
និមិត្តសញ្ញាពីបុរាណអំពីព្រះអង្គសង្គ្រោះបង្រៀនអំពីទិដ្ឋភាពសំខាន់នៃតួនាទីរបស់ទ្រង់ និងទំនាក់ទំនងរបស់យើងជាមួយនឹងទ្រង់ ។



8


14


20


32

## យុវវ័យ


៤៦ រួមគ្នាតែមួយ ៖ បុព្វហេតុមួយនៃការសាទរ
*ដោយប្រធាន ដាល្លិន អេក អូក*
ឥទ្ធិពលសំខាន់បំផុតមួយនៃវិវរណៈឆ្នាំ ១៩៧៨ ស្ដីពីបព្វជិតភាពគឺជាការហៅមកពីព្រះ ដើម្បីបោះបង់ចោលឥរិយាបថនៃការប្រកាន់ពូជសាសន៍ ។

៥១ រួមគ្នាតែមួយ ៖ ការបង្កើតជាស្ពាន
*ដោយប្រធាន រ៉ុសុល អិម ណិលសុន*
ភាពខុសគ្នារវាងវប្បធម៌, ភាសា, ភេទ, ពូជាសាសន៍ និងសញ្ជាតិ ពុំសំខាន់នៅលើផ្លូវនៃសេចក្ដីសញ្ញាទេ ។

៥២ ការផ្ដល់ការងារបម្រើដូចដែលព្រះអង្គសង្គ្រោះបានធ្វើ
*ដោយ អ៊ីរិក ប៊ី ម៉ដុក*
ព្រះយេស៊ូវគ្រីស្ទបានធ្វើជាគំរូដ៏ល្អឥតខ្ចោះស្ដីពីរបៀបស្រឡាញ់ និងបម្រើបុគ្គលម្នាក់ៗ ។

៥៦ របៀបប្រាំពីរយ៉ាងដើម្បីទទួលអារម្មណ៍នៃវិញ្ញាណបុណ្យគ្រីស្ទម៉ាស់
*ដោយ ឆាឡុត ឡាកាបាល*
តើពុំទទួលអារម្មណ៍អំពីវានៅរដូវកាលនេះឬ ? នេះជារបៀបមួយចំនួនដើម្បីនាំអំណរនៃបុណ្យគ្រីស្ទម៉ាស់ទៅកាន់អ្នកដទៃ—និងចំពោះខ្លួនឯងផងដែរ ។

៦០ ការបន្ថែមអំណោយនៃព្រះវិញ្ញាណទៅលើបញ្ជីនៃបុណ្យគ្រីស្ទម៉ាស់របស់អ្នក
*ដោយ ដេវីឌ ឌីកសុន*
អំណោយទានខាងវិញ្ញាណគឺមានរួចជាស្រេចសម្រាប់យើងដើម្បីទទួល ប្រសិនបើយើងមានឆន្ទៈទូលសូមអំណោយទានទាំងនោះ ។

៦២ សំណួរ និងចម្លើយ
ខ្ញុំពុំមានអារម្មណ៍ថា សក្ដិសមដើម្បីទទួលបានសេចក្ដីស្រឡាញ់ពីព្រះអង្គសង្គ្រោះឡើយ ។ តើខ្ញុំអាចយកឈ្នះលើអារម្មណ៍នេះ ហើយស្គាល់តម្លៃរបស់ខ្លួនឯងតាមរបៀបណា ?

៦៤ បណ្ណប្រកាស: អំណោយដែលអាចធ្វើឲ្យអ្វីមួយកើតឡើងបាន

៦៥ ការអញ្ជើញរបស់ព្យាការី ៖ កិច្ចការប្រាំយ៉ាងដែលអ្នកអាចធ្វើ ដើម្បីជួយផ្លាស់ប្ដូរពិភពលោក
*ដោយប្រធាន រ៉ុសុល អិម ណិលសុន*




នៅលើក្របមុខ
*យប់សុខសាន្ត* ម៉ែឃល ម៉ម

## ការអានខ្លីៗ


៥ ការធ្វើដំណើរនៃបុណ្យគ្រីស្ទម៉ាស់ដំបូងគេ
*ដោយ គ្រីស្ទីណា ក្រូសខ្វែន*

៦ ការបង្ហាញអំពីសេចក្ដីជំនឿ : ប្លែនកា សូលីស—ទីក្រុងអាសិនស្យ៊ុន ប្រទេសប៉ារ៉ាហ្គាយ

១២ តើគ្រូបង្រៀនតាមផ្ទះ និងគ្រូបង្រៀនសួរសុខទុក្ខរបស់ខ្ញុំទៅណា ?
*ដោយ ជីន ប៊ី. ប៊ីងហាំ*

១៨ ធ្វើឲ្យបានល្អប្រសើរបន្តិចជាងពីម្សិលមិញ
*ដោយ ល្វីស អូម៉ា ខាដូស្សូ*

៣០ នៅលើវេទិកា : ការសម្រេចចិត្ត និងអព្ភូតហេតុ ៖ ហើយឥឡូវនេះខ្ញុំឃើញ
*ដោយ អ៊ីណា វ៉ី ក្រាគហ្សេ*

៣៦ ការគិតពិចារណា : អំពូលភ្លើងពណ៌ក្រហមមួយ
*ដោយ ឡូរី រ៉ាយ*

៣៧ ការបម្រើនៅក្នុងសាសនាចក្រ : រីកចម្រើនមកពីការបម្រើ
*ដោយ ប៉ូ ញៀន ( ហ្វេលីព ) ជូ និង ពេត្រា ជូ*

៣៨ សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ

៨០ លុះត្រាជួបទៀត : ការស្គាល់ព្រះគ្រីស្ទតាមរយៈយ៉ូសែប ស្ម៊ីធ
*ដោយអែលឌើរ ព្រូស អរ ម៉ាក់ខនគី*


## យុវមជ្ឈិមវ័យ


៤២ សំឡេងតូចរហៀងនៅក្នុងពេលធ្វើការសម្រេចចិត្តដ៏ធំ
*ដោយ អិម យ៉ូសែប ប្រោហ្ស*
ស្ដាប់តាមការបំផុសគំនិតខាងវិញ្ញាណ និងទុកចិត្តលើព្រះអម្ចាស់ ដើម្បីឲ្យទ្រង់ដឹកនាំផ្លូវរបស់អ្នក ។


## កុមារ


៦៦ អំណោយបុណ្យគ្រីស្ទម៉ាស់របស់ខាល
*ដោយ ជូលៀន ថេននី ដូមែន*
ខាលបានរកឃើញអំណោយដ៏ល្អឥតខ្ចោះសម្រាប់គ្រួសារគាត់នៅព្រឹកព្រលឹមនៃថ្ងៃបុណ្យគ្រីស្ទម៉ាស់ ។

៦៨ ខាធី និង យ៉ូនសឹ
*ដោយ អ៊ីវ៉ាន វ៉ាលិនថាញ និង ម៉ារីសា វែនឌីសុន*
យ៉ូនសឹបានដឹងអំពីរបៀបលួងលោមមិត្តរបស់នាង ។

៧០ គារវភាពជាក្ដីស្នេហ៍
*ដោយ លូអាយប៉ូ ដុបយូ*
ការចាំថាមានគារវភាព បានជួយខ្ញុំកុំឲ្យមានចិត្តភ័យ ។

៧១ បានសង្គ្រោះចេញពីភក់
*ដោយអែលឌើរ អាឌីលសុន ឌី ប៉ោឡូ ដាវីលឡា*
នៅពេលផ្ទះអ្នកជិតខាងរបស់យើងត្រូវបានបំផ្លាញដោយភក់ នោះយើងបានដឹងថា យើងអាចជួយពួកគេបាន ។

៧២ ពួកសាវកថ្លែងទីបន្ទាល់អំពីព្រះគ្រីស្ទ
*ដោយអែលឌើរ យ៉ូនជិន អិល យុក*

៧៣ ទំព័ររបស់យើង

៧៤ បញ្ចាំងពន្លឺរបស់អ្នកចេញទៅ : បងប្អូនប្រុសដែលបញ្ចាំងពន្លឺដល់ពិភពលោក
បងប្អូនប្រុសទាំងនេះមកពីប្រទេសហ្គាណា ចែកចាយពន្លឺរបស់ពួកគេជាមួយអស់អ្នកដែលនៅជុំវិញពួកគេ ។

៧៦ រឿងក្នុងព្រះគម្ពីរ : យ៉ូណាស និងត្រីបាឡែន
*ដោយ គីម វិប រៀង*

៧៩ ទំព័រផាត់ពណ៌


***ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ « ___________ មិនគ្រាន់តែអង្គុយស្ងៀមស្ងាត់ទេ » ។***



**លីអាហូណាឌីជីថល** liahona.lds.org facebook.com/liahona កម្មវិធី Gospel Library ( បណ្ណាល័យដំណឹងល្អ )

## ស្វែងរកបន្ថែមទៀត

នៅក្នុងកម្មវិធី Gospel Library និងនៅគេហទំព័រ liahona.lds.org អ្នកអាច ៖

- ស្វែងរកច្បាប់ចេញផ្សាយបច្ចុប្បន្ន ។
- មើលមាតិកាមានតែឌីជីថល ។
- ស្វែងរកលេខចេញផ្សាយមុនៗ ។
- ដាក់បញ្ជូនរឿង និងមតិកែលម្អរបស់អ្នក ។
- ជាវ ឬជាវដើម្បីផ្តល់ជាអំណោយ ។
- ពង្រីកការសិក្សារបស់អ្នកជាមួយឧបករណ៍ឌីជីថល ។
- ចែកចាយអត្ថបទ និងវីដេអូដែលចូលចិត្ត ។
- ទាញយក ឬបោះពុម្ពអត្ថបទ ។
- ស្តាប់អត្ថបទដែលអ្នកចូលចិត្ត ។

## សូមទាក់ទងមកយើងខ្ញុំ

សូមអ៊ីមែលសំណួរ និងមតិកែលម្អរបស់អ្នកទៅកាន់ liahona@ldschurch.org ។

សូមបញ្ជូនរឿងដែលជំរុញឲ្យមានសេចក្តីជំនឿទាំងឡាយរបស់អ្នកទៅអ៊ីម៉ែល liahona.lds.org *ឬផ្ញើសំបុត្រទៅកាន់ ៖*
*Liahona*, fl. 23
50 E. North Temple Street
Salt Lake City, UT, 84150-0023, USA

## អត្ថបទដែលមានលក្ខណៈសម្រាប់តែឌីជីថលប៉ុណ្ណោះ



ថតរូបដោយ NEONBRAND/UNSPLASH

**ចំណុច ៣ យ៉ាងដែលត្រូវចាំ ពេលអ្នកមានអារម្មណ៍ថា អ្នកដូចជាខ្វះសមត្ថភាព**
ដោយ លៀ បាតុន

មានអារម្មណ៍ថាជាប់គាំងឬ ? នេះជារបៀបដែលអ្នកអាចយកឈ្នះវា ហើយចាប់ផ្តើមរីកចម្រើនម្តងទៀត ។



**ហេតុអ្វីខ្ញុំឈប់សួរសំណួរ « ហេតុអ្វី ? » បន្ទាប់ពីមរណភាពរបស់បងប្រុសខ្ញុំ**
ដោយ ស៊្រីមែណា ខាដូស្ស ខូបាឡាន

ស៊្រីមែណាពន្យល់អំពីរបៀបដែលគាត់បានរកឃើញភាពសុខសាន្ត បន្ទាប់ពីបងប្រុសរបស់គាត់បានស្លាប់នៅក្នុងបេសកកម្ម ។ ដំណើររឿងរបស់ឪពុកគាត់មាននៅទំព័រទី ១៨ នៃច្បាប់ចេញផ្សាយនេះ ។

**ខែ ធ្នូ ឆ្នាំ ២០១៨ វ៉ុល 17 លេខ 6**
**លីអាហូណា 14797 258**
ទស្សនាវដ្តីជាអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

**គណៈប្រធានទីមួយ ៖** រ័សុល អិម ណិលសុន, ដាល្លិន អេក អូក, ហិនរី ប៊ី អាវរិង

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់ ៖** អិម រ័សុល បាឡឺដ, ជេហ្វ្រី អ័រ ហូឡិន, ឌៀថើរ អេហ្វ អុជដូហ្វ, ដេវីឌ អេ បែដណា, ឃ្វីនថិន អិល ឃុក, ឌី ថត គ្រីស្តូហ្វឺសិន, នែល អិល អាន់ឌើរសិន, រ៉ូណាល អេ រ៉ាសបាន, ហ្គែរី អ៊ី ស្ទីវែនសុន, ឌេល ជី រេនឡាន់, ជើរិត ដបុលយូ ហ្គង, អ៊ូលីសេស សូរ៉េស

**អ្នកនិពន្ធ ៖** ហ៊ូហ្គូ អ៊ី ម៉ាទីណេស្ស
**អ្នកប្រឹក្សា ៖** ប្រែអិន ខេ អាស្តុន, រ៉ាន់ដល ខេ បែណិត, ប៊ែកឃី ក្រាវិន, អែតវើត ឌូប, សារ៉ុន អ៊ូបែង, គ្រីស្ទីណា ប៊ី ហ្វ្រានកូ, វ៉ាន់ឌី ឌី ហ្វាំង, ដូណាល អិល ហលស្ត្រម, អ៊ីរិច ដុបយូ កូពីឆ្កេ, លីន ជី រ៉ូប៊ីន

**នាយកគ្រប់គ្រង ៖** រីឆាដ អាយ ហ៊ីតុន
**នាយកទស្សនាវដ្តីសាសនាចក្រ ៖** អាលែន អ័រ ឡយប៊ិហ្គ
**អ្នកចាត់ការពាណិជ្ជកម្ម ៖** ហ្គាស្វ ខាណាន់
**និពន្ធនាយកគ្រប់គ្រង ៖** អ័ដាម ស៊ី អូសុន
**ជំនួយការនិពន្ធនាយកគ្រប់គ្រង ៖** រ៉ាយអិន ខារ
**ជំនួយការបោះពុម្ពផ្សាយ ៖** ហ្វ្រានស៊ីស្កា អូស្លុន
**និពន្ធ និង បោះពុម្ព ៖** ម៉ារីស្សា ឌែននីស, ដេវីឌ ឌិកសុន, ដេវីដ អេ អែតវើត, ម៉ាធ្យូ ឌី ហ្វ្លីតុន, ឡារី ហ្វូលើរ, ហ្គារែត អេច ហ្គាហ្វ, ឡារ៉ែន ផតទើរ ហ្គាន, ចន រ៉ាយអ៊ិន ជិនសិន, ឆាលឡុត ឡាកាបាល់, ម៉ៃយល អរ ម៉ូរីស, អ៊ីរិក ប៊ី ម៉ដុក, សាលី ចនសុន អូដេឃឹក, យ៉ូស្វេ ដេ ភីគី, ចាន ភីនបូរ៉ាហ្វ, រីឆាត អិម រ៉មនី, មីនឌី សេលូ, ឆាកខែល វួដឡេ, ម៉ារីសា វីឌីសុន
**នាយកគ្រប់គ្រងផ្នែកសិល្បៈ ៖** ជេ ស្កត នូដសឹន
**នាយកផ្នែកសិល្បៈ ៖** ថែដ អ័រ ភីធើរសុន
**រចនាប្លង់ ៖** ជីនិត អាន់ទ្រូ, ហ្វេ ភី អាន់ត្រូស, មែនឌី បិនផ្លី, ស៊ី ឃឹមប៊ឺល បុត, ថូម៉ាស ឆាល, ដេវីឌ ហ្វ្រីន, ខូលីន ហ៊ីងគ្លី, អេរិក ភី ចនសិន, ស៊ូសាន ឡូហ្វ្រីន, ស្កត អិម ម៉ូយ, អ៊ីមីលី ឆៀកូ រ៉េមីងតុន, ម៉ាក ដបុលយូ រ៉ូប៊ីសុន, ប្រាត ធៀរ, យេនីកូល វ៉កឃិនហូស

**អ្នកសម្របសម្រួលកម្មសិទ្ធិបញ្ញា ៖** ខូលែត នែបេឃើ អាននី
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម ៖** ជេន អាន ភិធើរស៍
**ផលិតកម្ម ៖** អ៊ីវ៉ា ហ្វែន អាឌៀ, ជូលី ប៊ឺដេត, ថូម៉ាស ជី ខ្រូនីន, ប្រាយអែន ដបុលយូ ហ្គីជី, ជីននី ជេ នីលសុន, ឌើរិក រីឆាដសុន
**មុនការបោះពុម្ព ៖** យ៉ូស្វេ ដែននីស, អាំមុន ហារីស
**នាយកផ្នែកបោះពុម្ព ៖** ស្ទេវិន ធី លេវីស
**នាយកចែកចាយ ៖** ត្រយ អ័រ ប៉ាយើរ

សូមផ្ញើអត្ថបទ និង សំណួរនានា តាមអ៊ិនធើរណែតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉ែលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ *Liahona*, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150–0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសាអាល់បានី, អាមេនី, ប៊ីស្លាមៀ, ប៊ុលហ្គារី, ខ្មែរ, ស៊ីប៊ូអាណូ, ចិន, ចិន ( សម្រាយ ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូនី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងគ្រី, អ៊ីស្លង់, ឥណ្ឌូណេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាត់វៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី, នរវេ, ប៉ូឡូញ, ព័រទុយហ្គាយ, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្គាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញផ្សាយញឹកញាប់មានផ្សេងៗគ្នាទៅតាមភាសា ) ។

© 2018 by Intellectual Reserve, Inc. All rights reserved. បោះពុម្ពនៅសហរដ្ឋអាមេរិក ។

**For Readers in the United States and Canada:** December 2018 Vol. 17 No. 6. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $10.00 per year; Canada, $12.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 507.1.5.2). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.

ដោយ គ្រីស្ទីណា ក្រូសឡែន
ទស្សនាវដ្ដីសាសនាចក្រ



# ការធ្វើដំណើរនៃបុណ្យគ្រីស្ទម៉ាស់ដំបូងគេ

យើងប្រាប់រឿងអំពីបុណ្យគ្រីស្ទម៉ាស់រៀងរាល់ឆ្នាំ ប៉ុន្តែតើយើងបានគិតស្រមៃដល់ការធ្វើដំណើររបស់ម៉ារា និងយ៉ូសែបញឹកញាប់ប៉ុណ្ណាដែរ ? សេចក្ដីជំនឿ និងការពលិកម្មរបស់ពួកគេគឺជាចំណែកដ៏សំខាន់បំផុតនៃរឿងនេះ ។




**១. លូកា ១:២៦–២៧, ៣០–៣១**

ម៉ារាមកពីស្រុកណាសារ៉ែត ជាភូមិមួយដែលមានមនុស្សពី ៤០០–៥០០ នាក់ ។[១] ចំពោះលោកិយ នាងគឺជាក្មេងស្រីស្រុកស្រែចម្ការម្នាក់ ។ ប៉ុន្តែនាង និងយ៉ូសែបបានទទួលយកមុខងារនេះដើម្បីចិញ្ចឹមបីបាច់ព្រះរាជបុត្រានៃព្រះ ។



**២. លូកា ២:៤–៥**

ការធ្វើដំណើរទៅភូមិបេថ្លេហិមវិញអាចចំណាយពេលយ៉ាងហោចណាស់តិចជាងបួនទៅប្រាំថ្ងៃ[២] ហើយព្រះគម្ពីរពុំបានផ្ដល់តម្រុយអំពីសត្វលាដែលធ្វើដំណើរជាមួយពួកគាត់ឆ្លងកាត់កូនភ្នំដែលមានសុទ្ធតែថ្មនោះឡើយ ។ ទោះបីជា « មានគភ៌ » ក្ដី ម៉ារាបានធ្វើដំណើរជាមួយយ៉ូសែបដែលបានបំពេញការព្យាករ ៖ ព្រះមែស៊ីនឹងប្រសូតនៅក្នុងភូមិបេថ្លេហិម ( សូមមើល មីកា ៥:២ ) ។

**៣. លូកា ២:៧–១១**

នៅក្នុងភូមិបេថ្លេហិម យ៉ូសែប និងម៉ារាគ្មានផ្ទះសម្បែងផ្ទាល់ខ្លួន ឬកូនគ្រែដើម្បីដាក់ស្ដេចនៃអស់ទាំងស្ដេចឡើយ ។ ពួកគាត់ពិតជាបានស្គាល់អារម្មណ៍នៃការបន្ទាបខ្លួនដ៏អស្ចារ្យ នៅពេលពួកគាត់បានឃើញទីសម្គាល់ដ៏ច្បាស់ដែលថា ទារកនេះគឺជាព្រះរាជបុត្រានៃព្រះ នៅកណ្ដាលការប្រសូតដ៏រាបសានោះ ។



**៤. ម៉ាថាយ ២:១៣–១៤**

ដោយគ្មានការជូនដំណឹងអ្វីជាមុនឡើយ គ្រួសារតូចមួយនេះត្រូវចាកចេញពីទីក្រុង និងប្រទេសរបស់ពួកគាត់ ។ ពីមុនព្រះគ្រីស្ទជាកុមារមិនទាន់ទាំងមានព្រះជន្មពីរព្រះវស្សាផង មានគេគំរាមកំហែងយកព្រះជន្មរបស់ទ្រង់ ( សូមមើល ម៉ាថាយ ២:១៦ ) ។

ប៉ុន្តែការបូជា និងសេចក្ដីស្រឡាញ់សម្រាប់ព្រះអង្គសង្គ្រោះរបស់ពួកគាត់បានជំរុញចិត្តឲ្យម៉ារា និងយ៉ូសែបធ្វើដំណើរយ៉ាងឆ្ងាយទៅស្រុកអេស៊ីព្ទ ។

**៥. ម៉ាថាយ ២:១៩–២៣**

មួយរយៈក្រោយមកនៅក្នុងទឹកដីដែលពុំស្គាល់ នោះយ៉ូសែប និងម៉ារាបានធ្វើដំណើរដ៏ឆ្ងាយបំផុតដែលពួកគាត់ពុំដែលធ្វើ ដើម្បីត្រឡប់មកវិញ ។ ប៉ុន្តែចម្ងាយនោះហាក់ដូចជាជិតជាង ដោយសារលើកនេះពួកគាត់បានធ្វើដំណើរត្រឡប់ទៅផ្ទះវិញ ។ នៅពេលពួកគាត់ទៅដល់ផ្ទះ ពួកគេបានដាក់សេចក្ដីជំនឿពួកគាត់លើព្រះ ហើយបានចិញ្ចឹមបីបាច់ទ្រង់ដែលនឹង « ត្រូវបានហៅថា អ្នកស្រុកណាសារ៉ែត » ( ម៉ាថាយ ២:២៣ ) ។



ដូចជាម៉ារា និងយ៉ូសែបដែរ **យើងក៏កំពុងធ្វើដំណើរលើផ្លូវរបស់យើងផ្ទាល់ជាមួយព្រះយេស៊ូវគ្រីស្ទ ។**

ខណៈដែលដំណើរនេះអាចនៅវែងឆ្ងាយ និងលំបាក នោះគ្រប់ជំហាននៃសេចក្ដីជំនឿ ដឹកនាំយើងឲ្យខិតកាន់តែជិតជីវិតអស់កល្បជានិច្ច—ជាអំណោយមួយដែលបានប្រទានមកដោយព្រះអង្គសង្គ្រោះរបស់យើងដែលពោរពេញដោយក្ដីស្រឡាញ់ ដែលការធ្វើដំណើរផ្ទាល់របស់ទ្រង់អាចនាំមកនូវសេចក្ដីសង្គ្រោះ ។ ■

**កំណត់ចំណាំ**

១. សូមមើល James E. Strange « Nazareth » *Anchor Bible Dictionary* ។
២. សូមមើល D. Kelly Ogden « The Road to Bethlehem » *Tambuli* ខែ ធ្នូ ឆ្នាំ ១៩៩៣ ទំព័រ ៤១ ។

ផែនទី និងរូបចម្លាក់ពី GETTY IMAGES ពីគំនូរផ្អែកមកពី ការប្រកាស ដោយ ខាល ហៃនរិច ប្លុច FLIGHT ដោយ រ៉ូស ដាប៊ុក ដាល

*នៅពេលស្វាមី និងម្ដាយរបស់ប្លែនកាបានឈឺ ហើយពុំអាចមើលថែខ្លួនពួកគាត់បាន នោះប្លែនកាបានឈប់ធ្វើការដើម្បីមើលថែពួកគាត់ពេញម៉ោង ។ តាមរយៈការបែរទៅរកព្រះអម្ចាស់ នោះប្លែនកាបានរកឃើញកម្លាំងហួសពីកម្លាំងរបស់គាត់ ។*

**ខូឌី បែល ជាងថតរូប**

## ប្លែនកា សូលីស

*ទីក្រុងអាសិនស្យីអុន ប្រទេសប៉ារ៉ាហ្គាយ*



ខ្ញុំពុំធុញទ្រាន់ក្នុងការអធិស្ឋាន និងទូលសុំកម្លាំងមកពីព្រះអម្ចាស់ដើម្បីបន្តទៅមុខទៀតឡើយ ។ ខ្ញុំអធិស្ឋានទៅកាន់ទ្រង់នៅគ្រប់ពេលវេលាទាំងអស់ ។ អ្វីៗដែលគ្រួសារខ្ញុំបានហែលឆ្លងកាត់ បានជួយខ្ញុំឲ្យទទួលស្គាល់ថា ព្រះអម្ចាស់បានយាងជាមួយខ្ញុំតាមរយៈអ្វីៗទាំងនោះ ។ ទ្រង់ប្រទានដល់ខ្ញុំនូវឱកាសដើម្បីក្រោកឡើងម្ដងទៀត ។ វាគឺជាកម្លាំងដ៏ច្រើនមហិមាដែលព្រះអម្ចាស់ប្រទានដល់ខ្ញុំ ។

ខ្ញុំពុំធ្លាប់សួរខ្លួនខ្ញុំថា « ហេតុអ្វីរឿងនេះវាកើតឡើងចំពោះខ្ញុំ ? »ទេ ។ ខ្ញុំបានគិតជានិច្ចថា មានហេតុផលមួយចំពោះរឿងនេះ ។ ខ្ញុំទុកចិត្តលើព្រះអម្ចាស់ ហើយទទួលយកនូវអ្វីដែលទ្រង់បញ្ជូនដល់ខ្ញុំ ។ ទ្រង់បានគាំទ្រខ្ញុំ នៅពេលខ្ញុំបានហែលឆ្លងកាត់គ្រាដ៏លំបាកៗ ហើយខ្ញុំត្រូវបានពង្រឹង ។

ស្វែងរកបន្ថែមទៀត

ត្រូវការជំនួយក្នុងនាមជាអ្នកមើលថែឬ ? សូមទស្សនាគេហទំព័រ **lds.org/go/12186** ។

រៀនបន្ថែមទៀតអំពីការមើលថែទាំដល់មនុស្សចាស់ដ៏ជាទីស្រឡាញ់នៅគេហទំព័រ **lds.org/go/12187** ។

ស្វែងរកការបង្ហាញអំពីសេចក្ដីជំនឿបន្ថែមទៀតនៅគេហទំព័រ **lds.org/go/18** ។



## គោលការណ៍នៃការងារបម្រើ

# ទំនាក់ទំនងដែលបង្ហាញថាអ្នកយកចិត្តទុកដាក់

*មានវិធីជាច្រើន ដែលយើងអាចបង្ហាញថា យើងយកចិត្តទុកដាក់ ជាពិសេសនៅក្នុងគ្រានៃបុណ្យគ្រីស្ទម៉ាស់ ។ យើងអាចនិយាយអំពីវា, ផ្ញើសារអំពីវា, សរសេរអំពីវា, ឲ្យវា, ចែកចាយអំពីវា, អធិស្ឋានអំពីវា, ផ្ញើនំអំពីវា, ច្រៀងអំពីវា, ឱបវា, លេងជាមួយវា, ដាំដំណាំអំពីវា ឬធ្វើការសម្អាតដើម្បីបុណ្យគ្រីស្ទម៉ាស់ ។ គឺគ្រាន់តែសាកធ្វើវាប៉ុណ្ណោះ ។*



ការបង្ហាញសេចក្ដីស្រឡាញ់ចំពោះអ្នកដទៃគឺជាជាចំណុចសំខាន់នៃការផ្ដល់ការងារបម្រើ ។ ជីន ប៊ី ប៊ីងហាំ ប្រធានសមាគមសង្គ្រោះទូទៅបានថ្លែងថា « ការងារបម្រើពិតគឺសម្រេចបានម្ដងមួយៗដោយសេចក្ដីស្រឡាញ់ដែលជាការលើកទឹកចិត្ត ។ . . . ដោយមានសេចក្ដីស្រឡាញ់ជាការលើកទឹកចិត្ត នោះអព្ភូតហេតុជាច្រើននឹងកើតមានឡើង ហើយយើងនឹងរកឃើញវិធីជាច្រើនដើម្បីនាំបងប្អូនប្រុសស្រី ‹ ដែលពុំបានមកព្រះវិហារ › របស់យើងឲ្យមករួមចំណែកក្នុងការឱបក្រសោបនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទវិញ » ។[១]

ការអនុញ្ញាតឲ្យអ្នកដទៃដឹងថា យើងយកចិត្តទុកដាក់ គឺជាធាតុសំខាន់នៃការអភិវឌ្ឍទំនាក់ទំនងផ្ទាល់ខ្លួន ។ ប៉ុន្តែមនុស្សផ្សេងៗទទួលសារលិខិតនេះតាមរបៀបផ្សេងៗគ្នា ។ ដូច្នេះតើយើងអាចបង្ហាញសេចក្ដីស្រឡាញ់របស់យើងដោយសមរម្យ ចំពោះអ្នកដទៃក្នុងរបៀបមួយដែលពួកគេនឹងយល់ ហើយមានអំណរគុណដោយរបៀបណា ? នេះគឺជាមធ្យោបាយមួយចំនួនដើម្បីទាក់ទងដែលបង្ហាញថា យើងយកចិត្តទុកដាក់ ជាមួយនឹងយោបល់មួយចំនួនដើម្បីចាប់ផ្ដើមគំនិតរបស់អ្នក ។

អត្ថបទ « គោលការណ៍នៃការងារបម្រើ » មានគោលបំណងជួយយើងឲ្យមើលថែគ្នាទៅវិញទៅមក—ពុំមែនយកវាទៅចែកចាយជាសារលិខិតនៅពេលទៅសួរទុក្ខឡើយ ។ នៅពេលយើងស្គាល់អស់អ្នកដែលយើងបម្រើ នោះព្រះវិញ្ញាណបរិសុទ្ធនឹងបំផុសគំនិតយើងឲ្យដឹងអំពីសារលិខិតអ្វីខ្លះដែលពួកគេអាចត្រូវការបន្ថែមពីលើការមើលថែ និងសេចក្ដីមេត្តាករុណារបស់យើង ។

**និយាយវា**

ជួនកាល វាគ្មានអ្វីជំនួសឲ្យការនិយាយអំពីអារម្មណ៍ដែលអ្នកមានអំពីនរណាម្នាក់ឡើយ ។ នេះអាចមានន័យថា ជាការប្រាប់នរណាម្នាក់ថា អ្នកស្រឡាញ់ពួកគេ វាក៏រួមមានទាំងការចែកចាយអ្វីដែលអ្នកកោតសរសើរពីពួកគេ ឬថ្លែងការសរសើរដោយស្មោះសរ ។ ការបញ្ជាក់បែបនេះជួយពង្រឹងដល់ទំនាក់ទំនង ។ ( សូមមើល អេភេសូរ ៤:២៩ ) ។

- សូមស្វែងរកឱកាសដើម្បីឲ្យបុគ្គលម្នាក់ៗដឹងថា អ្នកកោតសរសើរយ៉ាងខ្លាំងចំពោះភាពរឹងប៉ឹងរបស់ពួកគេ ។
- ឆៀងចូលលេង, ទូរសព្ទទៅ ឬផ្ញើអ៊ីម៉ែល ផ្ញើសា ឬធ្វើប័ណ្ណប្រាប់បុគ្គលម្នាក់ៗថា អ្នកគិតអំពីពួកគេ ។





**ទៅសួរសុខទុក្ខ**

ចំណាយពេលនិយាយជាមួយ និងស្ដាប់នរណាម្នាក់ គឺជាមធ្យោបាយដ៏មានឥទ្ធិពលមួយ ដើម្បីបង្ហាញថា អ្នកផ្ដល់តម្លៃដល់គាត់ជាខ្លាំង ។ ទោះបីជាអ្នកទៅសួរសុខទុក្ខនៅផ្ទះ ព្រះវិហារ ឬនៅកន្លែងផ្សេងៗទៀត នោះមានមនុស្សជាច្រើនដែលត្រូវការនរណាម្នាក់ដែលពួកគេអាចនិយាយជាមួយ ។ ( សូមមើល ម៉ូសាយ ៤:២៦; គ. និង ស. ២០:៤៧ ) ។

- ស្របតាមតម្រូវការរបស់បុគ្គលម្នាក់ៗ នោះសូមដាក់កាលវិភាគមួយដើម្បីទៅសួរសុខទុក្ខ ។ សូមចំណាយពេលដើម្បីស្ដាប់ និងយល់អំពីកាលៈទេសៈរបស់គាត់ ។
- នៅទីណាដែលពិបាកទៅសួរសុខទុក្ខដល់ផ្ទះដោយសារតែចម្ងាយផ្លូវឆ្ងាយ ទំនៀមទម្លាប់វប្បធម៌ ឬកាលៈទេសៈផ្សេងៗទៀត នោះសូមគិតពីការស្វែងរកពេលជួបគ្នាបន្ទាប់ពីការប្រជុំនៅព្រះវិហារ ។



**បម្រើដោយមានគោលបំណង**

សូមយកចិត្តទុកដាក់អំពីតម្រូវការរបស់បុគ្គលម្នាក់ៗ ឬក្រុមគ្រួសារ ។ ការផ្ដល់ការបម្រើដែលប្រកបដោយអត្ថន័យជាទំនាក់ទំនងដែលបង្ហាញថាអ្នកយកចិត្តទុកដាក់ ។ វារួមផ្សំជាមួយនឹងអំណោយដ៏មានគុណតម្លៃនៃពេលវេលា និងកិច្ចខិតខំដែលមានការចេះគិតគូរ ។ ស៊ីស្ទើរប៊ីងហាំងបានថ្លែងថា « ទង្វើសាមញ្ញៗនៃការបម្រើអាចមានឥទ្ធិពលដ៏ខ្លាំងទៅលើអ្នកដទៃ » ។[២]

- ផ្ដល់ការបម្រើដែលពង្រឹងដល់បុគ្គលម្នាក់ៗ ឬគ្រួសាររបស់ពួកគេ ដូចជាការមើលថែក្មេងៗ ដើម្បីឲ្យឪពុកម្ដាយអាចទៅព្រះវិហារបរិសុទ្ធជាដើម ។
- សូមស្វែងរកវិធីនានាដើម្បីបន្ធូរបន្ទុកនៅពេលមានការស្មុគស្មាញក្នុងជីវិត ដូចជាការសម្អាតបង្អួច បណ្ដើរឆ្កែ ឬជួយសម្អាតនៅទីធ្លា ។



ការស្ដាប់អ្នកដទៃនឹងជួយយើងឲ្យរកឃើញវិធីនានាដើម្បីបង្ហាញពួកគេថា យើងយកចិត្តទុកដាក់ ។ សូមមើលអត្ថបទគោលការណ៍នៃការងារបម្រើ « រឿងប្រាំយ៉ាងដែលអ្នកស្ដាប់ដ៏ល្អធ្វើ » នៅក្នុងច្បាប់ចេញផ្សាយនៃ *លីអាហូណា* ខែ មិថុនា ឆ្នាំ ២០១៨ ។



**ធ្វើកិច្ចការនានាជាមួយគ្នា**

មានបុគ្គលជាច្រើនដែលពុំព្រមទាក់ទងតាមរយៈការសន្ទនាដ៏ស៊ីជម្រៅឡើយ ។ សម្រាប់មនុស្សមួយចំនួន ទំនាក់ទំនងកើតមានតាមរយៈការស្វែងរកចំណាប់អារម្មណ៍រួមគ្នា ឬចំណាយពេលនៅជាមួយគ្នាធ្វើកិច្ចការទាំងនោះ ។ ព្រះអម្ចាស់ជំរុញយើងថា « នៅជាមួយ និងចម្រើនកម្លាំង » (គ. និង ស. ២០:៥៣ ) បងប្អូនប្រុសស្រីរបស់យើង ។

- ដើរលេងកម្សាន្ត, លេងហ្គេមកម្សាន្តនាពេលយប់ ឬកំណត់ម៉ោងជាទៀងទាត់ដើម្បីហាត់ប្រាណជាមួយគ្នា ។
- បម្រើជាមួយគ្នាក្នុងគម្រោងសហគមន៍ ឬព្រះវិហារ ។

**ផ្ដល់អំណោយ**

ជូនកាល ពេលវេលា ឬឱកាសដើម្បីទាក់ទងគ្នាមានកំណត់ ។ នៅក្នុងវប្បធម៌ជាច្រើន ការផ្ដល់អំណោយគឺជាទីសម្គាល់មួយនៃការយកចិត្តទុកដាក់ និងការយល់ចិត្តថ្លើមគ្នា ។ យូរៗម្ដង អំណោយសាមញ្ញៗអាចទាក់ទងចំណាប់អារម្មណ៍របស់អ្នកឲ្យកសាងទំនាក់ទំនងកាន់តែប្រសើរឡើង ។ ( សូមមើល សុភាសិត ២១:១៤ ) ។

- ជូនអាហារដែលពួកគេចូលចិត្ត ។
- ចែកចាយសម្ដីដកស្រង់ ខគម្ពីរ ឬសារលិខិតផ្សេងទៀតដែលអ្នកទទួលអារម្មណ៍ថាវាអាចមានប្រយោជន៍ដល់ពួកគេ ។



### ពលកម្មនៃសេចក្តីស្រឡាញ់

នៅពេលអ្នកស្គាល់បុគ្គលដែលអ្នកត្រូវផ្តល់ការងារបម្រើបានច្បាស់ និងអ្នកដែលអ្នកស្វែងរកការបំផុសគំនិត នោះអ្នកនឹងរៀនកាន់តែពិសេស អំពីរបៀបទាក់ទងសេចក្តីស្រឡាញ់ និងការយកចិត្តទុកដាក់របស់អ្នក ដល់ពួកគេម្នាក់ៗ ។

គីមបើលី សីប៊ូត មកពីរដ្ឋ អូរិហ្គេន ស. រ. អា. ប្រាប់រឿងមួយ អំពីការស្វែងរកការបំផុសគំនិត និងការផ្តល់អំណោយដើម្បីបង្ហាញ សេចក្តីស្រឡាញ់ ៖

« នៅពេលខ្ញុំឃើញថា ជីវិតខ្ញុំកំពុងមានភាពស្មុគស្មាញ នោះខ្ញុំ បានក្រោកឡើង ហើយធ្វើនំប៉ុង ជាទូទៅខ្ញុំធ្វើចំនួនប្រាំបីដុំ ។ គ្រឿងផ្សំ ពិសេសរបស់ខ្ញុំគឺការអធិស្ឋានដោយស្ងាត់ៗដែលខ្ញុំបានថ្លែង នៅពេល ខ្ញុំដុតនំប៉ុងនោះដើម្បីដឹងថា តើនរណាត្រូវការនំប៉ុងនេះ ។ ខ្ញុំអាចស្គាល់ អ្នកជិតខាងដែលនៅជុំវិញខ្ញុំច្បាស់ នៅពេលខ្ញុំយកនំប៉ុងក្តៅៗទៅផ្ទះ និងជីវិតរបស់ពួកគេ ។

« នៅថ្ងៃមួយនារដូវក្តៅ ខ្ញុំបានបើកឡានកាត់គ្រួសារមួយដែល លក់ភេសជ្ជៈប្លាកប៊ើរនៅលើចិញ្ចើមផ្លូវ ។ ខ្ញុំមិនត្រូវការប្លាកប៊ើរបន្ថែម ទៀតទេ ប៉ុន្តែក្មេងប្រុសរាងស្គមដែលកំពុងឈរនោះ មានចិត្តរីករាយ ដែលឃើញខ្ញុំ ដោយគិតថា ខ្ញុំគឺជាអតិថិជនបន្ទាប់ទៀតរបស់គាត់ ។ ខ្ញុំបានទិញប្លាកប៊ើរមួយចំនួន ហើយខ្ញុំក៏មានអំណោយមួយឲ្យគាត់ ផងដែរ ។ ខ្ញុំបានឲ្យនំប៉ុងពីរដុំដល់ក្មេងប្រុសនោះ ។ គាត់បានងាកទៅ មើលឪពុកគាត់ដើម្បីសុំការអនុញ្ញាត បន្ទាប់មកក្មេងប្រុសនោះនិយាយ ថា ‹ មើលនែ៎ប៉ា ឥឡូវយើងមានអាហារបរិភោគហើយថ្ងៃនេះ › ។ ខ្ញុំមាន អំណរគុណចំពោះឱកាសនេះដើម្បីបង្ហាញសេចក្តីស្រឡាញ់នៅក្នុងរបៀប ដ៏សាមញ្ញាមួយ » ។

អែលឌើរ ជែហ្វ្រី អ័រ ហូឡិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បាន អង្វរកថា « សូមឲ្យបុរសស្ត្រីគ្រប់រូប—និងយុវជនយុវនារីពេញវ័យ របស់យើង—នឹង [ មាន ] . . . ការតាំងចិត្តកាន់តែខ្លាំងចំពោះការថែទាំ ដោយអស់ពីចិត្តចំពោះគ្នាទៅវិញទៅមក ដែលជំរុញទឹកចិត្តតែតាមរយៈ សេចក្តីស្រឡាញ់សុទ្ធសាធរបស់ព្រះគ្រីស្ទដើម្បីធ្វើដូច្នោះប៉ុណ្ណោះ » ។ . . . សូមឲ្យយើងធ្វើការរួមគ្នាជាមួយព្រះអម្ចាស់នៃចម្ការទំពាំងបាយជូរ ដើម្បីជួយដល់ព្រះវរបិតារបស់យើងឆ្លើយតបនឹងការអធិស្ឋាន ផ្តល់ការ លួងលោមចិត្ត ជូតទឹកភ្នែក និងពង្រឹងជង្គង់ដែលញ័រ » ។[៣]



### ព្រះយេស៊ូវគ្រីស្ទយកព្រះទ័យទុកដាក់

ពីមុនព្រះយេស៊ូវគ្រីស្ទបានប្រោសឡាសារឲ្យរស់ពីស្លាប់ឡើងវិញ « ព្រះយេស៊ូវគ្រីស្ទបានព្រះកន្សែង ។

« ដូច្នេះពួកសាសន៍យូដានិយាយថា មើលលោកស្រឡាញ់គាត់ ណាស់ហ្ន៎ ! » ( យ៉ូហាន ១១:៣៥–៣៦ ) ។

ព្រះគ្រីស្ទមានបន្ទូលទៅកាន់ពួកសាសន៍នីហ្វៃថា « យើងមាន ចិត្តអាណិតអាសូរដល់ពួកអ្នករាល់គ្នា » ។ បន្ទាប់មកទ្រង់បានហៅ អ្នកឈឺ និងអ្នករងទុក្ខ អ្នកពិការ និងអ្នកខ្វាក់របស់ពួកគេ ហើយ « ទ្រង់បានប្រោសឲ្យជាសះស្បើយគ្រប់ៗគ្នា » ( សូមមើល នីហ្វៃទី ៣ ១៧:៧–៩ ) ។

ព្រះអង្គសង្គ្រោះបានធ្វើគំរូដល់យើង នៅពេលទ្រង់បានយក ព្រះទ័យទុកដាក់លើអ្នកដទៃ ។ ទ្រង់ បានបង្រៀនយើងថា ៖

« ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់អំពីចិត្តអស់ពី ព្រលឹង ហើយអស់អំពីគំនិតឯង ។

នេះជាបញ្ញត្តយ៉ាងសំខាន់ទីមួយ ។

ហើយបញ្ញត្តទីពីរក៏បែបដូចគ្នាគឺថា ត្រូវឲ្យស្រឡាញ់អ្នកជិតខាង ដូចខ្លួនឯង » ( ម៉ាថាយ ២២:៣៧–៣៩ ) ។

**តើនរណាខ្លះត្រូវការការមើលថែពីអ្នក ? តើអ្នកអាចបង្ហាញពួកគេថា អ្នកយកចិត្តទុកដាក់យ៉ាងដូចម្តេច ? ■**

**កំណត់ចំណាំ**
១. ជីន ប៊ី ប៊ីងហាំ « ការងារបម្រើដូចដែលព្រះអង្គសង្គ្រោះបានធ្វើ » *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០៦ ។
២. ជីន ប៊ី ប៊ីងហាំ « ការងារបម្រើដូចដែលព្រះអង្គសង្គ្រោះបានធ្វើ » ទំព័រ ១០៤ ។
៣. ជែហ្វ្រី អ័រ ហូឡិន « នៅជាមួយ និងចម្រើនកម្លាំងពួកគេ » *លីអាហូណា* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០៣ ។



# តើគ្រូបង្រៀនតាមផ្ទះ និងគ្រូបង្រៀនសួរសុខទុក្ខរបស់ខ្ញុំទៅណា ?

**ដោយ ជីន ប៊ី ប៊ីងហាំ**
ប្រធានសមាគមសង្គ្រោះទូទៅ

ភាពបត់បែននៃការងារបម្រើគួរតែជំរុញយើងឲ្យបង្ហាញការយកចិត្តទុកដាក់កាន់តែច្រើនឡើង ពុំមែននាំយើងឲ្យសម្រាកលំហែកាយនោះទេ ។

ថ្មីៗនេះ មិត្តម្នាក់របស់ខ្ញុំបានសួរខ្ញុំដោយភាន់ភាំងថា « តើគ្រូបង្រៀនសួរសុខទុក្ខរបស់ខ្ញុំទៅណា ? » ចាប់តាំងពីពេលដែលស្វាមីរបស់គាត់បានស្លាប់ទៅ ពួកគេត្រូវបានគេមើលថៃ និងយកចិត្តទុកដាក់ ប៉ុន្តែចាប់តាំងពីការប្រកាសអំពីកម្មវិធីការងារបម្រើថ្មីនៅឯសន្និសីទទូទៅខែមេសា ឆ្នាំ ២០១៨ មក គាត់ពុំដែលឃើញពួកគេសោះ ។



យើងទាំងអស់គ្នាកំពុងកែតម្រូវទៅនឹងវិធីថ្មីមួយនៃការធ្វើកិច្ចការនេះ ហើយបងប្អូនប្រុសស្រីដែលផ្តល់ការងារបម្រើមួយចំនួនអាចនឹងពុំយល់ថា ទោះបីជាការសួរសុខទុក្ខតាមផ្ទះពុំមែនគ្រាន់តែជាវិធីមួយនៃការងារបម្រើឡើយ ប្រាកដណាស់វាគឺជាវិធីដ៏អស្ចារ្យមួយដើម្បីបង្ហាញសេចក្តីស្រឡាញ់ និងចំណាប់អារម្មណ៍ដ៏ស្មោះត្រង់—ហើយសមាជិកជាច្រើននៅតែត្រូវការវា ។



**ការដាក់អាទិភាពលើសំណួរ *ហេតុអ្វី* ឲ្យនៅលើសំណួរ *ដូចម្តេច***

សម្រាប់មនុស្សមួយចំនួន បញ្ហាអាចកើតឡើងពីការយល់ច្រឡំអំពីគោលបំណងនៃការផ្លាស់ប្តូរនេះ ។ គោលបំណងដែលបង្កប់នៅក្នុងការជំនួសការបង្រៀនតាមផ្ទះ និងការបង្រៀនសួរសុខទុក្ខឲ្យទៅជាការងារបម្រើនោះ គឺពុំមែនជាការផ្លាស់ប្តូរធម្មតាៗអំពី *របៀប* ដែលយើងមើលថែដល់គ្នាទៅវិញទៅមកនោះទេ តែវាជួយយើងឲ្យកាន់តែទទួលបានការដឹកនាំពី *មូលហេតុនោះ ។*



គោលបំណងចម្បងនៃការងារបម្រើរបស់យើង គឺដើម្បីជួយអ្នកដទៃឲ្យកាន់តែ



ប្រែចិត្តជឿខ្លាំងឡើងដល់ព្រះអង្គសង្គ្រោះព្រះយេស៊ូវគ្រីស្ទ ហើយរីកចម្រើនឆ្ពោះទៅកាន់សក្តានុពលនៃភាពជាព្រះរបស់ពួកគេ ។ ភាពបត់បែនដែលបានបន្ថែមលើកម្មវិធីនេះ ពុំមែនជំរុញឲ្យកិច្ចខិតខំយើងមានការសម្រាកលំហែនោះទេ តែវាផ្តល់ឱកាសកាន់តែច្រើនឡើងសម្រាប់ឲ្យព្រះវិញ្ញាណដឹកនាំកិច្ចខិតខំរបស់យើង ។

ដូច្នេះទោះបីមាន ឬគ្មាននរណាម្នាក់ត្រូវការការសួរសុខទុក្ខនៅថ្ងៃនេះក្តី វាគួរតែផ្តោតទៅលើចំណុចសំខាន់ថា តើអ្វីនឹងជួយពួកគេឲ្យបន្តឆ្ពោះទៅមុខលើមាគ៌ារបស់ព្រះវរបិតាសួគ៌ ។

**រៀនជាមួយគ្នា**

ទោះបីជាការចាប់ផ្តើមគ្មានភាពប្រាកដប្រជាអំពីអ្វីដែលរំពឹងចង់បានពីយើងនៅពេលយើងធ្វើការងារបម្រើក្តី បងប្អូនប្រុសស្រីរបស់យើងកំពុងឈោងទៅជួយគ្នាទៅវិញទៅមក ។ នៅគ្រប់កន្លែងដែលខ្ញុំបានធ្វើដំណើរទៅ វាគឺជាក្តីរំភើបដែលបានឮពីស្ត្រីដ៏ច្រើនរាប់មិនអស់ ( និងបុរសផងដែរ ) ចែកចាយរឿងរបស់ពួកគេអំពីឥទ្ធិពលវិជ្ជមាននៃការងារបម្រើរបស់ខ្លួន—ឬត្រូវបានគេផ្តល់ការងារបម្រើដល់ពួកគេ—គឺទំនាក់ទំនងបានកើនឡើង និងការរីកចម្រើនផ្ទាល់ខ្លួន ។

ថ្មីៗនេះ ខ្ញុំបានត្រឡប់មកពីរដ្ឋ ណ័រខារូឡាយណា ស. រ. អា. នៅទីនោះប្រធានសមាគមសង្គ្រោះវួដម្នាក់បានចែកចាយយោបល់មួយចំនួនដែលគាត់បានទទួលពីថ្នាក់ដឹកនាំស្តេក ។ ជាមួយនឹងការបញ្ជាក់ច្បាស់មួយចំនួន ខ្ញុំបានគិតថា ពួកគាត់អស្ចារ្យណាស់ ហើយសក្តិសមនឹងចែកចាយយោបល់នោះ ។

**បន្តឆ្ពោះទៅមុខ**

យើងទាំងអស់គ្នាកំពុងរៀនជាមួយគ្នានៅពេលយើងចាប់យក « មធ្យោបាយកាន់តែថ្មី និង កាន់តែបរិសុទ្ធ » ដើម្បីផ្តល់ការងារបម្រើ ។[1] ប្រហែលពួកយើងមួយចំនួនមានអារម្មណ៍ស្មុគស្មាញ ឬភ័យខ្លាច ។ វាមានប្រយោជន៍ដើម្បីចាំថា « កាន់តែថ្មី និង កាន់តែ



# « មធ្យោបាយកាន់តែថ្មី កាន់តែបរិសុទ្ធ »

តារាងនេះតំណាងឲ្យវិធីដែលសមាជិកមួយចំនួនបានដឹងអំពីកម្មវិធីចាស់ ដោយប្រៀបធៀបទៅនឹងរបៀបដែលយើងសង្ឃឹមថា មនុស្សទាំងអស់គ្នានឹងយល់អំពីអត្ថន័យនៃការងារបម្រើ ។

| ចាស់ | ថ្មី |
|---|---|
| ការបង្រៀនតាមផ្ទះ និងការបង្រៀនសួរសុខទុក្ខ | ការងារបម្រើ |
| កាតព្វកិច្ចជំរុញចិត្តឲ្យធ្វើ | សេចក្តីស្រឡាញ់ជំរុញចិត្តឲ្យធ្វើ |
| ប្រអប់* | មុក្តា |
| *តើ* ខ្ញុំត្រូវធ្វើអ្វី ? | *ហេតុអ្វី* ខ្ញុំត្រូវធ្វើវា ? |
| ដំណើរការ | លទ្ធផល |
| **គូសរួចថាបានធ្វើ** | **បន្ទាក់ទង** |
| ផ្តោតទៅលើកិច្ចការ | ផ្តោតទៅលើមនុស្ស |
| មួយខែទៅសួរសុខទុក្ខម្តង | ទាក់ទងដោយសាមញ្ញដែលអាចបត់បែនបាន |
| យកសារលិខិតមួយដែលមានរួច | ចែកចាយដំណឹងល្អតាមការដឹកនាំពីព្រះវិញ្ញាណ |
| តើអ្វីទៅដែលត្រូវបានចាត់ទុកថា ជាការសួរសុខទុក្ខនោះ ? | ទទួលខុសត្រូវចំពោះសុខុមាលភាពខាងវិញ្ញាណ |
| ត្រូវបានចាត់តាំងដល់បងប្អូនប្រុសស្រី | ត្រូវបានផ្ទុកផ្តាក់ដោយទុកចិត្តលើបងប្អូនប្រុសស្រី |
| រាយការណ៍ថាបានធ្វើរួច | ផ្លាស់ប្តូរដួងចិត្ត |

* រឿងប្រៀបប្រដូចដែលបានប្រាប់អំពីគ្រឿងអលង្ការមួយដែលមានមុក្តាដ៏មានតម្លៃ ប៉ុន្តែគួរឲ្យសោកស្តាយណាស់នៅពេលមនុស្សបានមើលថា ពួកគេបានផ្តោតចិត្តខ្លាំងទៅលើប្រអប់ដ៏ស្រស់ស្អាតដែលដាក់មុក្តានោះ ជាជាងផ្តោតចិត្តទៅលើមុក្តានោះទៅវិញ ។ ស្រដៀងគ្នានេះផងដែរ នៅពេលយើងប្តូរពីការបង្រៀនតាមផ្ទះ និងការបង្រៀនសួរសុខទុក្ខ នោះយើងអាចផ្តោតចិត្តកាន់តែខ្លាំងលើ « មុក្តា » ដែលជាអត្ថន័យនៃការងារបម្រើ ជាជាងផ្តោតចិត្តលើ « ប្រអប់ » ដែលជាគោលនយោបាយ និងដំណើរការនោះ ។

**របៀបដើម្បីមានការសម្ភាសអំពីការងារបម្រើដ៏មានជោគជ័យ**

នៅក្នុងអត្ថបទនេះជាទម្រង់ឌីជីថល ស៊ីស្ទើរ ប៊ីងហាំង ចែកចាយនូវសេចក្តីណែនាំប្រាំយ៉ាងសម្រាប់ការសម្ភាសអំពីការងារបម្រើដ៏មានប្រយោជន៍ ។ សូមមើលគេហទំព័រ **lds.org/go/១២១៨១៣** ។

បរិសុទ្ធ » ពុំមែនមានន័យថា « គ្មានកំហុស និងពុំអាចសម្រេចបាន » នោះឡើយ ។

មិនថាអ្នកនៅតែពុំប្រាកដចិត្តអំពីគោលបំណងនៃការងារបម្រើ និងរបៀបដែលវាដំណើរការ ឬអ្នកគិតថា អ្នកយល់ពីវាហើយ នោះខ្ញុំសូមអញ្ជើញអ្នកឲ្យមើល និងអានធនធាននៅគេហទំព័រ **ministering.lds.org** និងសិក្សាអត្ថបទស្តីពីគោលការណ៍នៃការងារបម្រើដែលបានបោះពុម្ពចេញផ្សាយរៀងរាល់ខែនៅក្នុង *លីអាហូណា* ( សូមមើលទំព័រទី ៨ ក្នុងច្បាប់ចេញផ្សាយនេះ ) ។ សម្ភារទាំងនេះនឹងជួយឲ្យកិច្ចខិតខំនៃការងារបម្រើរបស់អ្នកស្របទៅនឹងកិច្ចការរបស់ព្រះអង្គសង្គ្រោះ ។

សូមអរគុណដល់បងប្អូនប្រុសស្រីដ៏អស្ចារ្យ សម្រាប់សេចក្តីស្រឡាញ់ និងការមើលថៃ និងឈោងទៅជួយ ព្រមទាំងការលះបង់ខ្លួនរបស់អ្នក ។ អ្នកពិតជាអស្ចារ្យណាស់ ហើយការងារបម្រើរបស់អ្នកនឹងក្លាយជា « អ្វីមួយដែលកាន់តែប្រពៃបំផុត ! »[២] ■





កំណត់ចំណាំ

១. រ័សុល អិម ណិលសុន « ការងារបម្រើ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០០ ។

២. អិមម៉ា ស្មីធ នៅក្នុង *Daughters in My Kingdom: The History and Work of Relief Society* ( ឆ្នាំ ២០១១ ) ទំព័រ ១៤ ។



**ដោយអែលឌើរ**
**អិល វិតនី ក្លេតុន**
ក្នុងគណៈប្រធាននៃ
ពួកចិតសិបនាក់



# អំណោយនៃ សេចក្ដីសុខសាន្ត របស់ព្រះអង្គសង្គ្រោះ

ទោះបីជានៅក្នុងពិភពលោកមួយដែលភាពសុខសាន្តហាក់ដូចជានៅដ៏សែនឆ្ងាយក្ដី ក៏អំណោយនៃភាពសុខសាន្តរបស់ព្រះអង្គសង្គ្រោះ អាចមាននៅក្នុងដួងចិត្តយើង មិនថាស្ថានភាពរបស់យើងជាយ៉ាងណាទេ ។

តើមានអ្វីផ្សេងទៀតដែលប្រសើរជាងតន្ត្រីបុណ្យគ្រីស្ទម៉ាស់ដ៏ពិរោះ ការជួបជុំគ្រួសារ និងមិត្តភក្ដិ ស្នាមញញឹមលើផ្ទៃមុខ និងភាពរីករាយដ៏ភ្លៀវភ្លារបស់កុមារតូចៗក្នុងពេលបុណ្យគ្រីស្ទម៉ាស់នោះ ? បុណ្យគ្រីស្ទម៉ាស់មានសមត្ថភាពដ៏ទេវភាពដើម្បីនាំយើងជួបជុំគ្នាជាគ្រួសារ មិត្តភក្ដិ និងសហគមន៍ ។ យើងទន្ទឹងចាំធ្វើការផ្លាស់ប្ដូរអំណោយគ្នា ហើយទទួលទានអាហារនៅថ្ងៃបុណ្យដ៏រីករាយនេះ ។

នៅក្នុង *ចម្រៀងបុណ្យគ្រីស្ទម៉ាស់* ដែលបាននិពន្ធដោយអ្នកនិពន្ធជនជាតិអង់គ្លេសឈ្មោះ ឆាលទ្បេស ឌីកគិន ជាក្មួយរបស់ អ៊ីប៉ែនណេហ្ស៊ី ស្ក្រូហ្គ បានរៀបរាប់នូវភាពអស្ចារ្យនៃគ្រាដ៏ពិសិដ្ឋនេះ ។ គាត់ឆ្លុះបញ្ចាំងថា « ខ្ញុំតែងតែគិតអំពីគ្រាបុណ្យគ្រីស្ទម៉ាស់ ពេលវាជិតមកដល់ . . . ជាពេលដ៏ល្អមួយ ជាពេលមានចិត្តល្អ អភ័យទោស សប្បុរស និងរីករាយ ជាពេលតែមួយគត់ដែលខ្ញុំដឹង នៅក្នុងប្រតិទិន ពេលបុរសស្ត្រីហាក់ដូចជាបើក . . . ដួងចិត្តរបស់ពួកគេដោយសេរី ហើយគិតអំពី [ មនុស្សដទៃ ] ។ . . . ហេតុដូច្នោះហើយ . . . ទោះខ្ញុំពុំដែលធ្លាប់ទទួលបានមាស ឬប្រាក់ចូលក្នុងថង់របស់ខ្ញុំមកពីបុណ្យគ្រីស្ទម៉ាស់ក្ដី ក៏ខ្ញុំជឿថា វា *បាន* ល្អដល់ខ្ញុំ ហើយខ្ញុំ *នឹង* បានល្អ ហើយខ្ញុំនិយាយថា ព្រះប្រទានពរ ! »[១]

ក្នុងនាមជាឪពុក ឥឡូវជាជីតា ខ្ញុំបាននឹកចាំពីបុណ្យគ្រីស្ទម៉ាស់ដ៏អស្ចារ្យ ពេលខ្ញុំបានមើលកូនៗរបស់ខ្ញុំ ហើយឥឡូវកូនៗរបស់ពួកគេ សាទរដល់ការប្រសូតរបស់ព្រះអង្គសង្គ្រោះ ហើយរីករាយនឹងជួបជុំគ្នាជាការជួបជុំក្រុមគ្រួសាររបស់យើង ។ ខ្ញុំដឹងច្បាស់ថាអ្នកបានមើលឃើញ ដូចខ្ញុំបានមើលឃើញនូវអំណរ និងចិត្តបរិសុទ្ធដែលកូនៗទន្ទឹងចាំ ហើយរីករាយក្នុងបុណ្យដ៏ពិសេសនេះ ។ ការមើលឃើញអំណររបស់ពួកគេ បានរំឭកដល់យើងម្នាក់ៗអំពីភាពរីករាយនៃបុណ្យគ្រីស្ទម៉ាស់ដែលបានកន្លងផុតទៅជាច្រើននោះ ។ ឌីកគិនបានសង្កេតម្ដងទៀតថា « ពេលខ្លះវាល្អដើម្បីធ្វើជាកុមារតូចៗ ហើយគ្មានអ្វីប្រសើរជាងបុណ្យគ្រីស្ទម៉ាស់ទ្បើយ នៅពេលដែលអង្គបង្កើតដ៏មហិទ្ធិឫទ្ធិ គឺជាព្រះកុមារផ្ទាល់តែម្ដង » ។[២]

ខ្ញុំបានកើតនៅជិតនឹងទីក្រុង ឡូស អាន់ជើរទ្បេស រដ្ឋ កាលីហ្វូញ៉ា ស.រ.អា. ជាកន្លែងដែលគេហដ្ឋានរបស់យើងត្រូវបានហ៊ុមទ័ព្វទៅដោយចម្ការក្រូច ។ នៅល្ងាចនៃបុណ្យគ្រីស្ទម៉ាស់ម្ដងៗ ឪពុកម្ដាយរបស់ខ្ញុំបានអញ្ជើញគ្រួសារ មិត្តភក្ដិ និងអ្នកជិតខាងមកផ្ទះរបស់យើងច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ ហើយទទួលទានអាហារ ។ វាគឺជាទំនៀមទម្លាប់ដ៏អស្ចារ្យមួយសម្រាប់យើងទាំងអស់គ្នា ហើយការច្រៀងហាក់ដូចជាបន្តទៅយ៉ាងយូរ ។ យើងដែលជាកូនៗនឹងច្រៀងយ៉ាងយូរតាមដែលយើងមានអារម្មណ៍ថាត្រូវច្រៀង បន្ទាប់មកយើងនឹងគេចទៅលេងនៅក្នុងចម្ការក្រូច ។

ភរិយារបស់ខ្ញុំ ខាសុី និង ខ្ញុំក៏បានមានគ្រួសាររបស់យើងនៅរដ្ឋកាលីហ្វូញ៉ាភាគខាងត្បូងផងដែរ នៅជិតនឹងឆ្នេរសមុទ្រ ។ បុណ្យគ្រីស្ទម៉ាស់នៅទីនោះ ត្រូវបានចាត់ទុកដូចជាដើមដូងដែលរេរាំតាមខ្យល់ជំនោរ ។ ជារៀងរាល់ឆ្នាំ កូនៗរបស់យើងទន្ទឹងចាំចុះទៅកំពង់ផែដើម្បីមើលការបណ្ដែតប្រទីបបុណ្យគ្រីស្ទម៉ាស់ប្រចាំឆ្នាំ ។ មានប្រទីបស្អាតៗរាប់រយ បំភ្លឺដោយពន្លឺគ្រប់ពណ៌ចម្រុះ បណ្ដែតនៅជុំវិញផែនៅពេលដែលយើងមើលដោយស្ងើចអស្ចារ្យ ។

ឥឡូវ យើងរស់នៅក្នុងទីក្រុងសលត៍ លេក រដ្ឋ យូថាហ៍ ស.រ.អា. ខាសុី និងខ្ញុំបានបង្កើតទំនៀមទម្លាប់មួយក្នុងការនាំកូនៗ និងចៅៗរបស់យើងទៅកន្លែងផលិតកម្មក្នុងស្រុកដែល

*ប្រសូតកម្មជាពណ៌ទង់ដែង និងស្លេ ដោយ ជេ ខឹក រីឆាដ*



អារម្មណ៍នៃរដូវបុណ្យគ្រីស្ទម៉ាស់ដែលធ្វើឲ្យមានការផ្លាស់ប្រែ ត្រូវបានចាក់ឫសនៅក្នុងព្រះចេស្ដាប្រោសលោះនៃព្រះយេស៊ូវគ្រីស្ទដើម្បីផ្លាស់ប្ដូរជីវិតរបស់យើងឲ្យកាន់តែល្អប្រសើរ ។

សម្ដែង *ចម្រៀងបុណ្យគ្រីស្ទម៉ាស់មួយ* ។ ជារៀងរាល់ឆ្នាំ នៅពេលយើងមើលស្គ្រូហ្គ ឆ្លងកាត់ការផ្លាស់ប្រែដ៏អស្ចារ្យរបស់គាត់ពីមនុស្សពុំមានចិត្តចង់រាប់រកអ្នកដទៃទៅប្រែជាអ្នកជិតខាងដ៏រីករាយម្នាក់ដែលពេញដោយក្ដីអំណរនៃបុណ្យគ្រីស្ទម៉ាស់ នោះយើងមានអារម្មណ៍ថា ចង់ផ្លាស់ប្ដូរឥរិយាបថដែលយើងមានដូចជាស្គ្រូហ្គ នៅក្នុងខ្លួនយើង ។ យើងមានអារម្មណ៍បំផុសគំនិតឲ្យធ្វើបានល្អប្រសើរបន្តិចម្ដងៗ ដើម្បីធ្វើតាមគំរូនៃសេចក្ដីសប្បុរសរបស់ព្រះអង្គសង្គ្រោះចំពោះមនុស្សគ្រប់រូប ។

## អំណាចនៃសេចក្ដីប្រោសលោះរបស់ព្រះយេស៊ូវគ្រីស្ទ

អារម្មណ៍នៃរដូវបុណ្យគ្រីស្ទម៉ាស់ដែលធ្វើឲ្យមានការផ្លាស់ប្រែ ត្រូវបានចាក់ឫសនៅក្នុងព្រះចេស្ដាប្រោសលោះនៃព្រះយេស៊ូវគ្រីស្ទ ដើម្បីផ្លាស់ប្ដូរជីវិតរបស់យើងឲ្យកាន់តែល្អប្រសើរ ។ ដំណើររឿងជាទីស្រឡាញ់នៃការប្រសូតរបស់ព្រះរាជបុត្រានៃព្រះដែលបានកើតឡើងជាងពីរពាន់ឆ្នាំកន្លងទៅនៅក្នុងភូមិបេថ្លេហិម ត្រូវបានកត់ត្រានៅក្នុងគម្ពីរលូកា ៖

« នៅគ្រានោះ សេសារ-អូគូស្ទ បានចេញព្រះរាជឱង្ការមួយច្បាប់ឲ្យមនុស្សទាំងអស់ដែលនៅផែនដីបានចុះបញ្ជី ។ . . .

មនុស្សទាំងអស់ក៏ទៅឯស្រុកកំណើតរៀងខ្លួនដើម្បីចុះបញ្ជី ។

ឯយ៉ូសែបគាត់ក៏ចេញពីណាសារ៉ែត ស្រុកកាលីឡេ ឡើងទៅស្រុកយូដា ដល់ក្រុងរបស់ហ្លួងដាវីឌ ដែលឈ្មោះថា បេថ្លេហិម ។ . . .

ដើម្បីនឹងចុះបញ្ជីជាមួយនឹងម៉ារាដែលបានបម្រុងទុកឲ្យធ្វើជាប្រពន្ធគាត់ ដែលនាងមានគភ៌នោះ ។

កាលកំពុងតែនៅទីនោះ វេលាដែលនាងត្រូវប្រសូតក៏មកដល់ ។

ហើយនាងប្រសូតបានបុត្រាជាចម្បងមក រួចរុំនឹងសំពត់ផ្ដេកក្នុងស្នូក ពីព្រោះក្នុងផ្ទះសំណាក់គ្មានកន្លែងណានៅទេ ។

រីឯនៅស្រុកនោះ ឯងមានពួកអ្នកគង្វាល ដែលចាំយាមរក្សាហ្វូងចៀមរបស់ខ្លួននៅឯវាលក្នុងវេលាយប់ ។

នោះមើល មានទេវតានៃព្រះអម្ចាស់មកឈរជិតគេ ឯសិរីល្អរបស់ទ្រង់ក៏ភ្លឺឆ្វាត់ជុំវិញ ហើយគេមានសេចក្ដីភ័យខ្លាចជាខ្លាំង ។

តែទេវតាប្រាប់ថា កុំខ្លាចអី មើល ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ពីសេចក្ដីអំណរយ៉ាងអស្ចារ្យ ដែលសម្រាប់បណ្ដាជនទាំងអស់គ្នា ។

ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះ ១ អង្គប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ ។

ហើយនេះជាទីសម្គាល់ដល់អ្នករាល់គ្នា គឺអ្នករាល់គ្នានឹងឃើញព្រះឱរស ១ រុំនឹងសំពត់ផ្ដេកនៅក្នុងស្នូក ។

នោះស្រាប់តែមានពួកពលបរិវារកកកុញស្ថានសួគ៌មកនៅជាមួយនឹងទេវតានោះ ក៏ពោលសរសើរដល់ព្រះថា

សួស្ដីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្ដីសុខសាន្តនៅផែនដី នៅកណ្ដាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់ » ( លូកា ២:១, ៣–១៤ ) ។

## ចូរកុំខ្លាចឡើយ

ទេវតាបានដឹងអំពីភាពភ័យខ្លាចរបស់ពួកអ្នកគង្វាល នៅពេលទ្រង់បង្ហាញកាយដល់ពួកគេ ដោយប្រាប់ពួកគេថា « កុំខ្លាចឡើយ » ។ សិរីល្អដ៏អស្ចារ្យរបស់ព្រះ ដែលបានបញ្ចេញរស្មីមកពីសារទូតសួគ៌ា ដោយពុំបានរំពឹងទុកនោះ ពិតជាធ្វើឲ្យដួងចិត្តរបស់ពួកគេភ័យខ្លាចណាស់ ។ ប៉ុន្តែដំណឹងល្អដែលទេវតាបាននាំមកចែកចាយនោះ គឺគ្មានអ្វីគួរឲ្យភ័យខ្លាចទេ ។ ទ្រង់បានមកប្រកាសអំពីអព្ភូតហេតុមួយ ដើម្បីនាំដំណឹងល្អដ៏សំខាន់ ប្រាប់ដល់ពួកគេថា ការប្រោសលោះមនុស្សលោកពិតជាបានចាប់ផ្ដើមឡើងហើយ ។ គ្មានសារលិខិតណាផ្សេងទៀតពីមុន ឬបន្ទាប់ពីនោះ នាំមកនូវការស្វាគមន៍ដ៏រីករាយជាងនោះទេ ។

បុត្រសំណព្វតែមួយគត់របស់ព្រះបិតា បានចាប់ផ្ដើមដំណើរជីវិតរមែងស្លាប់របស់ទ្រង់ ៖ « ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះមួយអង្គ

ពួកអ្នកគង្វាលត្រូវបានប្រាប់ឲ្យដឹង ដោយ ជេ ខឹក ថែងម



ប្រសូតដល់អ្នករាល់គ្នានៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ » ។ ទាំងនេះគឺជាដំណឹងល្អដ៏ពិតនៃអំណរដ៏មហិមា ។

យើងម្នាក់ៗជួបនឹងព្រឹត្តការណ៍ជាច្រើនក្នុងជីវិតយើង ពេលអំណរដ៏មហិមាដែលទេវតាបានសន្យា អាចហាក់ដូចជាមិនអាចទទួលយកបាន ។ យើងទាំងអស់គ្នា ស្ថិតនៅក្រោមភាពទន់ខ្សោយ និងការលំបាកនៃជីវិត—ជំងឺ ការបរាជ័យ បញ្ហា ការខកចិត្ត និងទីបំផុតគឺសេចក្ដីស្លាប់ ។ ទន្ទឹមនឹងពេលដែលមនុស្សជាច្រើនត្រូវបានប្រទានពរឲ្យរស់ដោយមានសុវត្ថិភាពខាងរូបកាយ ក៏មានអ្នកផ្សេងទៀតពុំមានអ្វីទាំងនោះទេសព្វថ្ងៃនេះ ។ មនុស្សជាច្រើនបានជួបនឹងការលំបាកដ៏ធំក្នុងការបំពេញតាមតម្រូវការនៃជីវិត និងរូបកាយ និងសតិអារម្មណ៍ ។

ប៉ុន្តែមិនថា ការលំបាកក្នុងជីវិតមានយ៉ាងណាទេ សារលិខិតរបស់ព្រះអម្ចាស់ចំពោះយើងម្នាក់ៗ គឺនៅថ្ងៃនេះដូចគ្នានឹងថ្ងៃដែលពួកអ្នកគង្វាលបានទន្ទឹងចាំមើលកាលពី ២០០០ ឆ្នាំកន្លងទៅផងដែរ ៖ « ចូរកុំខ្លាចឡើយ » ។ ប្រហែលជាពាក្យបង្គាប់របស់ទេវតាថា កុំខ្លាចឡើយ មានជាប់ទាក់ទងនឹងយើងយ៉ាងខ្លាំងសព្វថ្ងៃនេះ ជាងគ្រាដែលទ្រង់រម្ងាប់ភាពភ័យខ្លាចរបស់ពួកអ្នកគង្វាលនារាត្រីបុណ្យគ្រីស្ទម៉ាស់ដំបូងនោះទៅទៀត ។ តើទ្រង់អាចនឹងចង់មានន័យប្រាប់យើងឲ្យយល់ថា ដោយសារព្រះអង្គសង្គ្រោះ ទើបភាពភ័យខ្លាចនឹងគ្មានជ័យជម្នះផងដែរឬ ? ដើម្បីពង្រឹងដល់យើងថា ចុងបញ្ចប់នៃភាពភ័យខ្លាចគឺពុំត្រូវបានដោះសារឡើយ ដើម្បីរំឭកយើងថា គ្មានបញ្ហានៅលើផែនដីណា នឹងមានជារៀងរហូត ដែលគ្មានគ្នាយើងណាម្នាក់ពុំអាចទទួលការប្រោសលោះនោះឡើយ ?

អំណោយដ៏ផ្អែមល្ហែមបំផុតដែលបានប្រទាននៅបុណ្យគ្រីស្ទម៉ាស់ នឹងជាអំណោយមួយដែលព្រះអង្គសង្គ្រោះផ្ទាល់បានប្រទានដល់យើងជានិច្ចនោះគឺ ៖ ភាពសុខសាន្តដ៏ឥតខ្ចោះរបស់ទ្រង់ ។ ទ្រង់មានបន្ទូលដូចនេះ ៖ « ខ្ញុំទុកសេចក្ដីសុខនៅនឹងអ្នករាល់គ្នា គឺខ្ញុំឲ្យសេចក្ដីសុខសាន្តរបស់ខ្ញុំដល់អ្នករាល់គ្នា ហើយដែលខ្ញុំឲ្យ នោះមិនមែនដូចជាលោកីយ៍ឲ្យទេ ។ កុំឲ្យចិត្តអ្នករាល់គ្នាថប់បារម្ភ ឬភ័យឡើយ » ( យ៉ូហាន ១៤:២៧ ) ។

ទោះបីជានៅក្នុងពិភពលោកមួយដែលភាពសុខសាន្តហាក់ដូចជានៅដ៏សែនឆ្ងាយក្ដី ក៏អំណោយនៃភាពសុខសាន្តរបស់ព្រះអង្គសង្គ្រោះ អាចមាននៅក្នុងដួងចិត្តយើង មិនថាស្ថានភាពរបស់យើងជាយ៉ាងណាទេ ។ ប្រសិនបើយើងទទួលយកការអញ្ជើញរបស់ព្រះអង្គសង្គ្រោះឲ្យដើរតាមទ្រង់ នោះភាពភ័យខ្លាចនឹងរលាយបាត់ទៅជារៀងរហូត ។ អនាគតរបស់យើងនឹងមានសុវត្ថិភាព ។ ទាំងនេះជា « ដំណឹងល្អដល់អ្នករាល់គ្នាពីសេចក្ដីអំណរយ៉ាងអស្ចារ្យដែលសម្រាប់បណ្ដាជនទាំងអស់គ្នា » ។

ព្យាការីអេសាយបានរំឭកយើងថា « កុំឲ្យភ័យខ្លាចឡើយ ដ្បិតយើងនៅជាមួយនឹងឯង កុំឲ្យស្រយុតចិត្តឲ្យសោះ ពីព្រោះយើងជាព្រះនៃឯង ៖ យើងនឹងចម្រើនកម្លាំងដល់ឯង អើ យើងនឹងជួយឯង អើ យើងនឹងទ្រឯង ដោយដៃស្ដាំដ៏សុចរិតរបស់យើង » ( អេសាយ ៤១:១០ ) ។

## សេចក្ដីសង្ឃឹមលើព្រះអង្គសង្គ្រោះ

ដោយសារតែព្រះអង្គសង្គ្រោះបានប្រសូតមកតាំងពី ២០០០ ឆ្នាំកន្លងទៅនៅភូមិបេថ្លេហិម ទើបមានក្ដីសង្ឃឹម—និងអ្វីៗដ៏ច្រើនសន្ធឹកទៀត ។ មានការប្រោសលោះ ការរំដោះ ជ័យជម្នះ និងជោគជ័យ ។ « កំហុសនឹងបរាជ័យ ភាពត្រឹមត្រូវនឹងមានជ័យជម្នះ » ។[៣]

វាពុំគួរភ្ញាក់ផ្អើលទេ ដែលក្រុមចម្រៀងពួកទេវតាបានលេចមកភ្លាមៗនោះ ជាការគូសបញ្ជាក់ពីស្ថានសួគ៌ដល់ការប្រកាសរបស់ទេវតាអំពីការប្រសូត្ររបស់ព្រះអង្គសង្គ្រោះដោយច្រៀងបទ « សួស្ដីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្ដីសុខសាន្តនៅផែនដី នៅកណ្ដាលមនុស្ស » ។ គ្មានសារលិខិតណាដែលអាចមានការអះអាងខ្លាំងជាងនេះទេ ។ គ្មានសារលិខិតណាដែលមាននៅកណ្ដាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់ខ្លាំងជាងនេះទេ ។

សូមឲ្យរដូវនេះជាក្ដីសុខសាន្ត និងអំណរចំពោះយើងទាំងអស់គ្នា « ដ្បិតនៅថ្ងៃ [ នេះ ] មានព្រះអង្គសង្គ្រោះមួយអង្គប្រសូតដល់ [ យើង ] នៅក្រុងហ្លួងដាវីឌ គឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ » ។ ■

ដកស្រង់មកពីសុន្ទរកថាការប្រជុំធម្មនិដ្ឋានបុណ្យគ្រីស្ទម៉ាស់របស់គណៈប្រធានទីមួយដែលមានចំណងជើងថា « ចូរកុំខ្លាចឡើយ » ដែលបានថ្លែងនៅថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០១៥ នៅក្នុងមជ្ឈមណ្ឌលសន្និសីទ ។

**កំណត់ចំណាំ**

១. Charles Dickens *A Christmas Carol* ( ឆ្នាំ ១៨៥៨ ) ទំព័រ ៥–៦ ។
២. *A Christmas Carol* ទំព័រ ៦៧ ។
៣. « I Heard the Bells on Christmas Day » *ទំនុកតម្កើង* លេខរៀង ២១៤ ។



# ធ្វើឲ្យបានល្អប្រសើរបន្តិចជាងពី

# ម្សិលមិញ

ដោយ ល្វីស អូម៉ា ខាដូស្សូ

**នៅ**ពេលប្រធានបេសកកម្មរបស់គាត់បានទូរសព្ទមក នោះស្ទីអូបានបម្រើបេសកកម្មបានជិតមួយឆ្នាំហើយ ។ គាត់គឺជាកូនប្រុសតែម្នាក់គត់របស់យើង ហើយគាត់គឺជាកូនដំបូងរបស់យើងដែលទៅបម្រើបេសកកម្មពេញម៉ោង ។ លីលៀណាភរិយារបស់ខ្ញុំ និងខ្ញុំមានមោទនភាពចំពោះគាត់ និងគំរូដែលគាត់បានធ្វើសម្រាប់ប្អូនស្រីទាំងពីររបស់គាត់ ។

ស្ទីអូមានរបៀបពិសេសមួយអំពីខ្លួនគាត់ ដែលយើងបានដឹងថា នឹងធ្វើឲ្យគាត់ក្លាយជាអ្នកផ្សព្វផ្សាយសាសនាល្អ ។ គាត់មានភាពជាអ្នកដឹកនាំតាំងពីកំណើត គាត់រីករាយ ហើយមានចិត្តស្មោះសរ ហើយគាត់អាចជំរុញទឹកចិត្តអ្នកដទៃបាន ។

វាមិនជាបញ្ហាចំពោះគាត់ឡើយ ទោះជាបុគ្គលនោះជាសមាជិកសាសនាចក្រឬមិនមែនជាសមាជិកក្តី—គាត់រាប់អានមិត្តជាមួយមនុស្សគ្រប់គ្នា ។ ហើយប្រសិនបើអ្នកដទៃសើចចំអកដាក់គាត់ដោយសារតែគាត់ជាពួកបរិសុទ្ធថ្ងៃចុងក្រោយ នោះគាត់បានទទួលវាដោយកំប្លែង និងកម្រអាក់អន់ចិត្តណាស់ ។

យើងមានចិត្តរំភើប នៅពេលស្ទីអូបានទទួលការហៅបេសកកម្មរបស់គាត់ទៅបេសកកម្មពេរូ ឈីខ្លាយ៉ូ ។ គាត់បានចាប់ផ្តើមការបម្រើរបស់គាត់នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៣ ។ គាត់ស្រឡាញ់បេសកកម្មរបស់គាត់ ។ នៅគ្រាដំបូង វាមានភាពងាយស្រួលក្នុងការសរសេរសំបុត្រទៅគាត់ ។ ប៉ុន្តែយូរៗទៅខ្ញុំត្រូវការពេលវេលាបន្ថែមទៀតដើម្បីគិតអំពីសំបុត្ររបស់គាត់ និងឆ្លើយតបចំពោះការរីកចម្រើនខាងវិញ្ញាណរបស់គាត់ ។

យើងពុំបានបារម្ភអំពីស្ទីអូទេ ។ យើងបានគិតថា តំបន់បេសកកម្មគឺជាកន្លែងដ៏មានសុវត្ថិភាពបំផុតសម្រាប់គាត់ ។ ប្រធានបេសកកម្មរបស់គាត់បានទូរសព្ទមកយើងនៅថ្ងៃទី ៧ ខែ តុលា ឆ្នាំ ២០១៤ ។

### យើងពុំមានអារម្មណ៍ថាឯកោឡើយ

ប្រធានបេសកកម្មបានប្រាប់យើងថា ស្ទីអូ និងដៃគូរបស់គាត់បានបង្រៀនសាសនាគន់ការីអំពីព្រះវិហារបរិសុទ្ធ និងក្រុមគ្រួសារអស់កល្បជានិច្ច ។ បន្ទាប់មក នៅពេលស្ទីអូបានអធិស្ឋានបិទ គាត់បានឈប់មួយសន្ទុះ ហើយរំពេចនោះ គាត់បានសន្លប់បាត់ស្មារតី ហើយបានដួលចុះទៅលើកម្រាលឥដ្ឋ ។ គាត់បានទទួលការប្រសិទ្ធពរ ហើយគេបានបញ្ជូនគាត់យ៉ាងលឿនទៅកាន់មន្ទីរពេទ្យ ។ វេជ្ជបណ្ឌិតបានកំណត់ថា គាត់បានរងឈឺចាប់ដោយសារការដាច់សសៃឈាមដែលប៉ោងនៅក្នុងខួរក្បាល ។ វេជ្ជបណ្ឌិតបានព្យាយាមជួយធ្វើឲ្យគាត់ដឹងខ្លួនវិញ ប៉ុន្តែវាគ្មានប្រយោជន៍ឡើយ ។

ដំណឹងនេះបានធ្វើឲ្យយើងកើតទុក្ខជាខ្លាំង ។ ទោះបីជាយើងមានទុក្ខលំបាកក្តី លីលៀណា និងខ្ញុំបានធ្វើដំណើរទៅពេរូ ដើម្បីទៅទទួលសាកសព និងរបស់របរប្រើប្រាស់ផ្ទាល់ខ្លួនរបស់ស្ទីអូ ។ យើងមាន

គំនូរដោយ ស្ទីវ ក្រប់

ស៊្រីមែណាប្អូនស្រីរបស់សូជីអូចែកចាយគំនិតរបស់នាងអំពីមរណភាពរបស់សូជីអូនៅគេហទំព័រ **lds.org/go/១២១៨១៩** ។

ភាពស្មុគស្មាញដែលធ្វើឲ្យគិតពុំបានច្បាស់លាស់ ដូច្នេះយើងមានអំណរគុណចំពោះសមាជិកដែលមកពីសាសនាចក្រ—ចាប់តាំងពីគ្រាដែលយើងបានចេញពីផ្ទះយើង រហូតដល់យើងត្រឡប់មកវិញ—បាននៅទីនោះដើម្បីជួយយើង ។ យើងក៏ទទួលបានជំនួយមកពីព្រះវិញ្ញាណបរិសុទ្ធ ដែលបានលួងលោមយើង ហើយបានជួយយើងឲ្យមានការស៊ូទ្រាំ ។ យើងពុំមានអារម្មណ៍ថាឯកោឡើយ ។

វាលំបាកនឹងរកឃើញអំណរគុណនៅក្នុងគ្រាលំបាក ប៉ុន្តែខ្ញុំមានអំណរគុណចំពោះសេចក្ដីមេត្តាករុណាដ៏ទន់ភ្លន់របស់ព្រះអម្ចាស់ ដែលទាក់ទងនឹងមរណភាពរបស់សូជីអូ ។ នៅពេលគាត់ស្លាប់ ខ្ញុំកំពុងបម្រើជាប៊ីស្សព ហើយលីលៀណាគឺជាគ្រូបង្រៀនថ្នាក់សិក្ខាសាលា ហើយកូនស្រីរបស់យើង ស៊្រីមែណាកំពុងបម្រើជាប្រធានយុវនារីវួដ ។ យើងមានភាពមមាញឹកក្នុងការបម្រើ និងស្រឡាញ់អ្នកដទៃ ដែលបានពង្រឹងយើងនៅក្នុងដំណឹងល្អ ។ ប្រសិនបើសូជីអូបានចាកចេញពីយើង នោះខ្ញុំនឹងមានអំណរគុណជានិច្ចថា ព្រះវរបិតាសួគ៌បានយកគាត់ទៅ អំឡុងពេលដែលយើងមានភាពរឹងមាំនៅក្នុងសេចក្ដីជំនឿ ។

ខ្ញុំក៏មានអំណរគុណដែលសូជីអូបានស្លាប់ទៅអំឡុងពេលបម្រើព្រះអម្ចាស់ និងអំឡុងពេល « នៅក្នុងការបម្រើដល់មនុស្ស [ របស់គាត់ ] » ( ម៉ូសាយ ២:១៧ ) ។ ព្រះអម្ចាស់បានប្រកាសថា « អស់អ្នកណាដែលស្លាប់ក្នុងយើង នោះនឹងមិនត្រូវភ្លក់សេចក្ដីស្លាប់ឡើយ ដ្បិតសេចក្ដីស្លាប់នឹងបានទៅជាសេចក្ដីផ្អែមល្ហែមដល់ពួកគេវិញ » ( គ. និង ស. ៤២:៤៦ ) ។

ព្រះវិញ្ញាណបរិសុទ្ធបានប្រទានដល់ខ្ញុំនូវការឃើញមួយភ្លែត នូវអ្វីដែលព្រះវរបិតាសួគ៌ត្រូវតែស៊ូទ្រាំ នៅពេលបុត្រាសំណព្វតែមួយរបស់ទ្រង់បានសុគតសម្រាប់ពួកយើង ។ ខ្ញុំបានដឹងថា ខ្ញុំគ្មានសិទ្ធិខឹងសម្បានឹងព្រះឡើយ ។ ព្រះវរបិតាដែលគង់នៅស្ថានសួគ៌របស់ខ្ញុំ បានជ្រាបដឹងអំពីអ្វី ដែលខ្ញុំបានហែលឆ្លងកាត់ ។ សេចក្ដីសុខសាន្តបានគ្របសណ្ដប់លើរូបខ្ញុំ ដែលធ្វើឲ្យខ្ញុំទទួលយកព្រះទ័យទ្រង់ និងពេលវេលានៃមរណភាពរបស់សូជីអូ ។ លីលៀណាបានទទួលបទពិសោធន៍ និងទទួលអារម្មណ៍ដូចនេះផងដែរ ។

**ពាក្យលួងលោម**

គ្រួសាររបស់យើងបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធនៅក្នុងឆ្នាំ ២០០៥ ពេលដែលសូជីអូ និង ស៊្រីមែណានៅតូច ។ ក្រោយមក រុស្សបានកើតក្នុងសេចក្ដីសញ្ញា ។ ពីមុនគាត់បានចេញទៅបម្រើបេសកកម្ម សូជីអូបានជ្រមុជទឹកឲ្យរុស្ស ។

បីថ្ងៃបន្ទាប់ពីសូជីអូស្លាប់ រុស្សបានសុបិនឃើញសូជីអូ ។ វាជារាត្រីនៃថ្ងៃខួបកំណើតអាយុប្រាំបួនឆ្នាំរបស់រុស្ស ។ រុស្សបានសុបិនឃើញថា ពួកគេទាំងពីរនាក់បានដើរកាន់ដៃគ្នាពេញមួយថ្ងៃ ហើយថាសូជីអូបាននិយាយពាក្យលួងលោមទៅកាន់នាង ។

> យើងត្រូវបន្តរស់នៅតាមដំណឹងល្អ ។ នោះជារបៀបដែលសូជីអូអាចក្លាយជាកូនប្រុសរបស់យើងម្តងទៀត ។

រុស្ស និង ស៊្រីមែណាមានភាពស្និទ្ធស្នាលនឹងសូជីអូ ហើយពួកគេនឹកគាត់ខ្លាំងណាស់ ។ រុស្សនៅតែទទួលការលួងលោមពីការចងចាំនៃសុបិនរបស់នាង ។

ថ្ងៃមួយ នៅពេលយើងកំពុងរៀបចំរបស់ប្រើប្រាស់របស់សូជីអូ នោះលីលៀណា និងខ្ញុំបានឃើញសៀវភៅផែនការប្រចាំថ្ងៃនៃបេសកកម្មរបស់គាត់ ។ យើងបានសម្គាល់ឃើញថា នៅលើទំព័រនីមួយៗគ្រប់ថ្ងៃទាំងអស់ សូជីអូបានសរសេរឃ្លាថា « ចូរធ្វើខ្លួនឲ្យបានល្អប្រសើរបន្តិចជាងពីម្សិលមិញ » ។

ពាក្យទាំងនោះមិនទៅណាឆ្ងាយពីខ្ញុំឡើយ ។ ពាក្យទាំងនោះរំឭកខ្ញុំថា យើងត្រូវបន្តរស់នៅតាមដំណឹងល្អ ។ នោះជារបៀបដែលយើងអាចរស់នៅជាមួយគ្នាជាគ្រួសារបន្ទាប់ពីជីវិតនេះ ។ នោះជារបៀបដែលសូជីអូអាចក្លាយជាកូនប្រុសរបស់យើងម្តងទៀត ។

នៅពេលយើងឆ្លងកាត់គ្រាលំបាកៗ នោះព្រះអង្គសង្គ្រោះនឹងជួយយើង ។ ខ្ញុំដឹងថា វាជាការពិតគឺដូចខ្ញុំដឹងថា ការសន្យារបស់ទ្រង់គឺពិតប្រាកដ ។ ដូច្នេះយើងបានបន្តកាន់ខ្ជាប់នឹងដំណឹងល្អ ហើយយើងធ្វើតាមគំរូរបស់សូជីអូ ។ យើងព្យាយាមប្រែកាន់តែល្អប្រសើរឡើងរៀងរាល់ថ្ងៃ ។ ■

*អ្នកនិពន្ធរស់នៅទីក្រុងសាលតា ប្រទេសអាហ្សង់ទីន ។*







**ដោយអែលឌើរ**
**ជែហ្វ្រី អ័រ ហូឡិន**
ក្នុងកូរ៉ុមនៃពួកសាវក
ដប់ពីរនាក់

## ការធ្វើឲ្យជីវិតរបស់អ្នកក្លាយជាដំណើរដ៏បំផុសគំនិតនៃ

# ការរីកចម្រើនផ្ទាល់ខ្លួន

ការរៀនសូត្រ ការរស់នៅតាម និងការបង្រៀនដំណឹងល្អគឺជាផ្នែកសំខាន់នៃការរីកចម្រើនឆ្ពោះទៅកាន់សក្ដានុពលនៃភាពជាព្រះរបស់ពួកយើង ។

កំណត់ចំណាំរបស់អ្នកបោះពុម្ពផ្សាយ ៖ នៅក្នុងអត្ថបទដែលសរសេរសម្រាប់ *លីអាហូណា* នេះ អែលឌើរហូឡិនចែកចាយអំពីគោលការណ៍ដ៏មានឥទ្ធិពលនៃការប្រែចិត្តជឿ ដែលក្លាយជាគ្រឹះសម្រាប់កម្មវិធីសិក្សាថ្មីរបស់សាសនាចក្រគឺ *ចូរមកតាមខ្ញុំ* ។

ឱនេះគឺជាគ្រាដ៏គួរឲ្យរំភើបអ្វីម្ល៉េះ ដើម្បីធ្វើជាសមាជិកនៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ! ពេលខ្ញុំគិតអំពីការអភិវឌ្ឍថ្មីៗនេះនៅក្នុងនគររបស់ព្រះអម្ចាស់ នោះវាហាក់ដូចជាឃើញច្បាស់ថា ព្រះកំពុងនាំយើងនៅលើដំណើរដ៏បំផុសគំនិតមួយដែលពោរពេញដោយព្រឹត្តិការណ៍ និងបទពិសោធន៍អស្ចារ្យ ដែលធ្វើឲ្យយើងពិបាកនឹងស្រមៃដល់ និងមានអំណរគុណទាំងស្រុង លុះត្រាណាយើងបានទទួលការយល់ និងមានទស្សនវិស័យកាន់តែប្រសើរឡើង ។

កាលពីឆ្នាំមុន យើងបានលាព្យាការីជាទីស្រឡាញ់របស់យើង និងបានគាំទ្រដោយក្ដីស្រឡាញ់ដល់ព្យាការីថ្មីរបស់យើង ។ យើងបានផ្លាស់ប្ដូរការប្រជុំថ្នាក់សមាគមសង្គ្រោះ និងកូរ៉ុមបព្វជិតភាពជាមួយនឹងការគូសបញ្ជាក់កាន់តែប្រសើរឡើង អំពីការប្រឹក្សារួមគ្នាដើម្បីសម្រេចបាននូវកិច្ចការរបស់ព្រះអម្ចាស់ ។ នៅក្នុងស្មារតីដូចគ្នានេះ យើងបានឃើញព្រះអម្ចាស់ដាក់បញ្ចូលក្រុមសង្ឃជាន់ខ្ពស់ និងពួកអែលឌើរឲ្យនៅក្នុងកូរ៉ុមតែមួយ ហើយបានឃើញការផ្លាស់ប្ដូរដ៏ធំនៅក្នុងរបៀបដែលអ្នកកាន់បព្វជិតភាព និងបងប្អូនស្រីផ្ដល់ការងារបម្រើដល់បុត្រាបុត្រីរបស់ព្រះ ។ ប្រសិនបើរឿងនោះមិនគ្រប់គ្រាន់ដែលធ្វើឲ្យអ្នកមានភាពអស្ចារ្យក្នុងចិត្តទេនោះ សូមពិចារណាអំពីការប្រកាសថ្មីៗនេះរបស់គណៈប្រធាន

រូបភាពមកពី GETTY IMAGES

ទីមួយអំពីធនធានថ្មីៗ ដើម្បីគាំទ្រដល់ការសិក្សាផ្ទាល់ខ្លួន និងការសិក្សាព្រះគម្ពីរជាគ្រួសារ ស្របជាមួយនឹងការផ្លាស់ប្ដូរនូវសម្ភារសម្រាប់ថ្នាក់អង្គការបឋមសិក្សា និងថ្នាក់សាលាថ្ងៃអាទិត្យអ្វីៗទាំងនេះពុំទាន់បាននិយាយអំពីការលើកកម្ពស់ដល់ផ្នែកនានានៃកិច្ចការផ្សព្វផ្សាយសាសនា ការស្រាវជ្រាវពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធផង ។

ហើយប្រាកដណាស់នឹងមានអ្វីៗជាច្រើនដែលនឹងកើតឡើង ។ ដូចមាត្រានៃសេចក្ដីជំនឿទីប្រាំបួនរបស់យើងបានប្រកាសថា

« យើងខ្ញុំជឿចំពោះការណ៍ទាំងអស់ ដែលទ្រង់បានបើកសម្ដែងមក »ជារឿយៗ នោះគឺជាផ្នែកដែលងាយស្រួល ។ វាតម្រូវឲ្យមានជំនឿពិសេសមួយដើម្បី « ជឿថា ទ្រង់នឹងនៅបន្តបើកសម្ដែងនូវរឿងដ៏ធំ និងសំខាន់ៗជាច្រើន ដែលទាក់ទងទៅនឹងនគរនៃព្រះ » ហើយបន្ទាប់មកដើម្បីត្រៀមខ្លួនរួចជាស្រេចទទួលអ្វីៗទាំងនោះមិនថាវាជាអ្វីនោះឡើយ ។ ប្រសិនបើយើងមានឆន្ទៈ នោះព្រះនឹងដឹកនាំយើងទៅកាន់កន្លែងដែលយើងពុំធ្លាប់ស្រមៃដល់ថា យើងអាចទៅដល់ទោះជាយ៉ាងណាក៏ដោយ ការរំពឹងទុករបស់យើងអំពីអ្វីដែលអាចធ្វើបានគឺវានៅខ្ពស់ណាស់ ។ គំនិត និងផ្លូវរបស់ទ្រង់ប្រាកដជាខ្ពស់ជាងយើងខ្លាំងណាស់ ( សូមមើល អេសាយ ៥៥:៨–៩ ) ។ នៅក្នុងរបៀបមួយ ខ្ញុំគិតថា យើងដូចជាអ្នកនៅក្នុងទីក្រុងខឺតឡង់ ដែលព្យាការី យ៉ូសែប ស្ម៊ីធ បានថ្លែងថា « អ្នកពុំបានដឹងអ្វីទៀតអំពីជោគវាសនានៃសាសនាចក្រនេះ និងនគរច្រើនជាងទារកដែលនៅលើភ្លៅម្ដាយនោះទេ » ។[១]

### ទ្រង់មានព្រះទ័យផ្លាស់ប្ដូរដួងចិត្តរបស់យើង

ជាមួយនឹងអ្វីដែលបានថ្លែងនោះ ពេលយើងក្រឡេកមើលអ្វីដែលយើងធ្លាប់ធ្វើ ខ្ញុំសង្ឃឹមថា យើងអាចឃើញលើសពីការគ្រាន់តែកែតម្រូវគោលនយោបាយ កម្មវិធីថ្មី និងការធ្វើកំណែសៀវភៅសិក្សាទៅទៀត ។ កិច្ចការរបស់ព្រះអម្ចាស់គឺទាក់ទងនឹងមនុស្សជានិច្ច ពុំមែនទាក់ទងនឹងកម្មវិធីទេ ។ ទោះបីមានការផ្លាស់ប្ដូរអ្វីដែលទ្រង់ដឹកនាំនៅក្នុងអង្គការ ឬកាលវិភាគ ឬកម្មវិធីសិក្សាមួយក្ដី នោះអ្វីដែលទ្រង់ពិតជារំពឹងចង់បាននោះគឺដើម្បីផ្លាស់ប្ដូរអ្នក និងខ្ញុំ ។ ទ្រង់មានព្រះទ័យផ្លាស់ប្ដូរដួងចិត្តរបស់យើង ហើយពង្រីកអនាគតរបស់យើង ។

មែនហើយ យើងពុំទាន់មើលឃើញរឿងដ៏អស្ចារ្យ និងសំខាន់នោះ ដែលនឹងត្រូវបើកសម្ដែងនៅពេលខាងមុខនោះនៅឡើយ ។ ប៉ុន្តែយើងមានយោបល់មួយចំនួនអំពីទិសដៅចុងបំផុតនោះ ៖

*ការបង្រៀន ការរៀនសូត្រ និងការរស់នៅតាមដំណឹងល្អ គឺជាគោលការណ៍សំខាន់មួយនៃការរីកចម្រើនឆ្ពោះទៅកាន់សក្ដានុពលនៃភាពជាព្រះរបស់ពួកយើង និងការក្លាយដូចជាព្រះមាតាបិតាសួគ៌របស់យើង ។*

« មិនទាន់សម្ដែងមកនៅឡើយ ប៉ុន្តែយើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹងបានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង » ( យ៉ូហានទី ១ ៣:២ ) ។

« តើអ្នករាល់គ្នាគួរធ្វើជាមនុស្ស [ និងស្ត្រី ] បែបណាទៅ ? យើងប្រាប់អ្នករាល់គ្នាជាប្រាកដថា ត្រូវឲ្យបានដូចជាយើង » ( នីហ្វៃទី ៣ ២៧:២៧ ) ។

« អ្នកនឹងបានទទួលនូវភាពពោរពេញរបស់ទ្រង់ ហើយបានតម្កើងក្នុងយើង ដូចជាយើងនៅក្នុងព្រះវរបិតាដែរ ហេតុដូច្នេះហើយ យើងប្រាប់អ្នកថា អ្នកនឹងបានទទួលព្រះគុណថែមលើព្រះគុណ » ( គ. និង ស. ៩៣:២០ ) ។

ខ្ញុំពុំដឹងអំពីអ្នកទេ ប៉ុន្តែសម្រាប់ខ្ញុំវិញ រឿងនោះវាហាក់ដូចជាដំណើរមួយយ៉ាងឆ្ងាយប៉ុន្តែជាដំណើរដែលសប្បាយរីករាយមួយ ! គោលដៅនៃភាពជាព្រះបែបនេះ ទោះបីវាជាគោលដៅដ៏ខ្ពស់ក្ដី វាពិតជាអ្វីដែលធ្វើឲ្យដំណឹងល្អដែលបានស្ដារឡើងវិញមានភាពទាក់ទាញ និងបំផុសគំនិត ។ នៅក្នុងជម្រៅនៃព្រលឹងរបស់យើងគឺជាអារម្មណ៍មួយជាអនុស្សាវរីយ៍មួយដែលប្រាប់យើងថា នេះគឺជាមូលហេតុដែលយើងមកកាន់ផែនដីនេះ ។ យើងបានទទួលយកផែនការរបស់ព្រះវរបិតាដែលគង់នៅឋានសួគ៌ដ៏សំខាន់បំផុត ដោយសារយើងចង់ក្លាយដូចជាទ្រង់ ។ យើងបានដឹងថា វាគឺជាគោលដៅមួយដ៏សែនពិបាក ដែលនឹងពុំងាយស្រួលសម្រេច



បានឡើយ ។ ប៉ុន្តែយើងពុំគ្រាន់តែអាចពេញចិត្តនឹងអ្វីដែលមានតិចតួចជាងនេះឡើយ ។ ព្រលឹងរបស់យើងត្រូវបានបង្កើតឲ្យរីកចម្រើន ហើយយើងត្រូវបានបំផុសគំនិត តាំងពីមុនរហូតដល់ពេលនេះ ដើម្បីធ្វើដំណើរ ។

**ការរៀនសូត្រ និងការប្រែក្លាយ**

ការបង្រៀន ការរៀនសូត្រ និងការរស់នៅតាមដំណឹងល្អ គឺជាគោលការណ៍សំខាន់មួយនៃការរីកចម្រើនឆ្ពោះទៅកាន់សក្តានុពលនៃភាពជាព្រះរបស់ពួកយើង និងការក្លាយដូចជាព្រះមាតាបិតាសួគ៌របស់យើង ។ ជួនកាល យើងហៅដំណើរការនេះថា *ការរីកចម្រើនដ៏អស់កល្បជានិច្ច* ។ ជួនកាលយើងហៅវាថា *ការប្រែចិត្តជឿ* ។ ជួនកាលយើងហៅវាយ៉ាងសាមញ្ញថា *ការប្រែចិត្ត* ។ ប៉ុន្តែទោះបីយើងហៅវាបែបណាក្តី វារួមបញ្ចូលនូវការរៀនសូត្រ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានថ្លែងថា « អ្នកត្រូវតែរៀនអំពីរបៀបក្លាយជាព្រះដោយខ្លួនឯង ហើយក្លាយជាស្ដេច និងពួកសង្ឃចំពោះព្រះ . . . ដោយចាប់ផ្តើមពីកម្រិតតូចមួយទៅកាន់កម្រិតមួយទៀត និងពីសមត្ថភាពតូចមួយទៅកាន់សមត្ថភាពកាន់តែអស្ចារ្យឡើង ។ . . .

« នៅពេលអ្នកឡើងជណ្ដើរ អ្នកត្រូវតែចាប់ផ្តើមពីកាំក្រោមគេមុន ហើយឡើងមួយកាំម្ដងៗ រហូតដល់អ្នកមកដល់កំពូល គឺដូចគ្នានឹងគោលការណ៍នានានៃដំណឹងល្អអ្នកត្រូវចាប់ផ្តើមពីចំណុចដំបូង ហើយបន្តទៅរហូតទាល់តែអ្នករៀននូវគ្រប់គោលការណ៍នៃការលើកតម្កើង » ។[២]

ដូច្នេះ ចូរនិយាយអំពីការរៀនសូត្រ ។ ក្នុងនាមជាគ្រូបង្រៀនដែលចូលចិត្តបង្រៀន ខ្ញុំស្រឡាញ់ពាក្យ និងគំនិត ទោះបីខ្ញុំគិតថា យើងគួរតែផ្តល់និយមន័យវាឲ្យបានប្រសើរបន្តិច ជាងដែលយើងធ្លាប់ផ្តល់ឲ្យវានោះ ។ សម្រាប់គោលបំណងនៃដំណឹងល្អ ខ្ញុំពុំគ្រាន់តែចង់និយាយអំពីការប្រមូលផ្តុំនៃចំណេះដឹងនោះទេ តែទោះជាយ៉ាងណាក៏ដោយ នោះគឺជាផ្នែកមួយនៃការរៀនសូត្រ ។ ខ្ញុំក៏ពុំចង់តែនិយាយថា ត្រូវស្ដាប់ដោយអកម្មដល់មេរៀនមួយ ឬទន្ទេញចាំនូវរឿងពិតនោះឡើយ ។ ខ្ញុំចង់និយាយថា ការរៀនសូត្រនៅក្នុងស្មារតីមួយនៃការរីកចម្រើន និងផ្លាស់ប្ដូរ អំពីការយល់ដឹងដែលដឹកនាំទៅរកការរីកចម្រើនអំពីការដឹងនូវសេចក្តីពិត ដែលជាលទ្ធផលដឹកនាំយើងឲ្យខិតកាន់តែជិតព្រះនៃសេចក្តីពិតគ្រប់យ៉ាង ។

ប្រធាន រ័សុល អិម ណិលសុន បានផ្សារភ្ជាប់ការរៀនសូត្រ និងការផ្លាស់ប្តូរនៃដួងចិត្តដែលប្រែចិត្តជឿនេះ នៅពេលលោកបានបង្រៀនថា នៅពេល « ព្រះវិញ្ញាណបរិសុទ្ធប្រទានការជឿស៊ប់ដល់អ្នកដែលស្វះស្វែងរកសេចក្តីពិតដ៏ស្មោះត្រង់ » នោះវាចិញ្ចឹមបីបាច់ដល់សេចក្តីជំនឿ ដែល « ជំរុញឲ្យមានការប្រែចិត្ត និងគោរពប្រតិបត្តិតាមបទបញ្ញត្តិរបស់ព្រះ » ។ គ្រឿងផ្សំចាំបាច់នៃការប្រែចិត្តជឿទាំងនេះបង្វែរពួកយើង« *ពី* របៀបនៃលោកិយ *ទៅជា* . . . របៀបនៃព្រះអម្ចាស់ » ដែល « នាំឲ្យមានការផ្លាស់ប្តូរយ៉ាងធំដល់ដួងចិត្ត » ។[៣]

នេះពុំមែនជាការស្គាល់ឈ្មោះពូជអំបូរអ៊ីស្រាអែលទាំងដប់ពីរ ឬដ្យាក្រាមនៃការប្រដូចនៃដើមអូលីវនោះឡើយ ទោះបីការធ្វើបែបនោះវាមានប្រយោជន៍ក្តី ។ ការរៀនសូត្រប្រភេទនេះគឺអំពីការផ្លាស់ប្តូរខ្លួនយើង អំពីការផ្លាស់ប្តូរ ( ឲ្យបានប្រសើរឡើង ) ដោយសារយើងដឹងកាន់តែច្រើនអំពីអ្វីដែលព្រះទតដឹង ។

អ្នកអាចឃើញថា ការរៀនសូត្របែបនេះ គឺខ្ញុំនិយាយអំពីការរៀនសូត្រដែលលើសពីការរៀននៅក្នុងថ្នាក់រៀន ឬត្រូវសរុបមកតែក្នុងមេរៀនរយៈពេល ៤៥ នាទីទៅទៀត ។ ព្រះគម្ពីរ, ព្យាការី, ឪពុកម្ដាយ, រដូវប្រាំង, រដូវវស្សា, ការបំផុសគំនិតខាងវិញ្ញាណ និងកម្មវិធីប្រចាំថ្ងៃនានានៃជីវិត ដែលផ្ដល់ឱកាសដល់យើងឲ្យរៀនអំពីព្រះ និងផែនការរបស់ទ្រង់ ដ្បិតប្រាកដណាស់ « គ្រប់ការណ៍ទាំងអស់ធ្វើទីបន្ទាល់ » អំពីទ្រង់ ( ម៉ូសេ ៦:៦៣ ) ។ ទីបំផុតយើងទាំងអស់គ្នាឃើញថា ទ្រង់មានព្រះទ័យបង្រៀនយើង ពុំគ្រាន់តែនៅព្រះវិហារប៉ុណ្ណោះទេ ថែមទាំងនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលាទាំងអស់នៅក្នុងគ្រាក្រៅផ្លូវការជាមួយកូនៗ និងមិត្តភក្ដិរបស់យើង អ្នកជិតខាង ឬអ្នកធ្វើការ

*គេហដ្ឋានគឺជាថ្នាក់រៀន និងកន្លែងពិសោធន៍ ជាកន្លែងដែលការរៀនសូត្រ និងការរស់នៅតាមដំណឹងល្អ គឺត្រូវបានរួមចូលគ្នាយ៉ាងត្រឹមត្រូវឥតខ្ចោះ ដែលវាស្ទើរតែពុំអាចបំបែកគ្នាបាន ។*



ជាមួយយើង បុរស ឬស្ត្រីដែលយើងជួបនៅតាមឡានក្រុង ឬបុគ្គលិកដែលជួយយើងនៅឯផ្សារគឺគ្រប់ទីកន្លែង និងគ្រប់ពេលដែលយើងមានឆន្ទៈរៀន ។

ប៉ុន្តែគ្រប់សេចក្ដីពិតទាំងនេះដែលព្រះកំពុងព្យាយាមបង្រៀនយើងរៀងរាល់ថ្ងៃ គឺគ្រាន់តែជាគ្រាប់ពូជជាច្រើនដែលបានព្រោះនៅលើថ្ម ឬនៅក្នុងបន្លាដែលត្រូវឆេះ ឬងាប់ លុះត្រាណាយើងយកដំបូន្មានរបស់អាលម៉ា ដើម្បីចិញ្ចឹមបីបាច់វាដោយការដកពិសោធន៍នៅព្រះបន្ទូល ឬដូចជាយ៉ាកុបនិយាយថា ធ្វើជាអ្នកប្រព្រឹត្តតាមព្រះបន្ទូល ពុំគ្រាន់តែជាអ្នកស្ដាប់ប៉ុណ្ណោះឡើយ ( សូមមើល ម៉ាកុស ៤:១–២០; យ៉ាកុប ១:២២; អាលម៉ា ៣២:២៧–៤៣ ) ។ នៅពេលយើងរៀនសេចក្ដីពិត ហើយជ្រើសរើសអនុវត្តតាមសេចក្ដីពិត នោះទីបន្ទាល់របស់យើងរីកចម្រើន ( សូមមើល យ៉ូហាន ៧:១៧ ) ។ បន្ទាប់មក នៅពេលយើងធ្វើឲ្យសេចក្ដីពិតនោះក្លាយជាផ្នែកមួយនៃជីវិតយើង តាមរយៈការព្យាយាមយ៉ាងខ្ជាប់ខ្ជួន ដើម្បីរស់នៅតាមវា ទោះបីជួបនូវឧបសគ្គក្ដី វាផ្លាស់ប្ដូរយើង ហើយយើងក្លាយកាន់តែដូចជាព្រះវរបិតានៃសេចក្ដីពិត ។[៤]

**ការរៀនសូត្រដំណឹងល្អគឺត្រូវបានផ្ដោតយកចិត្តទុកដាក់នៅក្នុងគេហដ្ឋាន**

នេះគឺជាមូលហេតុដែលយើងនិយាយថា ការបង្រៀន ការរៀនសូត្រ និងការរស់នៅតាមដំណឹងល្អត្រូវតែ « ផ្ដោតចិត្តទុកដាក់នៅក្នុងគេហដ្ឋាន និងត្រូវបានគាំទ្រដោយសាសនាចក្រ » ។[៥] ទីមួយ គេហដ្ឋានគឺជាកន្លែងដែលយើងចំណាយពេលស្ទើរតែទាំងអស់របស់យើង ប្រាកដណាស់ យើងចំណាយពេលនៅផ្ទះច្រើនជាងនៅព្រះវិហារ ( ទោះបីជាប៊ីស្សពមានការងារច្រើនយ៉ាងណាក៏ដោយ ) ។ យើងពុំរំពឹងថា រូបកាយខាងសាច់ឈាមរបស់យើងនឹងរស់នៅបានយូរដោយការបរិភោគអាហារម្ដងក្នុងមួយសប្ដាហ៍ឡើយ ទោះបីអាហារម្ដងនោះជាអាហារល្អក្ដី ។ ស្រដៀងនេះផងដែរ ប្រសិនបើថ្នាក់រៀននៅព្រះវិហារតែមួយម៉ោង ទោះបីថ្នាក់នោះល្អឥតខ្ចោះយ៉ាងណាក្ដី គឺជារឿងសំខាន់សម្រាប់ « ការទទួលទានព្រះបន្ទូលនៃព្រះគ្រីស្ទ » របស់យើង ( នីហ្វៃទី ២ ៣១:២០ ) នោះយើងកំពុងស្ថិតនៅក្នុងគ្រោះថ្នាក់នៃការខ្វះរបបអាហារខាងវិញ្ញាណហើយ ។

ទីពីរ គេហដ្ឋានគឺជាថ្នាក់រៀន និងកន្លែងពិសោធន៍ ជាកន្លែងដែលការរៀនសូត្រ និងការរស់នៅតាមដំណឹងល្អ គឺត្រូវបានរួមចូលគ្នាយ៉ាងត្រឹមត្រូវឥតខ្ចោះ ដែលវាស្ទើរតែពុំអាចបំបែកគ្នាបាន ។ នេះគឺជាមន្ទីរពិសោធន៍នៃបទពិសោធន៍រស់នៅយ៉ាងសាមញ្ញ ដែលពុំអាចត្រូវបានបង្កើតឡើងនៅក្នុងថ្នាក់រៀនតែឯងបានឡើយ ។

ប្រហែលអ្វីដែលសំខាន់បំផុត គេហដ្ឋានគឺជា ឬអាចក្លាយដូចជាស្ថានសួគ៌ ជាការរំឭកនៃគោលដៅអស់កល្បជានិច្ច ដែលយើងបានមកលើផែនដីនេះដើម្បីឈោងចាប់យកវា ។ ដូចប្រធាន

ហានីរី ប៊ី អាររិង ទីប្រឹក្សាទីពីរក្នុងគណៈប្រធានទីមួយបានថ្លែងដូច្នេះថា ៖ « ទោះជាគ្រួសារលើផែនដីមិនល្អឥតខ្ចោះក្តី ស្ថាប័នទាំងនោះផ្តល់ឱកាសពិសេសឲ្យបុត្រាបុត្រីព្រះ ត្រូវបានស្វាគមន៍មកកាន់ពិភពលោកដោយមានក្តីស្រឡាញ់តែមួយគត់លើផែនដីដែលកាន់តែដូចអារម្មណ៍ដែលយើងបានមាននៅស្ថានសួគ៌ ជាក្តីស្រឡាញ់របស់មាតាបិតា ។ គ្រួសារក៏ជាមធ្យោបាយមួយប្រសើរបំផុតដើម្បីរក្សា ហើយបន្តគុណធម៌ខាងសីលធម៌ និងគោលការណ៍ពិតនានា ដែលនឹងដឹកនាំយើងត្រឡប់ទៅឯវត្តមានព្រះវិញ » ។[៦]

ឱឪពុកម្តាយអើយ តើខ្ញុំបំភ័យអ្នកឬ ? ខ្ញុំសង្ឃឹមថាអត់ទេ ។ ការគូសបញ្ជាក់ស្តីពីការបង្រៀន ការរៀនសូត្រ និងការរស់នៅតាមដំណឹងល្អនៅគេហដ្ឋាននេះពុំមែនមានន័យថា ជាការបន្ថែមបន្ទុកមួយដល់បុគ្គលម្នាក់ៗ ឬគ្រួសារនោះទេ ។ ផ្ទុយទៅវិញ ប្រាកដណាស់ យើងសង្ឃឹមថា តាមរយៈចំណេះដឹង និងការគាំទ្រនៃកិច្ចខិតខំរបស់អ្នកនៅគេហដ្ឋាន នោះយើងអាចបន្ថយបន្ទុកដែលអ្នកកំពុងមានតាមរបៀបមួយចំនួន ។ ឬ កាន់តែប្រសើរនោះប្រហែលជាយើងអាចពង្រឹងអ្នកដើម្បី « ទ្រ [បន្ទុក ] បានដោយងាយ » ( ម៉ូសាយ ២៤:១៥ ) ។

### ការគាំទ្រដល់ការរៀនសូត្រដំណឹងល្អនៅព្រះវិហារ

ការពង្រីកទស្សនវិស័យនៃការក្រេបជញ្ជក់យកដំណឹងល្អនៅក្រៅថ្នាក់រៀននេះ ពុំមែនមានន័យថា ថ្នាក់រៀនមិនសំខាន់នោះទេ ។ ប្រាកដណាស់ យើងសង្ឃឹមថា ការរៀនសូត្រកាន់តែមានអត្ថន័យនោះនៅតែកើតមាននៅព្រះវិហារ ។ ប្រាកដណាស់ ការគាំទ្រដល់តួនាទីនៃថ្នាក់រៀននៅព្រះវិហារគឺសំខាន់ចំពោះការរៀនសូត្រដែលផ្តោតទៅគេហដ្ឋាន ។ ប៉ុន្តែដើម្បីជួយផ្លាស់ប្តូរជីវិត នោះការបង្រៀននៅព្រះវិហារពុំអាចឯករាជ្យអំពីអ្វីដែលកំពុងកើតឡើងនៅក្នុងជីវិតមនុស្សទាំងនោះឡើយ ។ វាត្រូវតែទាក់ទង និងចេញមកពីបទពិសោធន៍ទាំងគ្រូបង្រៀន និងសិស្ស ។

ប្រាកដណាស់ ការផ្តោតទៅលើសៀវភៅសិក្សា ឬក្តារខៀន ឬការរៀបចំកៅអី ឬសូម្បីតែសំណួរពិភាក្សាដ៏ល្អឥតខ្ចោះមួយចំនួនអាចពុំមែនជាការផ្តោតចិត្តទុកដាក់ត្រឹមត្រូវឡើយ ។ បុត្រគ្រប់រូបរបស់ព្រះ និងការរីកចម្រើនអស់កល្បរបស់ពួកគេត្រូវតែជាកម្មវត្ថុនៃកិច្ចខិតខំ និងសេចក្តីស្រឡាញ់របស់យើង ។ យើងកំពុងព្យាយាមធ្វើឲ្យមនុស្សរំជួលចិត្ត ហើយយើងគ្រាន់តែប្រើប្រាស់កៅអី ឬដី-ស ឬឧបករណ៍សោតទស្សន៍ ប្រសិនបើវាជួយយើងធ្វើឲ្យមនុស្សរំជួលចិត្ត ។ ដើម្បីបកស្រាយឃ្លារបស់ព្រះអង្គសង្គ្រោះហើយធ្វើឲ្យងាយ

### ការរៀនសូត្រ និងការរស់នៅតាមដំណឹងល្អនៅក្នុងគេហដ្ឋាន

ការស្រាវជ្រាវទាំងអ្នកស្រាវជ្រាវពួក អិល. ឌី. អេស និងមិនមែន អិល. ឌី. អេស. បានរកឃើញថា ការប្រតិបត្តិសាសនាដែលផ្តោតទៅលើគេហដ្ឋានមានអនុភាព និងឥទ្ធិពលយូរអង្វែងលើកូនៗ ។ នៅពេលកូនៗចម្រើនវ័យធំឡើងជារឿយៗពួកគេរក្សាជំនឿសាសនា និងលំនាំដែលបានបង្កើតឡើងនៅក្នុងគេហដ្ឋានកាលពីពួកគេនៅយុវវ័យ ។

ឪពុកម្តាយដែលបង្កើតគ្រួសាររបស់ពួកគេនៅលើគោលការណ៍នៃសេចក្តីសុចរិតដូចដែលមាននៅក្នុង « ក្រុមគ្រួសារ ៖ ការប្រកាសដល់ពិភពលោក » ផ្តល់គុណសម្បត្តិដល់កូនៗរបស់ពួកគេច្រើនឡើងៗ នាំមកនូវពរជ័យទាំងខាងវិញ្ញាណ និងខាងសាច់ឈាមដល់ពួកគេ ។

ការស្រាវជ្រាវក្នុងសាសនាចក្រនៅក្នុងសហរដ្ឋអាមេរិកក៏បានរកឃើញផងដែរថា កុមារ និងយុវវ័យនៅក្នុងក្រុមគ្រួសារ អិល. ឌី. អេស. ដែលមានការអធិស្ឋានជាគ្រួសារ សិក្សាព្រះគម្ពីរជាគ្រួសារប្រចាំថ្ងៃ យ៉ាងហោចណាស់បួនប្រាំដងក្នុងមួយសប្តាហ៍ និងធ្វើរាត្រីជួបជុំក្រុមគ្រួសាររៀងរាល់សប្តាហ៍ ទំនងជាចូលរួមសាសនាចក្ររៀងរាល់សប្តាហ៍ ទទួលអំណោយទានពិសិដ្ឋ ឬរៀបការនៅក្នុងព្រះវិហារបរិសុទ្ធ នៅពេលពួកគេពេញវ័យ ២០ ភាគរយច្រើនជាងអ្នកផ្សេងទៀត ។

ប្រាកដណាស់ កុមារមានសិទ្ធិរបស់ពួកគេ ដូច្នេះការគោរពប្រតិបត្តិសាសនាដ៏ស្មោះត្រង់របស់ឪពុកម្តាយនៅក្នុងគេហដ្ឋាន ដូចជាការអធិស្ឋាន និងការសិក្សាព្រះគម្ពីរជាគ្រួសារជាទៀងទាត់ ពុំទទួលបានលទ្ធផលថាកូនៗទទួលគុណតម្លៃពីឪពុកម្តាយជានិច្ចនោះទេ ។ ជំនឿ និងការគោរពប្រតិបត្តិចំពោះសាសនាដែលបន្តពីមួយជំនាន់ទៅមួយជំនាន់បានកើនឡើងនៅពេលឪពុកម្តាយធ្វើជាគំរូល្អ មានទំនាក់ទំនងជិតស្និទ្ធ និងស្រឡាញ់កូនៗរបស់ខ្លួន ហើយបើកចំហរការសន្ទនាអំពីប្រធានបទស្តីពីសាសនា ។ គ្រួសាររបស់បុគ្គលម្នាក់ទោរទន់ទៅរកឥទ្ធិពលដ៏មានអនុភាពបែបនេះលើការគោរពប្រតិបត្តិសាសនារៀងៗខ្លួន ដែលធ្វើឲ្យ « អ្នកវង្វេងក្រោល » មួយចំនួនតូចត្រឡប់មកសកម្មក្នុងសាសនាចក្រវិញអំឡុងពេលនៃជីវិតរមែងស្លាប់នេះ ។

ខណៈដែលការជំពាក់ទាក់ទងនៃការស្រាវជ្រាវនេះផ្តល់ឥទ្ធិពលវិជ្ជមាននៅកន្លែងណាដែលមានការរៀនសូត្រដំណឹងល្អដែលផ្តោតនៅក្នុងគេហដ្ឋាន នោះវាក៏ផ្តល់ថា ការគាំទ្រពីសាសនាចក្រគឺសំខាន់ណាស់សម្រាប់អ្នកប្រែចិត្តជឿថ្មី ឬសមាជិកផ្សេងទៀតដែលរស់នៅក្នុងគេហដ្ឋានដែលមានការគោរពប្រតិបត្តិដំណឹងល្អទន់ខ្សោយ ។ សមាជិកទាំងនេះអាចទទួលប្រយោជន៍ពីគំរូ និងការផ្តល់ប្រឹក្សា ដូចជាមានរាត្រីជួបជុំក្រុមគ្រួសារជាមួយគ្រួសារផ្សេងទៀត ការរៀនអំពីរបៀបអធិស្ឋានជាគ្រួសារដោយខ្លាប់ខ្លួន ការសង្កេតមើលរបៀបវិជ្ជមាននានា ដើម្បីនិយាយអំពីសាសនានៅគេហដ្ឋាន និងការផ្តល់ការងារបម្រើអមជាមួយនឹងសមាជិកដែលមានបទពិសោធន៍ច្រើន ។

យល់ តើវាមានប្រយោជន៍អ្វីដល់គ្រូបង្រៀន ឬថ្នាក់មួយ ប្រសិនបើវាគាំទ្រដល់បទបង្ហាញគោលលទ្ធិដ៏ធំបំផុតនៃលោកិយ ហើយគ្មានគោលលទ្ធិណាមួយក្លាយជាភស្តុតាងជាក់ស្តែងនៅក្នុងជីវិត និងសេចក្តីស្រឡាញ់ គំនិត និងអារម្មណ៍របស់សមាជិកម្នាក់ៗ ជាបុគ្គលដែលព្រះចង់សង្គ្រោះ និងលើកតម្កើងនោះ ?

ការវាស់វែងពិតប្រាកដនៃភាពជោគជ័យនឹងពុំមែនជារបៀបដែលមេរៀនត្រូវបានបង្រៀនយ៉ាងរលូន ពុំមែនជារបៀបដ៏ល្អដែលយើងបង្គ្រប់ម៉ោង ពុំមែនជាការសរសើរដ៏ច្រើនដែលគ្រូបង្រៀនទទួលបានបន្ទាប់ពីបង្រៀន ឬពុំមែនមកពីមានសមាជិកថ្នាក់ចូលរួមច្រើននោះទេ ។ ភាពជោគជ័យផ្តែកទៅលើអ្វីដែលកើតឡើងនៅក្នុងជីវិតរបស់សិស្ស ។ តើបងប្រុសហើរ៉ូ បានរកឃើញអ្វីនៅក្នុងខគម្ពីរកាលសប្តាហ៍មុន ដែលជួយគាត់ឲ្យយកឈ្នះលើឧបសគ្គដែលគាត់កំពុងជួបប្រទះនោះ ? លើសពីនោះទៅទៀត តើមានអ្វីកើតឡើងនៅក្នុងថ្នាក់ ដែលបានពង្រីកសមត្ថភាពគាត់ឲ្យរកឃើញចម្លើយដែលគាត់ត្រូវការនៅអំឡុងសប្តាហ៍នោះ ? នៅក្នុងសប្តាហ៍នេះ កាលគាត់បានចែកចាយបទពិសោធន៍នោះ តើបងស្រីស្មីតរកឃើញសេចក្តីសង្ឃឹម និងសេចក្តីជំនឿដែលគាត់ត្រូវការ ដើម្បីជឿថា ព្រះនឹងជួយគាត់ដែរឬទេ ? ( សូមមើល « អ្នកពុំអាចមានសុខភាពល្អ ដោយគ្រាន់តែមើលអ្នកដទៃនោះទេ » ) ។

អ្វីៗទាំងអស់នេះអាចមានន័យថា ប្រសិនបើអ្នកគឺជាគ្រូបង្រៀន នោះអ្វីដែលអ្នកឃើញនៅក្នុងធនធានបង្រៀនថ្មីរបស់យើង នឹងក្លាយជាអ្វីដែលខុសប្លែកពីអ្វីដែលអ្នកធ្លាប់ឃើញនៅក្នុងសៀវភៅសិក្សាចាស់របស់យើង ។ អ្នកអាចរកឃើញសេចក្តីណែនាំជាក់លាក់តិចតួចអំពីអ្វីដែលត្រូវធ្វើ និងរបៀបដើម្បីធ្វើវា ។ នោះគឺជាអ្វីដែលវាត្រូវបានរៀបចំឡើង ដើម្បីជំរុញអ្នកឲ្យអធិស្ឋានទូលសូម ស្វែងរកមើល និងទាញយកបទពិសោធន៍ និងការបំផុសគំនិតផ្ទាល់របស់អ្នក ព្រមទាំងពីបុគ្គលដែលអ្នកបង្រៀន ។ ( សូមមើល « តើអ្នកកំពុងច្រៀងតែម្នាក់ឯង ឬដឹកនាំក្រុមចម្រៀង ? » )

ដូច្នេះឧបមាថា វគ្គសិក្សាគឺស្តីពីព្រះគម្ពីរសញ្ញាថ្មី ហើយខ្ញុំគឺជាគ្រូបង្រៀនសាលាថ្ងៃអាទិត្យ នោះខ្ញុំពុំចាំបាច់មកថ្នាក់រៀនដោយនាំមករឿងជាច្រើនអំពីមេរៀននៃ ម៉ាថាយ ៥ ការដកស្រង់ដ៏បំផុសគំនិតមកពីមនុស្សដ៏ឈ្លាសវៃទាក់ទងនឹងទេសនាកាថានៅលើភ្នំ និងសកម្មភាពដ៏ច្នៃប្រឌិតនានា អំពីរបៀបដើម្បីធ្វើជាអ្នកផ្សះផ្សារ អ្វីៗ ទាំងអស់ត្រូវបានរៀបចំ និងកំណត់ពេលបង្រៀនយើងរហូតដល់ប្រាំនាទីដល់ម៉ោងចប់នោះទេ ។ ផ្ទុយទៅវិញ ខ្ញុំសិក្សា និងរស់នៅតាមគោលការណ៍នានានៅក្នុង ម៉ាថាយ ៥ គឺដូចជាអ្វីដែលខ្ញុំរំពឹងថា សិស្សនឹងធ្វើដែរ ។ អ្វីមួយដែលខុសប្លែកនោះគឺថា ខ្ញុំអាចធ្វើវាដោយការគិតគូ និងអធិស្ឋានកាន់តែច្រើនអំពីសមាជិកម្នាក់ៗនៅក្នុងថ្នាក់របស់ខ្ញុំ និងរបៀបដែលគោលការណ៍ទាំងនេះអាចមានអត្ថន័យចំពោះពួកគេ ។ បន្ទាប់មក នៅក្នុងថ្នាក់ ក្រោមឥទ្ធិពលនៃព្រះវិញ្ញាណ នោះខ្ញុំលើកទឹកចិត្តពួកគេឲ្យស្វាង និងគាំទ្រគ្នាទៅវិញទៅមក នៅក្នុងការព្យាយាមរបស់ពួកគេដើម្បីសិក្សា និងរស់នៅតាម ម៉ាថាយ ៥ ។ ខ្ញុំជួយពួកគេឲ្យឃើញអំពីទំនាក់ទំនងរវាងជីវិតរបស់

**អ្នកពុំអាចមានសុខភាពល្អ ដោយគ្រាន់តែមើលអ្នកដទៃនោះទេ**

អែលឌើរ នែល អិល អាន់ឌើរសិន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានប្រៀបធៀបការរៀនសូត្រដំណឹងល្អទៅនឹងដំណើរឆ្ពោះទៅកាន់មជ្ឈមណ្ឌលហាត់ប្រាណ ។ លោកបានថ្លែងថា « សិស្សមិនខ្លាំងជាងមុនដោយការមើលអ្នកផ្សេងទៀតធ្វើលំហាត់ប្រាណនោះទេ ។ ពួកគេរៀន ហើយបន្ទាប់មកចូលរួមជាមួយគ្នា ។ នៅពេលកម្លាំងខាងវិញ្ញាណរបស់ពួកគេកើនឡើង នោះពួកគេទទួលបានទំនុកចិត្ត ហើយអនុវត្តដោយខ្លួនពួកគេនូវអ្វីៗទាំងអស់កាន់តែច្រើនឡើង » ( « A Classroom of Faith, Hope, and Charity » [ ជំនួបជាមួយអ្នកមានសិទ្ធិអំណាចទូទៅ ការចាក់ផ្សាយសម្រាប់គ្រូបង្រៀនប្រព័ន្ធអប់រំសាសនាចក្រ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០១៤ ] broadcasts.lds.org ) ។

**តើអ្នកកំពុងច្រៀងតែម្នាក់ឯង ឬដឹកនាំក្រុមចម្រៀង ?**

ជារឿយៗ ពួកគ្រូបង្រៀនមានអារម្មណ៍ថា ដូចជាអ្នកចម្រៀងឯក ហាក់ដូចជាអ្វីៗគ្រប់យ៉ាងពឹងផ្អែកលើពួកគេ ។ ផ្ទុយទៅវិញ ពួកគេអាចមើលឃើញខ្លួនពួកគេកាន់តែដូចអ្នកដឹកនាំក្រុមចម្រៀងមួយ ។ តួនាទីរបស់គ្រូបង្រៀនគឺពិសេស និងមានការត្រូវការ ពួកគេដឹកនាំការពិភាក្សាបំផុសគំនិតឲ្យរស់នៅតាមដំណឹងល្អ និងចង្អុលបង្ហាញអ្វីៗគ្រប់យ៉ាងឲ្យត្រឡប់ទៅកេគោលលទ្ធិដ៏បរិសុទ្ធ ។ ប៉ុន្តែតន្ត្រីកើតឡើងពីពួកយើងទាំងអស់គ្នា ។ គ្រូបង្រៀនជួយយើងឲ្យរកឃើញសំឡេងនៃដំណឹងល្អ ដែលយើងម្នាក់ៗមាននៅក្នុងចិត្តយើង តាមរយៈការអញ្ជើញ និងបំផុសគំនិតយើងឲ្យមានបទពិសោធន៍ផ្ទាល់ខ្លួននៅក្នុងការសិក្សាព្រះគម្ពីរ ។ បន្ទាប់មក នៅពេលយើងមករៀន យើងចែកចាយការយល់ដឹង និងការរកឃើញផ្ទាល់ខ្លួនរបស់យើង ។ ការណ៍នេះនឹងបន្ថែមទៅលើការបន្ទរក្នុងចម្រៀង ។

ពួកគេ និងគោលលទ្ធិដ៏មានតម្លៃនៅក្នុងព្រះគម្ពីរ ។ លើសពីអ្វីៗទាំងអស់ ខ្ញុំអធិស្ឋានទូលសូមការបំផុសគំនិតនៅក្នុងគ្រានោះ ដើម្បីបង្វែររឿងពិតនោះឲ្យទៅជាសេចក្តីជំនឿ ដើម្បីបង្វែរសំណួរឲ្យទៅជាការស្រាវជ្រាវរកចម្លើយ ។

ប្រាកដណាស់ ជាចម្បងតួនាទីរបស់ខ្ញុំអាចមានភាពខុសប្លែកបន្តិច ។ ប៉ុន្តែគោលបំណងរបស់ខ្ញុំគឺពុំមែនទុកឲ្យក្មេងៗ កម្សាន្តរយៈពេល ៤៥ នាទី ឬទុកឲ្យវានៅស្ងៀម ដើម្បីខ្ញុំអាចនិយាយអ្វីដែលខ្ញុំចង់និយាយដោយគ្មានការរំខាននោះឡើយ ។ គោលបំណងរបស់ខ្ញុំគឺដើម្បីស្ថាបនាពួកគេក្លាយជាអ្នករៀនឯករាជ្យ ដើម្បីជួយពួកគេឲ្យឃើញអំពីរបៀបដែលជីវិតពួកគេត្រូវបានពង្រីកតាមរយៈសេចក្តីពិតនៃដំណឹងល្អ និងដើម្បីគាំទ្រឪពុកម្តាយរបស់ពួកគេ ដែលជាគ្រូបង្រៀនដំណឹងល្អដ៏សំខាន់បំផុតរបស់ពួកគេ ។

ឥឡូវនេះ ដោយធ្វើឲ្យឪពុកម្តាយមានការភ័យ នោះប្រហែលជាខ្ញុំបានបំភ័យគ្រូបង្រៀនផងដែរ ។ បើអញ្ចឹងមែននោះ ខ្ញុំសូមបញ្ជាក់អ្នកជាមួយនឹងគំនិតពីរ ៖ ( ១ ) អ្នកកំពុងបង្រៀនមនុស្ស មិនមែនបង្រៀនមេរៀន

*ភាពជោគជ័យផ្អែកទៅលើអ្វីដែលកើតឡើងនៅក្នុងជីវិតរបស់សិស្ស ។*



ទេ ហើយអ្នកស្គាល់មនុស្សច្បាស់ជាងមេរៀនក្នុងសៀវភៅសិក្សានោះទៅទៀត ។ ( ២ ) កិច្ចខិតខំផ្ទាល់ខ្លួនរបស់អ្នកដើម្បីរៀនសូត្រ និងរស់នៅតាមដំណឹងល្អគឺជាការរៀបចំដ៏ល្អបំផុត ដើម្បីបង្រៀនដំណឹងល្អដល់អ្នកដទៃ ។ សូមចាំថា របៀបដ៏ល្អបំផុតដើម្បីអញ្ជើញព្រះវិញ្ញាណមកក្នុងជីវិតយើង និងទៅក្នុងការបង្រៀនរបស់យើង គឺការរៀនសូត្រ និងរស់នៅតាមដំណឹងល្អដោយខ្លួនយើងផ្ទាល់ ។ ព្រះវិញ្ញាណគឺជាគ្រូបង្រៀនសំខាន់បំផុតនៅក្នុងសាសនាចក្រ ហើយសំណាងល្អណាស់ វាគ្មានដែនកំណត់សម្រាប់ឥទ្ធិពលនោះទេ ។

**ទ្រង់បានគូសដានផ្លូវ និងដឹកនាំផ្លូវ**

វាគឺជាបំណងប្រាថ្នាដ៏ធំធេងរបស់យើង ដែលព្រះអម្ចាស់នឹងលើកស្ទួយយើងឡើង ទៅកាន់ការរីកចម្រើនខាងវិញ្ញាណដ៏ខ្ពស់ថ្មីមួយ តាមរយៈរបៀបថ្មីនៃការរៀនសូត្រ និងការរស់នៅតាមដំណឹងល្អ ។ ជាមួយនឹងជំនួយរបស់ទ្រង់ នោះយើងនឹងចែកចាយដំណឹងល្អជាមួយមិត្តភក្តិរបស់យើង មិនមែនដោយសារយើងមានអារម្មណ៍ថា វាជាកាតព្វកិច្ចនោះទេ ប៉ុន្តែដោយសារដំណឹងល្អគឺជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់យើង ហើយយើងពុំអាចបើកមាត់យើង ដោយគ្មានការចែកចាយសេចក្តីពិតមួយចំនួននៃដំណឹងល្អឡើយ ។ មែនហើយ មិត្តភក្តិរបស់យើងដែលមានជំនឿផ្សេងនឹងឃើញពីពន្លឺដែលបានកើនឡើងនៅក្នុងជីវិតរបស់យើង ហើយនឹងស្វែងរកអ្នកផ្សព្វផ្សាយសាសនា គឺពីមុនពួកអ្នកផ្សព្វផ្សាយសាសនាស្វែងរកពួកគេទៅទៀត ដើម្បីទទួលបាននូវអ្វីមួយចំនួនដែលពួកគេបានឃើញឲ្យទៅក្រុមគ្រួសារពួកគេផ្ទាល់ ។ អាពាហ៍ពិពាហ៍ក្នុងព្រះវិហារបរិសុទ្ធ កិច្ចការពង្សប្រវត្តិ អំណាច និងពិធីបរិសុទ្ធនៃបព្វជិតភាព ភាពស្អាតស្អំខាងសីលធម៌ ការមើលថែដល់ជនក្រីក្រ អ្វីៗទាំងអស់ដែលនឹងក្លាយជាលទ្ធផលដ៏មានពរនៃការប្រែចិត្តជឿយ៉ាងជ្រាលជ្រៅរបស់សិស្សនៃព្រះគ្រីស្ទ ក្នុងការរៀនសូត្រ និងការរស់នៅតាមដំណឹងល្អរៀងរាល់ថ្ងៃ ជាមួយនឹងអំណរគុណដ៏ពោរពេញ ជាមួយនឹងការគាំទ្រឥតឈប់ឈរ

*ខ្ញុំសូមថ្លែងទីបន្ទាល់ថា នៅពេលយើងរៀនពីព្រះទ័យទ្រង់ នៅពេលយើងប្រមូលពន្លឺ និងសេចក្តីពិត ហើយធ្វើវាឲ្យក្លាយជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់យើង ពន្លឺនោះនឹងភ្លឺខ្លាំងឡើងៗនៅក្នុងខ្លួនយើង ។*



ពីថ្នាក់សាលាថ្ងៃអាទិត្យ ។ នោះជាអ្វីដែលព្រះអម្ចាស់កំពុងដឹកនាំយើង ហើយវាពិតជាដំណើរដ៏បំផុសគំនិតមួយ ។

យើងប្រើឃ្លាថា « ការបង្រៀនតាមរបៀបរបស់ព្រះអង្គសង្គ្រោះ » ប៉ុន្តែខ្ញុំសង្ឃឹមថា វានឹងពុំក្លាយជាឃ្លាដែលបាត់បង់អត្ថន័យដើមរបស់វាឡើយ ។ ប្រាកដណាស់ យើងចង់និយាយថា វាគឺជាអ្វីដែលយើងត្រូវការដើម្បីក្លាយដូចជាព្រះគ្រីស្ទ ជាគ្រូបង្រៀន និងជាសិស្ស ដើម្បីព្យាយាមចែកចាយដំណឹងល្អតាមរបៀបដែលទ្រង់បានធ្វើ ។ នេះគឺជាឱកាសដើម្បីចូលរួមនឹងពួកសិស្ស ដើម្បីទៅក្នុងផ្លូវធំ និងផ្លូវកាត់នានាជាមួយព្រះយេស៊ូវរកមើលនរណាម្នាក់ដែលអាចបាត់បង់ ។ នេះគឺជាឱកាសដើម្បីឡើងភ្នំនៃទេសនកថាជាមួយហ្វូងមនុស្ស ហើយអង្គុយនៅក្បែរឆ្នេរនៃស្រុកកាលីឡេជាមួយនឹងហ្វូងមនុស្ស ។ នេះគឺជាឱកាសសម្រាប់យើងទាំងអស់គ្នាដើម្បីប៉ះជាយព្រះពស្ត្ររបស់លោកថៅហ្វាយ ហើយត្រូវបានព្យាបាល ។

ខ្ញុំស្រឡាញ់ពាក្យកំណាព្យទាំងនេះជានិច្ចដែលនិពន្ធដោយ អ៊ីលីស្សា អ័រ ស្នូ សម្រាប់ទំនុកតម្កើងមួយដែលរំជួលចិត្តបំផុតនៅក្នុងសាសនាចក្រ ៖

*ទ្រង់បានគូសដាន ហើយដឹកនាំផ្លូវ*
*ហើយទ្រង់បានបង្ហាញឲ្យ*
*រកពន្លឺជីវិតដ៏អស់កាល*
*ក្នុងទីចំពោះនៃទ្រង់ ។*[៧]

បងប្អូនប្រុសស្រី ខ្ញុំមានកិត្តិយសដើម្បីដើរជាមួយបងប្អូនឆ្ពោះទៅកាន់អនាគតដ៏រុងរឿង ដែលព្រះវរបិតាដែលគង់នៅស្ថានសួគ៌បានរៀបចំសម្រាប់យើង ។ ខ្ញុំស្គាល់ចិត្តរបស់បងប្អូន ។ ខ្ញុំដឹងថា បងប្អូនស្រឡាញ់ព្រះអម្ចាស់ ហើយចង់ធ្វើតាមព្រះទ័យទ្រង់ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា នៅពេលយើងរៀនពីព្រះទ័យទ្រង់ នៅពេលយើងប្រមូលពន្លឺ និងសេចក្ដីពិត ហើយធ្វើវាឲ្យក្លាយជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់យើង ពន្លឺនោះនឹងភ្លឺខ្លាំងឡើងៗនៅក្នុងខ្លួនយើង « ភ្លឺកាន់តែខ្លាំងឡើងៗ រហូតដល់ថ្ងៃបាន *ល្អឥតខ្ចោះ* » ( គ. និង ស. ៥០:២៤ ការគូសបញ្ជាក់ត្រូវបានបន្ថែម ) នៅពេលយើងអាចនៅជាមួយទ្រង់ ដោយសារយើងនឹងក្លាយដូចជាទ្រង់ ។ ■

កំណត់ចំណាំ
១. *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* ( ឆ្នាំ ២០០៧ ) ទំព័រ ១៣៧ ។
២. *ការបង្រៀន ៖ យ៉ូសែប ស្ម៊ីធ* ទំព័រ ២២១, ២៦៨ ។
៣. រ័សុល អិម ណិលសុន « Jesus Christ the Master Healer » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៥ ទំព័រ ៨៦ ។
៤. សូមមើល ដាល្លិន អេក អូក « The Challenge to Become » *Liahona* ខែ មករា ឆ្នាំ ២០០១ ទំព័រ ៤០–៤៣ សូមមើលផងដែរ ដេវីឌ អេ បែដណា « Converted unto the Lord » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ១០៦–១០៩ ។
៥. ក្បួនខ្នាតភាគ ២ ៖ ការគ្រប់គ្រងសាសនាចក្រ ( ឆ្នាំ ២០១០ ) ចំណុច ១.៤ ។
៦. ហិនរី ប៊ី អាវរីង « Gathering the Family of God » *Liahona* ខែ ឧសភា ឆ្នាំ ២០១៧ ទំព័រ ២០ ។
៧. « ឱប្រាជ្ញា និងក្ដីស្នេហ៍ដ៏អស្ចារ្យ » ទំនុកតម្កើង លេខ ១១៧ ។



**ការយល់ដឹងថ្មីនឹងកើតឡើង**

« នៅពេលអ្នកពិចារណា និងអធិស្ឋានអំពីគោលការណ៍នៃគោលលទ្ធិ នោះព្រះវិញ្ញាណបរិសុទ្ធនឹងមានបន្ទូលទៅកាន់គំនិត និងចិត្តរបស់អ្នក ។ ចេញពីព្រឹត្តិការណ៍ដែលបានបង្ហាញនៅក្នុងព្រះគម្ពីរ នោះការយល់ដឹងថ្មីនឹងកើតឡើង ហើយគោលការណ៍ដែលទាក់ទងទៅនឹងស្ថានភាពអ្នកនឹងកើតមានក្នុងចិត្តរបស់អ្នក ។

អ្នកនឹងបណ្ដុះបទពិសោធន៍នៃវិវរណៈបែបនោះ តាមរយៈការរស់នៅស្របតាមពន្លឺដែលអ្នកបានទទួលរួចនោះ និងតាមរយៈការស្រាវជ្រាវបទគម្ពីរដោយការជំរុញចិត្តដ៏បរិសុទ្ធ ដោយស្មោះអស់ពីចិត្តដើម្បី ‹ មកកាន់ព្រះគ្រីស្ទ › ។ នៅពេលអ្នកធ្វើដូច្នោះ នោះទំនុកចិត្តរបស់អ្នកនឹង ‹ ក្លាហានឡើងនៅចំពោះវត្តមាននៃព្រះ › ហើយព្រះវិញ្ញាណបរិសុទ្ធនឹងទៅជាគូកនអ្នក » ។

ប្រធាន រ័សុល អិម ណិលសុន « Living by Scriptural Guidance » *Liahona* ខែ មករា ឆ្នាំ ២០០១ ទំព័រ ២១ ។

**តើខ្ញុំគួរតែប្រើប្រាស់ធនធានថ្មី *ចូរមកតាមខ្ញុំ* នេះដោយរបៀបណា ?**
ធនធានថ្មី *ចូរមកតាមខ្ញុំ* សម្រាប់បុគ្គលម្នាក់ៗ និងក្រុមគ្រួសារ ថ្នាក់សាលាថ្ងៃអាទិត្យ និងថ្នាក់អង្គការបឋមសិក្សា មានបំណងដើម្បីជួយយើងឲ្យទទួលបានបទពិសោធន៍រៀនសូត្រដ៏មានអត្ថន័យមកពីព្រះគម្ពីរនៅគេហដ្ឋាន និងនៅព្រះវិហារ ។ ដូច្នេះតើធនធានថ្មី *ចូរមកតាមខ្ញុំ* ទាំងនេះនឹងធ្វើការរួមគ្នាយ៉ាងដូចម្ដេច ?

- នៅក្នុងឆ្នាំ ២០១៩ អ្នកនឹងត្រូវបានអញ្ជើញឲ្យសិក្សាព្រះគម្ពីរសញ្ញាថ្មី ។ សៀវភៅ *ចូរមកតាមខ្ញុំ សម្រាប់បុគ្គលម្នាក់ៗ និងក្រុមគ្រួសារ* នឹងផ្ដល់គំនិតដើម្បីគាំទ្រដល់ការសិក្សាបទគម្ពីរផ្ទាល់ខ្លួន និងជាគ្រួសារនៅគេហដ្ឋាន ។ សូមប្រើធនធាននេះតាមរបៀបណាដែលជាជំនួយដល់អ្នក ។
- រៀងរាល់សប្ដាហ៍ មនុស្សពេញវ័យ យុវវ័យ និងកុមារទូទាំងសាសនាចក្រនឹងសិក្សា ហើយពិភាក្សាជំពូកដូចគ្នានៃព្រះគម្ពីរសញ្ញាថ្មី ។
- ប្រសិនបើអ្នកជាគ្រូបង្រៀនថ្នាក់សាលាថ្ងៃអាទិត្យ ឬថ្នាក់អង្គការបឋមសិក្សា សូមប្រើសៀវភៅ *ចូរមកតាមខ្ញុំ សម្រាប់បុគ្គលម្នាក់ៗ និងក្រុមគ្រួសារ* ដើម្បីពង្រីកការសិក្សាផ្ទាល់ខ្លួនរបស់អ្នក និងការសិក្សាជាគ្រួសារ ។ អ្នកក៏នឹងទទួលបានសៀវភៅសិក្សាសម្រាប់គ្រូបង្រៀន ដើម្បីជួយអ្នកបង្កើតបទពិសោធន៍ទំនាក់ទំនងក្នុងថ្នាក់រៀន ដែលគាំទ្រដល់ការសិក្សាព្រះគម្ពីរដែលសមាជិកថ្នាក់កំពុងរៀនសូត្រនៅគេហដ្ឋាន ។

សម្រាប់ព័ត៌មានបន្ថែមអំពីធនធានថ្មី *ចូរមកតាមខ្ញុំ* នេះ សូមមើលគេហទំព័រ **comefollowme.lds.org** ។

# ការសម្រេចចិត្ត និងអព្ភូតហេតុ ៖ ហើយឥឡូវនេះខ្ញុំឃើញ

ដោយ អ៊ីរីណា វី ក្រាតហ្សេី

ការចេញផ្សាយជាបន្តបន្ទាប់នេះដកស្រង់ផ្នែកសំខាន់ៗអំពីជីវិតស្ត្រីដ៏ស្មោះត្រង់ និងសារលិខិតរបស់ពួកគាត់ ដកស្រង់ចេញពីសៀវភៅ *At the Pulpit: 185 Years of Discourses by Latter-day Saint Women* ( ឆ្នាំ ២០១៧ ) ។ សៀវភៅនេះមានជាភាសាអង់គ្លេស ព័រទុយហ្គាយ និងអេស្ប៉ាញ ។

មានគ្រាមួយក្នុងជីវិតខ្ញុំ កាលខ្ញុំទទួលបានការរំជួលចិត្ត ដោយសារតែសេចក្តីស្រឡាញ់ និងពន្លឺនៃព្រះគ្រីស្ទ ។ ចាប់តាំងពីពេលនោះមក ជីវិតរបស់ខ្ញុំបានផ្លាស់ប្តូរជារៀងរហូត ។

ខ្ញុំដឹងថា តើវាមានសភាពយ៉ាងដូចម្តេចដែលរស់នៅគ្មានដំណឹងល្អនោះ ។ ខ្ញុំរស់នៅដោយគ្មានដំណឹងល្អអស់រយៈពេល ៣០ ឆ្នាំ ។ ខ្ញុំបានកើតមកពីឪពុកម្តាយល្អនៅក្នុងប្រទេសរុស្ស៊ី ។ . . . ពេលខ្ញុំធំឡើង ខ្ញុំបានរៀបការ ហើយបានផ្តល់កំណើតឲ្យកូនស្រីម្នាក់ដ៏គួរឲ្យស្រឡាញ់ ។ មិនយូរប៉ុន្មានក្រោយមក ខ្ញុំបានបញ្ចប់ការសិក្សាប្រកបដោយជោគជ័យពីសាកលវិទ្យាល័យ ហើយទទួលបានការងារមួយដែលខ្ញុំចូលចិត្តខ្លាំងណាស់ ។ ប៉ុន្តែ . . . ខ្ញុំមិនសប្បាយចិត្តទាល់តែសោះ ។

. . . អាពាហ៍ពិពាហ៍របស់ខ្ញុំ . . . បានប្រេះឆាបន្តិចម្តងៗ ។ . . . ខ្ញុំពុំអាចផ្តល់អាហារយ៉ាងសាមញ្ញដល់កូនស្រី និងរូបខ្ញុំផង ។ ខ្ញុំមានបាប ។ ខ្ញុំបានសម្រេចចិត្តខុសម្តងហើយម្តងទៀត ។ សេចក្តីស្រេកឃ្លានការបាក់ទឹកចិត្ត និងការសម្រេចចិត្តដោយគ្មានការពិចារណាបានធ្វើឲ្យជីវិតខ្ញុំជួបនឹងទុក្ខសោក ។ ខ្ញុំ [ បានបន្ទោស ] ដល់ជោគវាសនាអាក្រក់ ប៉ុន្តែពុំទទួលស្គាល់ថា នៅក្នុងរបៀបជាច្រើន ខ្ញុំបានរងទុក្ខដោយសារតែលទ្ធផលនៃអំពើបាបពីធម្មជាតិរបស់ខ្ញុំ ។ ប៉ុន្តែតើខ្ញុំអាចដឹងរឿងនោះដោយរបៀបណា ? យោងតាមអ្វីដែលខ្ញុំត្រូវបានបង្រៀនគឺថា គ្មានទេអំពើបាប ។ . . .

សាសនានៅក្នុងសហភាពសូវៀតត្រូវបានហាមប្រាមបន្ទាប់ពីបដិវត្តន៍របបគុម្មុនីសយ៍ក្នុងឆ្នាំ ១៩១៧ ។ ខ្ញុំត្រូវបានបង្រៀនតាំងពីថ្នាក់មត្តេយ្យថា គ្មានព្រះទេ ហើយមានតែបក្សគុម្មុនីសយ៍ និងលោកតាលេនីនប៉ុណ្ណោះដែលអាចនាំសុភមង្គលមកកាន់ប្រជាជនរុស្ស៊ី ។ មនុស្សដែលកាន់សាសនាត្រូវទទួលរងការបៀតបៀនយ៉ាងសាហាវឃោរឃៅនៅក្នុងសង្គមរបស់យើង ។ អ្នកមានជំនឿបាត់បង់ការងាររបស់ពួកគេ ពុំត្រូវបានអនុញ្ញាតឲ្យទៅសាលារៀន ហើយត្រូវបានគេហៅថា « មនុស្សឆ្កួត » ។ ប្រជាជនត្រូវបានតម្រូវឲ្យរៀនថ្នាក់អ្នកដែលមិនជឿលើព្រះនៅសាកលវិទ្យាល័យ ជាកន្លែងដែលយើងបានបង្ហាញថា គ្មានព្រះទេ ។ . . . ខ្ញុំពុំគិតអំពីព្រះឡើយ ។ ប៉ុន្តែខ្ញុំមានអារម្មណ៍ឈឺចាប់ក្នុងចិត្តខ្ញុំអំពីជម្រើសមិនល្អរបស់ខ្ញុំ ។ ក្រោយមកខ្ញុំបានរៀនថា ការឈឺចាប់ដែលខ្ញុំបានទទួលអារម្មណ៍នោះគឺជា ពន្លឺនៃព្រះគ្រីស្ទដែលផ្តល់ដល់ខ្ញុំនូវញាណមួយនៃការដឹងអ្វីដែលល្អ និងអាក្រក់ ។ . . .

. . .ជីវិតរបស់ខ្ញុំហាក់បីដូចជារូងងងឹតក្រោមដីមួយដែលមានតែសេចក្តីស្លាប់នៅទីបំផុតប៉ុណ្ណោះ ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំកំពុងស្លាប់ដោយសន្សឹមៗហើយ ។ . . . ខ្ញុំពុំចេះរបៀបអធិស្ឋានឡើយ ដូច្នេះខ្ញុំបានសុបិន ។ . . . ខ្ញុំបានសុបិនថា នៅថ្ងៃណាមួយ ខ្ញុំនឹងរត់គេចចេញពីទុក្ខសោកគ្រប់យ៉ាងនៅក្នុងជីវិតរបស់ខ្ញុំ ហើយចាប់ផ្តើមជីវិតថ្មីម្តងទៀត—ជាជីវិតថ្មីដែលរីករាយ និងមានពន្លឺ ។ ខ្ញុំចង់ឲ្យកូនស្រីរបស់ខ្ញុំមានជីវិតដែលល្អប្រសើរជាងខ្ញុំ ។ . . .



## អំពីស៊ីស្ទើរក្រាតហ្សេី

អ៊ីរីណា វ៉ាឡិនធីណូណា ក្រាតហ្សេី ( កើតឆ្នាំ ១៩៦៥ ) បានរស់នៅទីក្រុងប៉ាណូល ប្រទេសស៊ីបេរី ជាកន្លែងដែលគាត់បានទៅរៀននៅសាលាពេទ្យ ហើយក្លាយជាអ្នកឯកទេសខាងជំងឺបេះដូង ។ ពេទ្យពុំអាចរកកម្រៃបានច្រើនឡើយ ហើយអស់ពេលជាច្រើនខែដែលមន្ទីរពេទ្យពុំបានបង់ប្រាក់ខែឲ្យបុគ្គលិក ។ បន្ទាប់ពីលះលែងពីប្តីដ៏កាចសាហាវរបស់គាត់ក្នុងឆ្នាំ ១៩៩៦ មក អ៊ីរីណាមានអារម្មណ៍នឿយណាយ និងអស់សង្ឃឹម ពេលគាត់ធ្វើការថែមម៉ោងនៅវេនយប់ ដើម្បីទំនុកបម្រុងដល់ម្តាយ និងកូនស្រីរបស់គាត់ជាមួយនឹងប្រាក់ខែដ៏ទាប ។

អ៊ីរីណាត្រូវបានចិញ្ចឹមបីបាច់ឲ្យធំឡើងនៅក្នុងបរិយាកាសមួយនៃអ្នកមិនជឿព្រះ ហើយពុំជឿលើព្រះឡើយ ។ ទោះជាដូច្នោះក្តី នាយប់មួយគាត់បានធ្វើការស្នើសុំមួយ ៖ « ឱព្រះអើយ ប្រសិនបើមានទ្រង់មែននោះ សូមឲ្យខ្ញុំម្ចាស់ដឹងផងដោយសារទ្រង់ប្រហែលពុំបានខ្វាយខ្វល់ពីខ្ញុំម្ចាស់ឡើយ ។ តើខ្ញុំម្ចាស់ជាអ្វីនឹងទ្រង់ទៅ ជាអ្វីមួយតូចតាចដែលខំត្រដររស់មែនទេ ? »

ពីរបីសប្តាហ៍ក្រោយមក នៅក្នុងខែសីហា ឆ្នាំ ១៩៩៦ អ៊ីរីណាបានជួបនឹងបុរសម្នាក់ដែលបានណែនាំគាត់ឲ្យស្គាល់សាសនាចក្រ ហើយជួយគាត់ឲ្យធ្វើដំណើរទៅសហរដ្ឋអាមេរិកដើម្បីរៀនភាសាអង់គ្លេស ។ ប្រាំបីខែក្រោយមក បន្ទាប់ពីគាត់ទៅដល់រដ្ឋយូថាហ៍ ស. រ. អា. នៅខែមេសា ឆ្នាំ ១៩៩៨ អ៊ីរីណាបានរៀបការជាមួយ តាយ ក្រាតហ្សេី ។

ស៊ីស្ទើរក្រាតហ្សេីគឺជាគ្រូបង្រៀននៅក្នុងថ្នាក់សមាគមសង្គ្រោះនៅទីក្រុងអូរិម រដ្ឋយូថាហ៍ កាលដែលគេបានអញ្ជើញគាត់ឲ្យឡើងនិយាយនៅឯសន្និសីទស្ត្រីនៅសាកលវិទ្យាល័យ ព្រិកហាំយ៉ង់ ។ ការដាក់វណ្ណយុត្តិ និងអក្សរធំបានអនុលោមតាមបទដ្ឋាន ។

[ បន្ទាប់មក ] ព្រះគម្ពីរមរមនបានចូលមកក្នុងជីវិតខ្ញុំ ។ ខ្ញុំអានព្រះគម្ពីរមួយជំពូករៀងរាល់ព្រឹកពីមុនទៅធ្វើការ ។ ការអានព្រះគម្ពីរនេះ ធ្វើឲ្យខ្ញុំរៀនថា ព្រះមានព្រះជន្មរស់ ថាព្រះយេស៊ូវគឺជាព្រះរាជបុត្រាទ្រង់ [ ដែល ] យាងចុះមកកាន់ផែនដីនេះដើម្បីជួយអ្នកមានបាបដូចជារូបខ្ញុំ ។ កាលណាខ្ញុំកាន់តែអានព្រះគម្ពីរនេះ នោះខ្ញុំកាន់តែឃើញការខ្វះចន្លោះរវាងការបង្រៀននៃព្រះគ្រីស្ទ និងរបៀបដែលខ្ញុំបានរស់នៅ ។ ខ្ញុំបានរៀនថា ហេតុអ្វីជីវិតរបស់ខ្ញុំមានទុក្ខសោកអ្វីម្ល៉េះ ? . . .

. . . ខ្ញុំបានត្រៀមខ្លួនរួចជាស្រេចសម្រាប់ការផ្លាស់ប្ដូរដ៏ធំ ។ ខ្ញុំនឹងចងចាំនូវរាត្រីនោះជានិច្ច . . . កាលខ្ញុំយំពេញមួយយប់ ដោយសារដឹងថា ជីវិតខ្ញុំមិនល្អ ថាការសម្រេចចិត្តមិនល្អរបស់ខ្ញុំបានធ្វើឲ្យមនុស្សដែលខ្ញុំស្រឡាញ់បំផុតមានការឈឺចាប់ ។ វាគឺជាបទពិសោធន៍ដ៏ឈឺចាប់ខ្លាំងបំផុតក្នុងជីវិតខ្ញុំ ។ ខ្ញុំបានយំខ្សឹបខ្សួល និងអធិស្ឋានទូលអង្វរពេញមួយយប់ ។ . . . នៅទាបភ្លឺឡើង ខ្ញុំអស់កម្លាំងរលីងពីខ្លួន ហើយគ្មានទឹកភ្នែកយំទៀតទេ ។ នៅពេលពន្លឺព្រះអាទិត្យនាពេលព្រឹកបានរះឡើង ភាពសុខសាន្ត និងការធូរស្បើយបានកើតឡើងចំពោះខ្ញុំ ។ ខ្ញុំឮពាក្យថា ៖ « នេះជាព្រះហស្តយើង ។ យើងនឹងនាំអ្នក ហើយដឹកដៃអ្នក ។ ប៉ុន្តែអ្នកត្រូវសន្យានឹងខ្ញុំថា អ្នកត្រូវតែផ្លាស់ប្ដូរ » ។ ហើយខ្ញុំបានធ្វើតាមការសន្យានោះ ។ ខ្ញុំចង់បានការណែនាំ និងជំនួយនេះជាងអ្វីៗទាំងអស់ ។ . . .

នៅរាត្រីនៃក្ដីឈឺចាប់ និងអំណរនៅឯប្រទេសរុស្ស៊ីនោះ ខ្ញុំពុំបានដឹងឡើយថា ការសន្យារបស់ព្រះគ្រីស្ទមានទំហំធំធេងបែបណានោះទេ ។ កាលនោះខ្ញុំពុំដឹងឡើយថា ក្នុងរយៈពេលដ៏ខ្លីប៉ុណ្ណោះ ខ្ញុំនឹងធ្វើដំណើរទៅប្រទេសអាមេរិក ជាកន្លែងដែលខ្ញុំរៀនកាន់តែច្រើនអំពីដំណឹងល្អ ហើយមិនយូរប៉ុន្មានក្រោយមកខ្ញុំបានជ្រមុជទឹក ។ . . . ខ្ញុំពុំដឹងទេថា កូនស្រីរបស់ខ្ញុំនឹងមកប្រទេសអាមេរិកដើម្បីចូលរួមជាមួយពួកយើងក្នុងសុភមង្គលឡើយ ។ . . .

. . . ទ្រង់បានប្រទានអព្ភូតហេតុជាច្រើនដែលខ្ញុំពុំមានឱកាសសង្ស័យអំពីជំនួយនៃភាពជាព្រះរបស់ទ្រង់ក្នុងជីវិតរបស់ខ្ញុំឡើយ ។ . . .

ចូរដើរជាមួយព្រះគ្រីស្ទ ! ចូរកាន់ព្រះហស្តទ្រង់ឲ្យជាប់ ! ចូរទទួលទាននូវព្រះបន្ទូលនៃព្រះគ្រីស្ទ ។ ចូរទទួលពន្លឺរបស់ទ្រង់នូវគ្រប់ផ្នែកទាំងអស់របស់អ្នកជាមួយនឹងព្រលឹងទាំងស្រុងរបស់អ្នក ។ នៅក្នុងគ្រាដ៏លំបាក នោះអ្នកពុំត្រូវបានទុកចោលឲ្យនៅក្នុងរូងក្រោមដីដ៏ងងឹតនោះទេ ប៉ុន្តែនឹងទទួលពន្លឺនៃសេចក្ដីស្រឡាញ់របស់ទ្រង់ជាមួយនឹងពន្លឺកាន់តែភ្លឺឡើងនៅខាងមុខអ្នកជានិច្ច ។ ■



រូបថតដោយ GETTY IMAGES

# « យើងជាព្រះដ៏ជាព្រះ »

## និមិត្តសញ្ញានៃព្រះគ្រីស្ទនៅក្នុងព្រះគម្ពីរសញ្ញាចាស់

ដោយទ្បែក នៅក្នុងកំណត់ត្រាបុរាណនេះ ព្រះយេស៊ូវគ្រីស្ទត្រូវបានគេស្វែងរក ឬគេពុំអាចរកទ្រង់ឃើញឡើយ ។



**ដោយ ស្ទីហ្វិន ភី ស្ពែន**

នាយកដ្ឋានបព្វជិតភាព និង គ្រួសាររបស់សាសនាចក្រ

ពេលម៉ូសេបាំងមុខរបស់លោក នោះព្រះបន្ទូលប្រកបដោយសេចក្ដីមេត្តាករុណារបស់ព្រះអម្ចាស់បានចេញមកពីគុមបន្លាភ្លើងដោយសំឡេងខ្ទរនៃភាពអស់កល្បថា ៖ « យើងបានឃើញសេចក្ដីវេទនារបស់រាស្ត្រយើង ដែលនៅស្រុកអេស៊ីព្ទហើយ . . . ពីព្រោះយើងស្គាល់សេចក្ដីទុក្ខព្រួយរបស់គេ

ដូច្នេះយើងបានចុះមក ដើម្បីនឹងជួយដោះគេឲ្យរួច ។ . . .

ម៉ូសេក៏ទូលទៅព្រះថា មើលកាលណាទូលបង្គំទៅប្រាប់ពួកកូនចៅអ៊ីស្រាអែលថា ព្រះនៃឰយុកោអ្នករាល់គ្នាទ្រង់បានចាត់ខ្ញុំឲ្យមកឯអ្នករាល់គ្នា ហើយគេសួរទូលបង្គំថា តើព្រះទ្រង់ព្រះនាមជាអ្វី ? នោះតើត្រូវឲ្យទូលបង្គំប្រាប់គេថាដូចម្ដេច ?

ព្រះទ្រង់មានព្រះបន្ទូលទៅម៉ូសេថា « យើងជាព្រះដ៏ជាព្រះ ៖ រួចទ្រង់មានព្រះបន្ទូលទៀតថា ឯងត្រូវឆ្លើយប្រាប់ដល់ពួកកូនចៅអ៊ីស្រាអែលដូច្នេះថា ព្រះដ៏ជាព្រះទ្រង់បានចាត់ឲ្យខ្ញុំមកឯអ្នករាល់គ្នា » ( និក្ខមនំ ៣:៧–៨, ១៣–១៤ ) ។

ពួកសាសន៍អ៊ីស្រាអែលជំនាន់ដើមស្គាល់ទ្រង់ថា ព្រះយេហូវ៉ា ជីវិតមុនឆាកជីវិតនេះរបស់ព្រះយេស៊ូវគ្រីស្ទបានរកឃើញព្រះអង្គទ្រង់ថា ជាធនធនាដែលប្រជារាស្ត្ររបស់ទ្រង់គួរតែស្វែងរកការប្រោសលោះ ។ ជាច្រើនពាន់ឆ្នាំក្រោយមក ព្រះយេស៊ូវគ្រីស្ទដែលមានព្រះជន្មរស់ឡើងវិញ បានបញ្ជាក់អំពីការសន្យារបស់ទ្រង់ឡើងវិញអំពីការរំដោះដល់ពួកអ៊ីស្រាអែលសម័យទំនើបជាមួយព្រះបន្ទូលទាំងនេះ ៖ « ចូរសង្ឃឹមឡើង ហើយចូរកុំខ្លាចឡើយ ដ្បិតយើងជាព្រះអម្ចាស់គង់នៅជាមួយនឹងអ្នក ហើយនឹងឈរនៅក្បែរអ្នក ហើយអ្នកនឹងថ្លែងទីបន្ទាល់អំពីយើងគឺព្រះយេស៊ូវគ្រីស្ទថា *យើងជា* ព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅ ថា *យើងគង់នៅតាំងពីដើម* ហើយ *យើងនៅឥឡូវនេះ* ហើយថា *យើងត្រូវយាងមកទៀត* » ( គ. និង ស. ៦៨:៦ ការគូសបញ្ជាក់ត្រូវបានបន្ថែម ) ។

ព្រះគម្ពីរជាព្រះបន្ទូលនៃជីវិតត្រូវបានរៀបចំឡើងដើម្បីចង្អុលបង្ហាញដល់បុត្រាបុត្រីរបស់ព្រះនៅគ្រប់ជំនាន់អំពី ព្រះយេស៊ូវគ្រីស្ទសម្រាប់ការរំដោះពីអំពើបាប និងសេចក្ដីស្លាប់ និងពីបញ្ហានានាខាងលោកិយទាំងអស់របស់យើង ។ ព្រះគម្ពីរសញ្ញាចាស់ក៏គ្មានករណីលើកលែង ដូចជាភាគនៃព្រះគម្ពីរនីមួយៗដែរ ព្រះគម្ពីរសញ្ញាចាស់មានគោលបំណងបង្វែរដួងចិត្ត និងគំនិតរបស់យើងទៅរកព្រះអង្គដែលរំដោះយើងគឺព្រះយេស៊ូវគ្រីស្ទ ។ ប៉ុន្តែដោយទ្បែក នៅក្នុងកំណត់ត្រាបុរាណនេះ ទ្រង់ត្រូវបានគេស្វែងរក ឬគេពុំអាចរកទ្រង់ឃើញឡើយ ។

នៅពេលស្វែងរកព្រះគ្រីស្ទនៅក្នុងគម្ពីរណាមួយទាំងនេះ វាជួយរំឭកយើងយ៉ាងខ្ជាប់ខ្ជួននូវអ្វីដែលយើងកំពុងស្វែងរក ។ ព្រះយេស៊ូវគ្រីស្ទ *គឺជា* ប្រភពនៃជីវិត ! បញ្ហានៃសេចក្ដីស្លាប់ខាងវិញ្ញាណ និងខាងសាច់ឈាមដែលជាលទ្ធផលនៃការធ្លាក់ នោះព្រះគ្រីស្ទ *គឺជា* ដំណោះស្រាយដ៏អស់កល្បរបស់ពួកសាសន៍អ៊ីស្រាអែល ។ លីហៃបានប្រកាសថា « ទ្រង់ថ្វាយរូបអង្គទ្រង់ . . . ដើម្បី *តបស្នង* ការចុងបំផុតនៃក្រឹត្យវិន័យ » ( នីហ្វៃទី ២ ២:៧ ការគូសបញ្ជាក់ត្រូវបានបន្ថែម ) ។ វាគឺជាចម្លើយនោះ—ព្រះអង្គប្រោសលោះនៃអ៊ីស្រាអែល « យើងគឺជាព្រះ » ដ៏មហិមា—ដែលយើងស្វែងរកនៅពេលស្រាវជ្រាវក្នុងព្រះគម្ពីរ ។ ប៉ុន្តែ នៅក្នុងកំណាព្យ ហើយជារឿយៗនៅក្នុងភាសាហួសសម័យនៃព្រះគម្ពីរសញ្ញាចាស់ បញ្ហាអស់កល្ប—ហើយព្រះយេស៊ូវគ្រីស្ទគឺជាដំណោះស្រាយនោះ—ពុំត្រូវបានរកឃើញដោយងាយៗនោះទេ ។ ទោះជាយ៉ាងនោះក្ដី ព្រះយេស៊ូវគ្រីស្ទកំពុងរង់ចាំនៅក្នុងការសិក្សាព្រះគម្ពីរឲ្យស៊ីជម្រៅ ក្នុងនិទានកថាបុរាណ ។

ដូចអ្នកចាំក្នុងចិត្តអំពីឈ្មោះព្រះអម្ចាស់ដែលបានចែកចាយជាមួយម៉ូសេនៅលើភ្នំស៊ីណាយ—« យើងជាព្រះ »—សូមពិចារណាអំពីអ្វីៗជាច្រើនដែលព្រះយេស៊ូវគ្រីស្ទ *តំណាងឲ្យ* ដល់អ្នកដែលដាក់ទីទុកចិត្តលើទ្រង់ ។ គំរូដូចតទៅនេះគឺជានិមិត្តសញ្ញានៃការបង្រៀនមកពីព្រះគម្ពីរសញ្ញាចាស់ដែលបានរៀបចំឡើងដើម្បីបង្វែរដួងចិត្ត និងគំនិតរបស់យើងចំពោះព្រះអម្ចាស់យេស៊ូវគ្រីស្ទសម្រាប់ការប្រោសលោះ ។

## ការស្វែងរកព្រះយេស៊ូវគ្រីស្ទនៅក្នុងព្រះគម្ពីរសញ្ញាចាស់

អែលឌើរ ប្រ៊ូស អ័រ. ម៉ាក់ខន់ឃី ( ១៩១៥–១៩៨៥ ) ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានសរសេរថា ពួកព្យាការី រួមទាំងអស់អ្នកដែលនៅក្នុងព្រះគម្ពីរសញ្ញាចាស់ អាចត្រូវបានមើលឃើញថាជា « គំរូ និង និមិត្តរូបនៃព្រះមែស៊ីរបស់ពួកគេ ។ វាជារឿងត្រឹមត្រូវ និងសមរម្យដើម្បីរកមើលនិមិត្តសញ្ញានៃព្រះគ្រីស្ទគ្រប់ទីកន្លែង ហើយប្រើវាម្ដងហើយម្ដងទៀតនៅក្នុងការចងចាំទ្រង់ និង រក្សាបទបញ្ញត្តិទ្រង់ជានិច្ចនៅក្នុងគំនិតយើង » ( *The Promised Messiah* [ ឆ្នាំ ១៩៨៥ ] ទំព័រ ៤៥៣ ) ។

ព្រះគម្ពីរសញ្ញាចាស់ពុំត្រូវបានរៀបចំឡើងដោយសាមញ្ញដើម្បីរក្សាទុកនូវនិទានកថាអំពីប្រវត្តិនៃរាស្ត្រក្នុងសេចក្ដីសញ្ញារបស់ព្រះឡើយ ។ រឿងទាំងនោះ ជាមួយនឹងសារលិខិត និងដំបូន្មានដែលមានជាមួយនឹងវា គឺជាផ្នែកសំខាន់បន្ទាប់បន្សំចំពោះសិស្សនៃព្រះគ្រីស្ទ ។ ដោយមិនផ្លាស់ប្ដូរ នោះប្រធានបទចម្បងនៃការសរសេររបស់ពួកព្យាការី—និងកម្មបទដ៏មានតម្លៃបំផុតនៃប្រធានបទនៃការសិក្សារបស់យើង—គឺព្រះយេស៊ូវគ្រីស្ទ !

នេះគឺជាគោលការណ៍មួយចំនួនដើម្បីចាំទុកក្នុងចិត្ត នៅពេលស្រាវជ្រាវរកសេចក្ដីពិតអំពីព្រះយេស៊ូវគ្រីស្ទនៅក្នុងព្រះគម្ពីរសញ្ញាចាស់ ៖

១. អ្វីៗទាំងអស់ដែលព្រះបានប្រទានមកដល់មនុស្សគឺជាគំរូអំពីព្រះយេស៊ូវគ្រីស្ទ ( សូមមើល នីហ្វៃទី ២ ១១:៤; ម៉ូសេ ៦:៦៣ ) ។

២. ពួកព្យាការីទាំងអស់គឺជាគំរូ ឬនិមិត្តរូបអំពីព្រះយេស៊ូវគ្រីស្ទ ( សូមមើល ប្រ៊ូស អ័រ ម៉ាក់ខន់ឃី *The Promised Messiah* [ ឆ្នាំ ១៩៨៧ ] ទំព័រ ៤៥១ ) ។

៣. ការប្រែចិត្តបើកទ្វារទៅរកការរៀនសូត្រអំពីព្រះយេស៊ូវគ្រីស្ទតាមរយៈគំរូ ( សូមមើល អាលម៉ា ២៦:២១–២២ ) ។

ពន្លឺ និងសេចក្ដីពិត ដោយ ស៊ីម៉ុន ឌូវី

**យើងជាព្រះ** ... កូនចៀមដែលបានសម្លាប់សម្រាប់អ្នក

## ការបូជាយញ្ញសត្វ និងអាវធ្វើពីស្បែក



ពីមុនអ័ដាម និងអេវ៉ាត្រូវបានបណ្ដេញចេញពីសួនអេដែន នោះព្រះអម្ចាស់បានឲ្យសម្លៀកបំពាក់ដល់ពួកគេដែលធ្វើពីស្បែកសត្វ ដើម្បីផ្ដល់ការបិទបាំងកាយឲ្យពួកគេ ។ នៅក្នុងព្រះគម្ពីរសញ្ញាចាស់ ពាក្យ *ដង្វាយធួន* នៅក្នុងទម្រង់ជាច្រើនរបស់វាបង្ហាញឡើងចំនួន ៨១ ដង ។ មាន ៧៣ ដងកើតឡើងដដែលៗនៃពាក្យនោះ ដែលន័យដើមជាភាសាហេព្រើរគឺ *kaphar* ដែលមានន័យថា « បិទបាំង » ។

បន្ទាប់ពីពួកគេត្រូវបានបណ្ដេញចេញពីសួនច្បារមក អ័ដាម និងអេវ៉ាត្រូវបានបញ្ជាឲ្យថ្វាយកូនច្បងនៃហ្វូងសត្វរបស់ពួកគេសម្រាប់ជាយញ្ញបូជាថ្វាយដល់ព្រះអម្ចាស់ ។ ក្រោយមកទេវតាមួយអង្គបានបង្គាប់ពួកគេថា ការប្រតិបត្តិនេះគឺជា « និមិត្តរូបអំពីការបូជានៃព្រះរាជបុត្រាបង្កើតតែមួយនៃព្រះវរបិតា » ( ម៉ូសាយ ៥:៧ ) ។

ការធ្វើយញ្ញបូជាសត្វបានបន្តនៅក្រោមក្រឹត្យវិន័យរបស់ម៉ូសេ ពិធីដែលបិទបាំងនៃអស់អ្នកដែលចូលរួមនៅក្នុងពិធីបរិសុទ្ធបព្វជិតភាព ។

នៅពេលយើងចុះសេចក្ដីសញ្ញាជាមួយព្រះអម្ចាស់ ហើយទទួលពិធីបរិសុទ្ធដ៏បរិសុទ្ធរបស់ទ្រង់ នោះដង្វាយធួនរបស់ទ្រង់បិទបាំងយើង ដូច្នេះយើងពុំត្រូវប៉ះផ្ទាល់នឹងឥទ្ធិពលទាំងស្រុងនៃការធ្លាក់របស់អ័ដាមឡើយ ។ ព្រះយេស៊ូវគ្រីស្ទពិតជាកូនចៀមនៃព្រះ ដែលបានបូជាសម្រាប់យើង ដូច្នេះយើងពុំចាំបាច់ចុះចូលនឹងឥទ្ធិពលនៃអំពើបាប និងសេចក្ដីស្លាប់ឡើយ ។

**លោកុប្បត្តិ ៣:២១;** ៣៧:៣; និក្ខមនំ ៤០:១៤–១៥; អេសេគាល ១៦:១–១២; ម៉ាថាយ ២២:១១–១២; កាឡាទី ៣:២៦–២៩; នីហ្វៃទី ១ ១១:២១, ៣២–៣៣; អាលម៉ា ៣៤:១៤–១៦; ម៉ូសេ ៥:៥–៨; ៧:៤៧

**យើងជា** ... នំបុ័ងជីវិត

## នំម៉ាន៉ា



អំឡុងពេលម៉ូសេ និងកូនចៅនៃសាសន៍អ៊ីស្រាអែលបានធ្វើដំណើរពីស្រុកអេស៊ីព្ទទៅកាន់ដែនដីសន្យា ពួកគេបានពឹងផ្អែកលើព្រះគុណនៃព្រះអម្ចាស់ដើម្បីទទួលបានអាហារប្រចាំថ្ងៃ ។ ព្រះអម្ចាស់បានប្រទានពួកគេនូវ « នំបុ័ងពីលើមេឃមក » ដែលមនុស្សហៅថា « នំម៉ាន៉ា » ( ដែលបកស្រាយថា « តើនេះជាអ្វី ? » ) ។ អ្នកដែលបានប្រមូលអាហាប្រចាំថ្ងៃ និងបន្តស្មោះត្រង់ចំពោះព្រះអម្ចាស់ និងព្យាការីរបស់ទ្រង់មានជីវិតបន្តរហូតដល់ដំណើរពួកគេចប់នៅក្នុងទីរហោស្ថាន ។

ព្រះយេស៊ូវគ្រីស្ទគឺជានំបុ័ងជីវិត ទ្រង់បានយាងចុះពីស្ថានសួគ៌មកកាន់ផែនដីដើម្បីនាំឲ្យយើងមានជីវិតរៀងរាល់ថ្ងៃនៃដំណើរក្នុងជីវិតរមែងស្លាប់របស់យើងនេះ ។ នៅពេលយើងប្រមូលព្រះបន្ទូលរបស់ទ្រង់រៀងរាល់ថ្ងៃ យើងនឹងដកពិសោធន៍នូវភាពផ្អែមល្ហែម និងភាពត្អៀរក្លាដែលមានតាមរយៈទ្រង់ពេញមួយដំណើរនៃជីវិតរមែងស្លាប់របស់យើង ។

**និក្ខមនំ ១៦:៤, ១២–២១, ៣១;** ចោទិយកថា ៨:២–៣; យ៉ូហាន ៦:២៦–៣៥, ៤៨–៥៨, ៦៦–៦៨; នីហ្វៃទី ៣ ២០:៨

**យើងជា** ... ប្រភពនៃទឹករស់

**ទឹកចេញមកពីថ្មនៅភ្នំហោរែប**



នៅពេលកូនចៅសាសន៍អ៊ីស្រាអែលស្រេកទឹកនៅក្នុងទីរហោស្ថាន នោះម៉ូសេបានអធិស្ឋានទៅកាន់ព្រះអម្ចាស់ ។ ម៉ូសេត្រូវបានបង្គាប់ឲ្យវាយដុំថ្មមួយនៅភ្នំហោរែប ( ភ្នំស៊ីណាយ ) ជាមួយឈើដែលព្រះអម្ចាស់បានប្រទានឲ្យលោក ។ នៅពេលលោកធ្វើដូច្នេះ ទឹកបានផ្លាយចេញមកពីថ្ម ដើម្បីផ្គត់ផ្គង់ដល់ជីវិតនៃពួកសាសន៍អ៊ីស្រាអែលរាប់លាននាក់ដែលកំពុងធ្វើដំណើរនោះ ។ ព្រះយេស៊ូវគ្រីស្ទគឺជាថ្មដានៃសាសន៍អ៊ីស្រាអែល នៅពេលទ្រង់ត្រូវបានគេវាយនៅត្រង់ភ្នំកាល់វ៉ារី នោះព្រះលោហិតបានហូរចេញមកពីព្រះកាយរបស់ទ្រង់ ។ ព្រះលោហិតរបស់ព្រះគ្រីស្ទបានផ្ដល់ជីវិតដល់ពួកយើង ! យើងអាចទទួលបានជីវិតដែលរកឃើញនៅក្នុងព្រះលោហិតដ៏ធួននៃព្រះគ្រីស្ទ នៅពេលយើងធ្វើតាមព្យាការីដែលត្រូវបានប្រគល់កូនសោ ដើម្បីនាំយកទឹករស់ចេញមកពីទ្រង់ ។
**និក្ខមនំ ១៧:១–៦; ជនគណនា ២០:៨, ១១;** យ៉ូហាន ៤:១០–១៥; កូរិនថូសទី ១ ១០:១–៤; គ. និង ស. ២៨:២

**យើងជា** ... អង្គព្យាបាលរបស់អ្នក

**សត្វពស់ដែលត្រូវបានលើកឡើងនៅលើបង្គោលឈើ**



ភាពលំបាកនៃការធ្វើដំណើររបស់ពួកគេ បានបណ្ដាលឲ្យពួកកូនចៅនៃសាសន៍អ៊ីស្រាអែលត្អូញត្អែល រអ៊ូរទាំទាស់នឹងព្យាការី និងព្រះអម្ចាស់ ។ ជាលទ្ធផលព្រះអម្ចាស់បានធ្វើឲ្យសត្វពស់មានពិសចឹកពួកគេ ដែលនាំឲ្យមានមនុស្សស្លាប់ជាច្រើននាក់ ។ ម៉ូសេបានអធិស្ឋានទៅកាន់ព្រះអម្ចាស់សូមឲ្យដកសត្វពស់នោះចេញ ផ្ទុយទៅវិញ ព្រះអម្ចាស់បានប្រទាននូវវិធីមួយសម្រាប់មនុស្សដើម្បីគេចផុតពីសេចក្ដីស្លាប់ នៅពេលពួកគេត្រូវបានពស់ចឹក ។ សកម្មភាពដែលតម្រូវឲ្យពួកគេបានទទួលការព្យាបាលនោះគឺ មើលទៅសត្វពស់លង្ហិនដែលចងជាប់ទៅនឹងបង្គោលមួយ ។
ព្រះយេស៊ូវគ្រីស្ទត្រូវបានគេបោះដែកគោលភ្ជាប់ទៅលើបង្គោល – ឈើឆ្កាង – ដើម្បីយើងអាចមើលទៅកាន់ទ្រង់នៅក្នុងការរងទុក្ខរបស់យើង ហើយយកឈ្នះលើបញ្ហាទាំងអស់នោះ ។ ព្រះយេស៊ូវគ្រីស្ទពុំដកការសាកល្បងយើងចេញជានិច្ចនោះទេ ប៉ុន្តែក្នុងនាមជាអង្គព្យាបាលរបស់យើង នោះទ្រង់អាចយកភាពពិសពុលចេញពីពួកគេតាមរយៈពរជ័យនៃដង្វាយធួនរបស់ទ្រង់ ។
**ជនគណនា ២១:៤–៩;** យ៉ូហាន ៣:១៤–១៦; ពេត្រុសទី ១ ២:២៤; អាលម៉ា ៣៣:១៨–២២; ហេលេមិន ៨:១៤–១៥; នីហ្វៃទី ៣ ២៧:១៣–១៥

# អំពូលភ្លើងពណ៌ក្រហមមួយ

*ដោយ ឡូរី រ៉ាយ*

*គ្រឿងតុបតែងដើមគ្រីស្ទម៉ាស់សាមញ្ញមួយបានរំឭកខ្ញុំអំពីអត្ថន័យដ៏ពិតនៃបុណ្យគ្រីស្ទម៉ាស់ ។*

បុណ្យគ្រីស្ទម៉ាស់ពុំមានអារម្មណ៍ថាជាគ្រីស្ទម៉ាសឡើយ ។ ទោះបីជាខ្ញុំបានព្យាយាមរីករាយជាមួយនឹងបទចម្រៀងដែលប្រគំឡើងក្ដី នោះខ្ញុំបានទាញយកធុងស្ដុកឥវ៉ាន់ចេញមកទាំងមានទុក្ខព្រួយ ។ ក្រឡនំមនុស្សព្រិលបានរំឭកខ្ញុំថា គ្មាននរណាដុតនំជាមួយខ្ញុំឡើយ ។ រូបចម្លាក់នៃលោកតាណូអែលដែលហាក់ដូចជានិយាយថា មានហេតុផលតិចតួចដើម្បីចងភ្ជាប់ទៅនឹងស្រោមជើងវែងៗ ហើយក្រដាសខ្ចប់អំណោយឆ្នូតៗបានរំឭកខ្ញុំថា ព្រឹកនោះនឹងមិននាំមកនូវសំឡេងរំភើបរីករាយរបស់កូនៗឡើយ ។

ឆ្នាំនេះកូនពៅរបស់យើងបានទៅមហាវិទ្យាល័យ ហើយផ្ទះរបស់យើងមានអារម្មណ៍ថា កណ្ដោចកណ្ដែង និងស្ងប់ស្ងាត់ ។ ខ្ញុំបានជ្រើសយកតែគ្រឿងតុបតែងដែលពុំមែនជារូបតាណូអែលដើម្បីដាក់តាំង ហើយបានដាក់អ្វីៗផ្សេងទៀតទៅក្នុងប្រអប់របស់វាវិញ ។

ខ្ញុំបានតុបតែងដើមគ្រីស្ទម៉ាស់នោះតែម្នាក់ឯង ដោយសារស្វាមីរបស់ខ្ញុំពុំនៅផ្ទះទេ ។ កូនប្រសារស្រីរបស់ខ្ញុំបានបង្ហោះរូបភាពចៅៗរបស់ខ្ញុំព្យួរគ្រឿងតុបតែងនៅលើដើមគ្រីស្ទម៉ាស់របស់ពួកគេនៅលើអ៊ិនធើរណែត ហើយចិត្តរបស់ខ្ញុំចង់ត្រឡប់ទៅរកអ្វីៗដូចកាលពីដើមវិញ ។ ខ្ញុំឆ្ងល់ថា ហេតុអ្វីពេលវេលាវាដើរលឿនយ៉ាងនេះ ។ ហើយកូនៗរបស់ខ្ញុំពិតជាធំលឿនណាស់ ? ដោយភ្លឹកភ្លាំងក្នុងគំនិត នោះខ្ញុំបានមើលពន្លឺភ្លើងអំពូលនៅក្នុងដៃរបស់ខ្ញុំ ។ វាជាអំពូលភ្លើងពណ៌ក្រហមមួយ ។



ខ្ញុំបានពិនិត្យមើលពណ៌នោះ វាក្រហមខ្លាំងណាស់ ។ គឺក្រហមជាំតែម្ដង ។ ខ្ញុំបានមើលជុំវិញនូវភាពសាមញ្ញនៃអ្វីដែលនៅសល់ដើម្បីតុបតែងទៀត ៖ ប្រសូតកម្មពីរបី ស្នូកមួយដែលធ្វើពីឈើកាវ៉េម និងអក្សរតុបតែងដែលសរសេរថា បុណ្យណូអែល ជាអក្សរពណ៌មាស ។ ខ្ញុំបានយំ ។ អំពូលភ្លើងនោះ៖ ពណ៌ក្រហម—ក្រហមដូចជាព្រះលោហិតដ៏ធួននៃព្រះអង្គសង្គ្រោះ ។

ខ្ញុំបានគិតជានិច្ចអំពីរបៀបដែលខ្ញុំតុបតែង, ការធ្វើនំជារាងផ្សេងៗ និងចម្រៀងជាក្រុមរបស់កូនៗនៅព្រឹកថ្ងៃបុណ្យគ្រីស្ទម៉ាស់ជាមួយអ្វីដែលធ្វើឲ្យខ្ញុំរីករាយនៅរដូវបុណ្យគ្រីស្ទម៉ាស់ ។ ខ្ញុំបានគិតអំពីកូនៗរបស់ខ្ញុំ និងក្រុមគ្រួសារអស់កល្បជានិច្ចរបស់ពួកគេ ។ ខ្ញុំបានគិតអំពីអំណោយទាំងអស់ដែលខ្ញុំមាននៅក្នុងគ្រួសារខ្ញុំ និងអំណោយដែលពួកគេមាននៅក្នុងគ្រួសាររបស់ពួកគេ ។ ខ្ញុំបានគិតអំពីទារកដែលដេកនៅក្នុងស្នូកអាចធ្វើឲ្យរឿងទាំងនេះកើតឡើងបាន ។ អារម្មណ៍នៃភាពកក់ក្ដៅបានផុសឡើងក្នុងចិត្តខ្ញុំ នៅពេលខ្ញុំបានសញ្ជឹងគិតអំពីអំណោយនៃព្រះអង្គសង្គ្រោះ—ពុំមែនតែសម្រាប់ខ្ញុំនោះទេ ប៉ុន្តែសម្រាប់មនុស្សលោកទាំងអស់គ្នាផងដែរ ។

« តែទេវតាប្រាប់ថា កុំខ្លាចអី មើល ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ពីសេចក្ដីអំណរយ៉ាងអស្ចារ្យ ដែលសម្រាប់ *បណ្ដាជនទាំងអស់គ្នា* » ( លូកា ២:១០ ការគូសបញ្ជាក់ត្រូវបានបន្ថែម ) ។

នៅពេលខ្ញុំបន្តតុបតែងដើមគ្រីស្ទម៉ាស់ នោះខ្ញុំបានគិតអំពីការប្រសូត និងព្រះជន្មដ៏រាបសារបស់ព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់បានយាងមកដើម្បីជួសជុលការខូចខាត ស្ដាបនាអ្នកដែលគេគាបសង្កត់ លួងលោមចិត្តអ្នកឯកា នាំភាពសុខសាន្តមកក្នុងគ្រាដែលមិនល្អឥតខ្ចោះ និងប្រទានក្ដីអាណិតអាសូរដល់អ្នកដែលរងទុក្ខ ។ ទ្រង់បានប្រសូតមក ហើយសុគត ដើម្បីឲ្យយើងអាចរស់នៅជាមួយទ្រង់នៅក្នុងនគររបស់ព្រះវរបិតាម្ដងទៀត ។ ទ្រង់បានយាងមកដើម្បីឲ្យមនុស្សអាចស្គាល់អំពីសុភមង្គលពិតប្រាកដ ។ ដួងចិត្តរបស់ខ្ញុំបានរីករាយ ហើយខ្ញុំបានរកឃើញអំណរនៅក្នុងព្រះគ្រីស្ទដោយសារព្រះគ្រីស្ទគឺជាបុណ្យគ្រីស្ទម៉ាស់ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋអ៊ីដាហូ ស.រ.អា. ។*

រូបភាពពីគំរូ GETTY IMAGES

# រីកចម្រើនមកពីការបម្រើ

ដោយ ប៉ូ នៀន ( ហ្វេលីព ) ឆាវ និង ពេត្រា ឆាវ

*យើងមានអារម្មណ៍រំភើបដែលសមាជិកថ្មីក្នុងសាខាយើងគួរតែត្រូវបានផ្ដល់ការហៅបម្រើភ្លាមៗ ដើម្បីឲ្យពួកគេអាចរីកចម្រើនតាមរយៈការបម្រើ ។*



*សាខាកៅសៀងទីប្រាំពីរនៅឯព្រះវិហារបរិសុទ្ធតៃប៉ិ តៃវ៉ាន់ នៅក្នុងខែ ធ្នូ ឆ្នាំ ២០០១ ។*

នៅក្នុងឆ្នាំ ២០០០ យើងត្រូវបានហៅឲ្យបម្រើជាប្រធានសាខា និងប្រធានថ្នាក់អង្គការបឋមសិក្សានៃអង្គភាពតូចបំផុត មួយនៅក្នុងស្ដេកកៅសៀង តៃវ៉ាន់ ។ យើងមានសមាជិកប្រហែលជា ២០ នាក់ចូលរួមការប្រជុំសាក្រាម៉ង់ រួមទាំងគ្រួសារក្មេងវ័យរបស់យើងផងដែរ ដែលមានអែលឌើរសកម្មចំនួនបួននាក់ និងពួកអ្នកផ្សព្វផ្សាយសាសនា ។ ក្រោយមកយើងបានបញ្ជូនអែលឌើរពីររូបឲ្យទៅបម្រើបេសកកម្ម ដោយទុកចិត្តថា ព្រះអម្ចាស់នឹងធ្វើឲ្យសាខារបស់យើងចម្រើនឡើង ។

យើងបានធ្វើការជាមួយសាខារបស់យើង យើងបានចងចាំការទូន្មានរបស់ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ១៩១០–២០០៨ ) ដែលថា រាល់អ្នកប្រែចិត្តជឿត្រូវការ ៖ « មិត្តភក្តិ ការទទួលខុសត្រូវ និងការចិញ្ចឹមបីបាច់ដោយ ‹ ព្រះបន្ទូលដ៏ល្អនៃព្រះ › » ។[1] យើងមានអារម្មណ៍រំភើបដែលសមាជិកថ្មីរបស់យើងគួរតែត្រូវបានផ្ដល់ការហៅបម្រើភ្លាមៗ ដើម្បីឲ្យពួកគេអាចរីកចម្រើនតាមរយៈការបម្រើ ។ ពួកអ្នកផ្សព្វផ្សាយសាសនាបានណែនាំយើងឲ្យស្គាល់សាសនាគន់ការី ហើយនៅក្នុងរយៈពេលពីរសប្ដាហ៍នៃបុណ្យជ្រមុជទឹកនីមួយៗរបស់ពួកគេ នោះពួកគេបានទទួលការហៅបម្រើ ។ ពួកគេបានបង្កើនមិត្តភាពនៅពេលពួកគេបានបម្រើជាមួយសមាជិកដទៃទៀត ។

ក្នុងអំឡុងពេលមួយខែ បងប្អូនប្រុសដែលទើបតែបានទទួលបុណ្យជ្រមុជទឹកបានទទួលបព្វជិតភាពអើរ៉ុន ហើយពួកគាត់ម្នាក់ៗបានប្រសិទ្ធពរ និងចែកនំប៉័ងនឹងទឹក ។ យើងក៏រៀបចំពួកគេដើម្បីទទួលបព្វជិតភាពមិលគីស្សាដែកនៅសន្និសីទស្ដេកបន្ទាប់ផងដែរ ។

ពួកអែលឌើរថ្មីត្រូវបានបង្រៀនអំពីរបៀបធ្វើពិធីបរិសុទ្ធនានា ហើយបន្ទាប់មកពួកអែលឌើរទាំងនេះបានបង្រៀនពួកអែលឌើរថ្មីៗបន្តទៀត ។ យើងជឿជាក់លើការរៀនសូត្រតាមរយៈការអនុវត្ត និងជឿលើការបន្តការរៀនសូត្រតាមរយៈការបង្រៀន ។ សមាជិកសាខាមានការទទួលខុសត្រូវដើម្បីធ្វើជាគំរូ និងអ្នកផ្ដល់ប្រឹក្សា បង្រៀន និងបំពាក់បំប៉ន ហើយគាំទ្រ និងជួយជ្រោមជ្រែងគ្នាទៅវិញទៅមក ។

យើងបានប្រើគ្រូបង្រៀនតាមផ្ទះ និងគ្រូបង្រៀនសួរសុខទុក្ខ, រាត្រីជួបជុំក្រុមគ្រួសារ សកម្មភាពវួដ និងការធ្វើអាហារបរិភោគជុំគ្នាដើម្បីបង្កើនភាពស្និទស្នាលជាមួយអ្នកប្រែចិត្តជឿថ្មី ។ ពួកគេត្រូវបានចិញ្ចឹមបីបាច់ដោយព្រះបន្ទូលនៃព្រះ តាមរយៈថ្ងៃអាទិត្យ និងការណែនាំអំពីសាសនានៅថ្ងៃនានាក្នុងសប្ដាហ៍ ។ ថ្នាក់វិទ្យាស្ថានបានកើនសិស្សពី ២ ទៅ ២៥ នាក់ ។ ដើម្បីបន្តចិញ្ចឹមបីបាច់ដល់សាខាតូចរបស់យើង នោះយើងបានចូលរួម និងបម្រើនៅក្នុងព្រះវិហារបរិសុទ្ធ តៃប៉ិ តៃវ៉ាន់ រៀងរាល់ខែ—ដែលត្រូវជិះឡានក្រុងទាំងទៅទាំងមករយៈពេល ១០ ម៉ោង ។ ជាទូទៅ ស្ដេករបស់យើងមានការលំបាកដែលអត់មានសមាជិកច្រើនដើម្បីជិះឡានក្រុងទីពីរឲ្យពេញទៅព្រះវិហារបរិសុទ្ធឡើយ ។ សាខារបស់យើងបានរីកចម្រើន ហើយក្រុមគ្រួសារនានាបានរៀបចំខ្លួនដើម្បីទទួលពរជ័យព្រះវិហារបរិសុទ្ធរបស់ពួកគេ យើងបានដាក់គោលដៅដើម្បីឲ្យមានសមាជិកជិះឲ្យពេញឡានក្រុងរបស់យើងផ្ទាល់ ។ ការធ្វើដំណើរពីរដងនៅក្នុងឆ្នាំដំបូង ដោយសមាជិកផ្សេងទៀតនៅក្នុងស្ដេកជិះឡានក្រុងមួយទៅព្រះវិហារបរិសុទ្ធ ហើយសាខាដ៏តូចរបស់យើងបានជិះឡានក្រុងទីពីរ ។ មិនយូរប៉ុន្មានក្រោយមក ខាងស្ដេកបានសួមឲ្យវួដនីមួយៗមានសមាជិកជិះឲ្យពេញឡានក្រុងមួយដើម្បីទៅព្រះវិហារបរិសុទ្ធ យ៉ាងហោចណាស់ម្ដងក្នុងមួយឆ្នាំ ។

នៅឆ្នាំទីពីរ ការថែរក្សាអ្នកប្រែចិត្តជឿរបស់យើងបានកើនឡើងពី ៣០ ភាគរយទៅជាង ៩០ភាគរយ ហើយការប្រជុំសាក្រាម៉ង់របស់យើងបានកើនដល់ប្រហែលជា ១០០ នាក់ រួមមានទាំងពួកអែលឌើរដែលសកម្មចំនួន ២៥ នាក់ផងដែរ ។ សាខារបស់យើងបានក្លាយជាវួដ ហើយអគារចាស់របស់យើងត្រូវបានកែថ្មីឲ្យទៅជាសាលាជំនុំថ្មី ។

សាខាដែលតូចបំផុតបានប្រែទៅជាវួដដ៏ខ្លាំងបំផុតនៅក្នុងស្ដេក ដោយសារអ្នកប្រែចិត្តជឿគ្រប់រូបបានទទួលពរដោយមានមិត្តភក្តិ ការហៅបម្រើ និងការចិញ្ចឹមបីបាច់ដោយព្រះបន្ទូលនៃព្រះ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*

កំណត់ចំណាំ

1. ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី « Converts and Young Men » *Ensign* ខែ ឧសភា ឆ្នាំ ១៩៩៧ ទំព័រ ៤៧ ។

# បុណ្យគ្រីស្ទម៉ាស់មួយដ៏ផ្អែមល្ហែម

គ្រួសាររបស់ខ្ញុំបានធ្វើឲ្យបុណ្យគ្រីស្ទម៉ាស់ក្លាយជាឱកាសមួយដ៏គួរឲ្យចងចាំយ៉ាងយូរអង្វែងតាមដែលខ្ញុំអាចចាំបាន ។ ពេលខ្ញុំចេញទៅបម្រើបេសកកម្ម ប្រេស៊ីល ផតតូ អាលើហ្គ្រើ ភាគខាងត្បូង នោះខ្ញុំពុំដឹងថា តើវាលំបាកប៉ុណ្ណាសម្រាប់ខ្ញុំ ដើម្បីចំណាយពេលនៃបុណ្យគ្រីស្ទម៉ាស់នៅឆ្ងាយពីពួកគេនៅគ្រាដំបូងនោះទេ ។

នៅអំឡុងពេលបុណ្យគ្រីស្ទម៉ាស់គ្រាដំបូងរបស់ខ្ញុំនៅក្នុងតំបន់បេសកកម្ម នោះ ខ្ញុំមានបំណងចង់នៅជាមួយគ្រួសារខ្ញុំ *ប៉ុន្តែដៃគូខ្ញុំ* និងខ្ញុំនៅឯកោតែពីរនាក់ប៉ុណ្ណោះ ។ អារម្មណ៍មួយនៃការអាណិតខ្លួនឯង និងភាពក្រៀមក្រំបានកើតមានចំពោះខ្ញុំ ។

នៅយប់មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ គ្រួសារដ៏គួរឲ្យស្រឡាញ់មួយបានអញ្ជើញដៃគូខ្ញុំ និងខ្ញុំទៅបរិភោគអាហារពេលល្ងាច ។ យើងមានឱកាសរីករាយជាមួយគ្នានាល្ងាចនោះ ប៉ុន្តែសុភមង្គលរបស់គ្រួសារនេះបានរំឭកខ្ញុំថា ខ្ញុំបាននៅឆ្ងាយពីគ្រួសាររបស់ខ្ញុំផ្ទាល់ ។ យប់នោះពេលយើងបានត្រឡប់ទៅផ្ទះវិញ ខ្ញុំបានព្យាយាមដេក ហើយបំភ្លេចថា នៅថ្ងៃបន្ទាប់គឺជាថ្ងៃបុណ្យគ្រីស្ទម៉ាស់ ។ ជាគ្រាដំបូងនៅក្នុងជីវិតខ្ញុំ ខ្ញុំបានមានអារម្មណ៍ធូរស្បើយ នៅពេលបុណ្យគ្រីស្ទម៉ាស់បានចប់ទៅ ។

មួយឆ្នាំក្រោយមក ខ្ញុំបានគិតអំពីបុណ្យគ្រីស្ទម៉ាស់ពីឆ្នាំមុននោះ ហើយបានគិតអំពីអ្វីដែលខ្ញុំអាចធ្វើដើម្បីមានបុណ្យគ្រីស្ទម៉ាស់ដ៏ប្រសើរមួយនៅក្នុងតំបន់បេសកកម្ម ។ ខ្ញុំបានដឹងថា អារម្មណ៍នៃភាពកើតទុក្ខដែលខ្ញុំមានកាលពីឆ្នាំមុននោះ កើតឡើងមកពីការផ្ដោតចិត្តតែលើខ្លួនខ្ញុំ ដោយមិនបានផ្ដោតលើព្រះអង្គសង្គ្រោះឡើយ ។ ខ្ញុំក៏បានដឹងថា បុណ្យគ្រីស្ទម៉ាស់គឺជាគ្រាដើម្បីចងចាំការប្រសូតរបស់



*ដើម្បីមានបុណ្យគ្រីស្ទម៉ាស់ដ៏ល្អប្រសើរនៅក្នុងតំបន់បេសកកម្ម នោះដៃគូខ្ញុំ និងខ្ញុំបានសម្រេចចិត្តទិញស្ករគ្រាប់ជូនទៅមនុស្សម្នាដែលយើងជួបនៅថ្ងៃបុណ្យគ្រីស្ទម៉ាស់ ។*

ព្រះអង្គសង្គ្រោះ ហើយថា ខ្ញុំគួរតែរីករាយបម្រើទ្រង់ក្នុងនាមជាអ្នកតំណាងឲ្យទ្រង់ ។

ខ្ញុំបាននិយាយជាមួយដៃគូរបស់ខ្ញុំ យើងបានសម្រេចចិត្តទិញស្ករគ្រាប់ជូនសមាជិក សាសនាគន់ការី កុមារ និងនរណាផ្សេងទៀតដែលយើងជួបនៅថ្ងៃបុណ្យគ្រីស្ទម៉ាស់នោះ ។ យើងក៏បានហាត់សមទំនុកតម្កើងបុណ្យគ្រីស្ទម៉ាស់ដើម្បីច្រៀងផងដែរ ។ ដួងចិត្តរបស់ខ្ញុំមានអំណរនៅថ្ងៃបុណ្យគ្រីស្ទម៉ាស់ នៅពេលយើងបានជួបមនុស្សនានា បានច្រៀងទំនុកតម្កើង ហើយបានចែកស្ករគ្រាប់នោះ ។

នៅល្ងាចនោះពេលយើងធ្វើដំណើរទៅផ្ទះវិញ យើងបានជួបបុរសចំណាស់ម្នាក់អង្គុយនៅលើចិញ្ចើមថ្នល់ ។ យើងបានសួរគាត់ ប្រសិនបើគាត់បានទទួលអំណោយបុណ្យគ្រីស្ទម៉ាស់នៅថ្ងៃនោះដែរឬទេ ។ គាត់បានឆ្លើយថា បាទបានហើយ—គាត់បាននិយាយជាមួយកូនៗរបស់គាត់ដែលរស់នៅឆ្ងាយតាមទូរសព្ទ ។

យើងបាននិយាយថា « ពួកខ្ញុំមានអំណោយមួយបន្ថែមទៀតជូនលោកអ៊ំ » ។ យើងបានឲ្យស្ករគ្រាប់គាត់ ។

គាត់បាននិយាយថា « ស្ករគ្រាប់នេះពុំគ្រាន់តែផ្អែមត្រឹមមាត់របស់អ៊ំឡើយ ប៉ុន្តែវាក៏ផ្អែមដល់ព្រលឹងរបស់អ៊ំផងដែរ » ។

ខ្ញុំមានបុណ្យគ្រីស្ទម៉ាស់ដ៏មិនគួរឲ្យរីករាយមួយនៅក្នុងបេសកកម្មរបស់ខ្ញុំ ដោយសារខ្ញុំផ្ដោតចិត្តតែលើខ្លួនខ្ញុំ ។ ខ្ញុំក៏មានបុណ្យគ្រីស្ទម៉ាស់ដ៏រីករាយបំផុតនៅពេលខ្ញុំផ្ដោតទៅលើព្រះអង្គសង្គ្រោះជំនួសវិញ ។ ខ្ញុំដឹងថា នៅពេលយើងផ្ដោតចិត្តទុកដាក់ទៅលើទ្រង់ នោះទ្រង់នឹងនាំភាពផ្អែមល្ហែមមកកាន់វិញ្ញាណរបស់យើងនៅថ្ងៃបុណ្យគ្រីស្ទម៉ាស់ និងគ្រប់ថ្ងៃទាំងអស់នៅក្នុងឆ្នាំនេះ ។ ■

**វីលសុន ខូរៀ ដូស សានតូស ទីក្រុង ភើណាមប៊ូកូ ប្រទេសប្រេស៊ីល**

រចនារូបភាពដោយ អិនយ៉ា ថត



*ខ្ញុំទទួលអារម្មណ៍ជំរុញចិត្តមួយដើម្បីជួបបុរសនេះ ។ ខ្ញុំបានទៅជួបគាត់ ហើយបានចាប់ដៃគាត់ ហើយសួរឈ្មោះរបស់គាត់ ។*

# « អ្នកបានធ្វើវាដល់យើងដែរ »

គ្រួសាររបស់យើងមានប្រពៃណីបុណ្យគ្រីស្ទម៉ាស់មួយ គឺការជូនអំណោយជាកញ្ចប់អាហារ, ស្រោមដៃ, មួក និងរបស់ប្រើប្រាស់ចាំបាច់ផ្សេងៗទៀតដល់អ្នកដែលខ្វះខាត ។ នៅក្នុងឆ្នាំ ២០១៦ យប់មុនបុណ្យគ្រីស្ទម៉ាស់មានអាកាសធាតុត្រជាក់ណាស់នៅតំបន់រដ្ឋកាលីហ្វូញ៉ា ស.រ.អា. ជាកន្លែងដែលយើងរស់នៅ ។ យើងបានពាក់អាវជាច្រើនជាន់ ប៉ុន្តែយើងនៅតែរងា !

ពេលយើងបើកឡានទៅក្បែរឧទ្យានមួយនៅក្បែរផ្ទះរបស់យើង ជាកន្លែងដែលមនុស្សជាច្រើនគ្មានផ្ទះរស់នៅ នោះយើងបានឃើញបុរសម្នាក់ប្រច្រៀតជ្រកនៅក្រោមដំបូលចំណតឡានក្រុងមួយដោយរុំខ្លួនគាត់នឹងភួយកញ្ចាស់មួយ ។ ដេននីស ស្វាមីរបស់ខ្ញុំ បានឈប់ឡាន ហើយយកចូណាថាន់ កូនប្រុសរបស់យើងបានទៅជាមួយគាត់ ដើម្បីជូនអំណោយជាកញ្ចប់របស់យើងដល់គាត់ ។ អែបប៊ី កូនស្រីរបស់យើង និងខ្ញុំបាននៅក្នុងឡាន ហើយមើលពួកគេ ។

បុរសនោះបានងើយក្បាលគាត់ឡើងលើ នៅពេលដេននីសបានហុចកញ្ចប់អំណោយនោះជូនគាត់ ។ បុរសនោះបានញញឹមយ៉ាងរីករាយ ។ ពួកគេបានចាប់ដៃគ្នា ហើយចាប់ផ្ដើមនិយាយគ្នា ។ នេះពុំមែនជារឿងធម្មតាទេ ដោយសារជាធម្មតាគ្មានការសន្ទនាគ្នាបែបនោះទេ ។

បន្ទាប់ពីបួនប្រាំនាទីក្រោយមក ដេននីសបានត្រឡប់មកកាន់ឡានវិញ ហើយបើកគូថឡាន ។

ខ្ញុំបានសួរ « យ៉ាងម៉េចហើយបង ? »

គាត់បានឆ្លើយថា « មិនអីទេ ។ បងនឹងឲ្យអាវរងាទៅគាត់មួយ ។ គាត់ត្រូវការវាជាងបងត្រូវការទៅទៀត » ។

ខ្ញុំពុំបាននិយាយអ្វីទេ ។ នោះគឺជាអាវរងាដ៏ស្អាតដែលដេននីសពាក់វាបានពីរបីដងប៉ុណ្ណោះ ! ដេននីសបានត្រឡប់ទៅរកបុរសនោះវិញ ហើយបានជួយពាក់អាវរងានោះឲ្យគាត់ ។ បុរសនោះបានញញឹមដោយរីករាយ ។ ដេននីស និងបុរសនោះបានបន្តនិយាយគ្នាទៀត ។

ខ្ញុំទទួលអារម្មណ៍ជំរុញចិត្តមួយថា ចង់ជួបបុរសនេះ ។ ខ្ញុំបានបើកទ្វារឡាន ហើយអែបប៊ីបានដើរតាមខ្ញុំ ។ ដេននីសបានញញឹមនៅពេលយើងដើរសំដៅទៅរកពួកគាត់ ហើយគាត់បានណែនាំពួកយើងឲ្យស្គាល់បុរសនោះ ។ ខ្ញុំបានឈោងដៃទៅចាប់ដៃគាត់ ហើយសួរឈ្មោះរបស់គាត់ ។

គាត់បានចាប់ដៃខ្ញុំដោយស្នាមញញឹមដ៏កក់ក្ដៅ ហើយតបថា « យេស៊ូវ » ។

គ្រួសាររបស់យើងបានបន្តនិយាយជាមួយគាត់ ប៉ុន្តែចាប់តាំងពីពេលនោះមក ខ្ញុំពុំបានឮដំណឹងអ្វីច្រើនពីបុរសម្នាក់នោះឡើយ ។ ខ្ញុំបន្តគិតអំពីសារៈសំខាន់នៃឈ្មោះដ៏ពិរោះរបស់បុរសនេះ ៖ យេស៊ូវ—គឺជាព្រះនាមនៃព្រះអង្គសង្គ្រោះ ។ នៅគ្រានោះ ខ្ញុំត្រូវបានរំឭកឲ្យចាំអំពីការបង្រៀនរបស់ព្រះអង្គសង្គ្រោះ ៖ « ដែលអ្នករាល់គ្នាបានធ្វើការទាំងនោះ ដល់អ្នកតូចបំផុតក្នុងពួកបងប្អូនយើងនេះ នោះឈ្មោះថា បានធ្វើដល់យើងដែរ » ( ម៉ាថាយ ២៥:៤០ ) ។ បទពិសោធន៍នោះបានផ្លាស់ប្ដូរខ្ញុំជារៀងរហូត ។ ■

**ស្យានណាន់ ណែត៍ រដ្ឋ កាលីហ្វ័រញ៉ា ស.រ.អា.**

គំនូរដោយ អេលែន ហ្គាន់ស៍

**ខ្ញុំ** *បានខ្ចប់ឈើច្រត់របស់ខ្ញុំ ហើយផ្ដល់វាជាអំណោយបុណ្យគ្រីស្ទម៉ាស់ឲ្យបងប្រុសម្នាក់នេះដែលបានផ្ដល់ការប្រសិទ្ធពរដល់ខ្ញុំ ។*



រចនារូបភាពដោយ ខារ៉ូលីន វីបបើត

# យើងទាំងពីរនាក់បានទទួលពរ

ភ្នែករបស់ខ្ញុំបានខ្វាក់ពាក់កណ្ដាលមើលមិនសូវឃើញទេ នៅពេលឡានដឹកទំនិញមួយបានបុកខ្ញុំធ្វើឲ្យខ្ញុំខ្វាក់ចេញពីកង់ ។ ប្រហែលជាបួនឆ្នាំក្រោយមក អំឡុងពេលរដូវបុណ្យគ្រីស្ទម៉ាស់ឆ្នាំ ២០១១ ខ្ញុំបានទទួលអារម្មណ៍បំផុសគំនិតឲ្យសូមបងប្រុសម្នាក់ដែលខ្ញុំស្គាល់នៅក្នុងវួដចាស់របស់ខ្ញុំ ឲ្យប្រសិទ្ធពរបព្វជិតភាពដល់ខ្ញុំ ។ ខ្ញុំបានឃើញបងប្រុសម្នាក់នេះយូរៗម្ដង ដូច្នេះខ្ញុំពុំយល់អំពីមូលហេតុដែលខ្ញុំគួរតែសូមគាត់នោះទេ ។ ខ្ញុំបានដឹងថា មានអ្នកកាន់បព្វជិតភាពដែលសក្ដិសមដទៃទៀតដែលខ្ញុំអាចសូមការប្រសិទ្ធពរពីគេជំនួសឲ្យការសុំពីគាត់បាន ។

នៅប៉ុន្មានសប្ដាហ៍ក្រោយមក អារម្មណ៍ដែលខ្ញុំត្រូវការការប្រសិទ្ធពរនោះបានមានកាន់តែខ្លាំងឡើង ។ ខ្ញុំកំពុងបម្រើជាអ្នកធ្វើការនៅក្នុងព្រះវិហារបរិសុទ្ធនៅព្រះវិហារបរិសុទ្ធ ហ្វ្រេងហ្វើត អាល្លឺម៉ង់ ដូច្នេះខ្ញុំបានសម្រេចចិត្តសូមឲ្យបងប្រុសម្នាក់នៅទីនោះផ្ដល់ការប្រសិទ្ធពរឲ្យខ្ញុំ ។

បន្ទាប់ពីខ្ញុំបានធ្វើការសម្រេចចិត្តនេះ បងប្រុសដែលខ្ញុំបានទទួលការបំផុសគំនិតឲ្យសូមការប្រសិទ្ធពរនោះបានចូលមកព្រះវិហារបរិសុទ្ធ ។ រំពេចនោះខ្ញុំបានដឹងថា នេះពុំមែនជារឿងចៃដន្យទេ—គឺប្រាកដណាស់ព្រះវរបិតាសួគ៌សព្វព្រះទ័យឲ្យខ្ញុំសូមការប្រសិទ្ធពរពីបងប្រុសនោះ ។ ខ្ញុំបានតាំងចិត្តក្លាហាន ហើយនិយាយជាមួយគាត់ បន្ទាប់ពីគាត់បញ្ចប់វគ្គរបស់គាត់ ។ គាត់បានយល់ព្រម ។

ក្រោយមក ខ្ញុំបានពន្យល់ថា ខ្ញុំមិនបានដឹងថាហេតុអ្វីនោះទេ ប៉ុន្តែខ្ញុំទទួលអារម្មណ៍ថា ខ្ញុំត្រូវការការប្រសិទ្ធពរពីគាត់ ។ គាត់បាននិយាយថា គាត់រីករាយនឹងផ្ដល់ការប្រសិទ្ធពរឲ្យ ។ គាត់បានអញ្ជើញបងប្អូនប្រុសផ្សេងទៀតទៅក្នុងបន្ទប់ បន្ទាប់មកចាប់ផ្ដើមប្រសិទ្ធពរឲ្យខ្ញុំ ។ នៅពេលគាត់ប្រសិទ្ធពរចប់ខ្ញុំមានអារម្មណ៍ភាន់ភាំង ។ ការប្រសិទ្ធពរនោះល្អ ប៉ុន្តែគ្មានអ្វីមួយដែលជាក់លាក់សោះ ។

បន្ទាប់មកខ្ញុំបានបើកភ្នែករបស់ខ្ញុំ ។

ពេលខ្ញុំបើកភ្នែកឡើង ខ្ញុំអាចឃើញបន្ទប់ទាំងមូលឡើងច្បាស់ទែងតែម្ដង ។ ខ្ញុំពុំអាចជឿវាបានឡើយ ! ខ្ញុំបានសួរបងប្រុសនោះ តើគាត់ដឹងពីមូលហេតុដែលគាត់គឺជាមនុស្សម្នាក់គត់ដែលត្រូវផ្ដល់ការប្រសិទ្ធពរនេះដល់ខ្ញុំដែរឬទេ ។ ការឆ្លើយតបរបស់គាត់ធ្វើឲ្យខ្ញុំរាបសា ។

គាត់បាននិយាយថា « ខ្ញុំគិតថា ការប្រសិទ្ធពរពុំគ្រាន់តែសម្រាប់អ្នកប៉ុណ្ណោះទេ ។ វាក៏សម្រាប់ខ្ញុំផងដែរ ។ ខ្ញុំនឹងផ្ដល់ការប្រសិទ្ធពរឲ្យក្មួយស្រីខ្ញុំនៅថ្ងៃស្អែក ដោយសារគាត់នឹងទទួលបុណ្យជ្រមុជទឹក ។ គ្រួសារយើងពុំសកម្មនៅក្នុងសាសនាចក្រទេ ហើយនាងគឺជាសមាជិកគ្រួសារដែលទទួលបុណ្យជ្រមុជទឹកដំបូងគេក្នុងរយៈពេលស្ទើរតែជិត ២០ ឆ្នាំមកនេះ ។ សមាជិកគ្រួសារយើងជាច្រើននាក់នឹងចូលរួមពិធីបុណ្យជ្រមុជទឹកនេះ ហើយខ្ញុំពុំប្រាកដថា សេចក្ដីជំនឿរបស់ខ្ញុំមានខ្លាំងគ្រប់គ្រាន់ដើម្បីផ្ដល់ការប្រសិទ្ធពរនោះទេ ។ ឥឡូវនេះ ខ្ញុំដឹងថា ខ្ញុំអាចធ្វើវាបាន » ។

នៅថ្ងៃបន្ទាប់មក គំហើញរបស់ខ្ញុំបានប្រសើរឡើងល្អមដែលខ្ញុំពុំត្រូវការប្រើឈើច្រត់របស់ខ្ញុំទៀតឡើយ ។ ខ្ញុំបានខ្ចប់វា ហើយផ្ដល់វាជាអំណោយបុណ្យគ្រីស្ទម៉ាស់ឲ្យបងប្រុសម្នាក់នេះជាមួយនឹងសំបុត្រមួយ ។ ខ្ញុំបានសរសេរថា « ខ្ញុំដឹងថា នេះពុំមែនជាដំបងរបស់ម៉ូសេទេ ប៉ុន្តែខ្ញុំសង្ឃឹមថា វារំឭកអ្នកអំពីអំណាចបព្វជិតភាពដែលអ្នកបានកាន់ » ។

ព្រះវរបិតាសួគ៌ស្រឡាញ់យើង ហើយសព្វព្រះទ័យប្រទានពរដល់យើង ។ ពរជ័យនៅបុណ្យគ្រីស្ទម៉ាស់នេះពុំគ្រាន់ស្ដារគំហើញរបស់ខ្ញុំឡើងវិញទេ វាថែមទាំងផ្ដល់ទំនុកចិត្តដល់អ្នកកាន់បព្វជិតភាពដ៏រាបសាម្នាក់នៅក្នុងការបម្រើបព្វជិតភាពរបស់គាត់ ។ ■

**អាណា ហ្វីងហ្គើល ទីក្រុងហេសេ ប្រទេសអាល្លឺម៉ង់**

# ព្រះគម្ពីរមរមន ៖ អំណោយដ៏ពិសេស

នៅយប់មុនថ្ងៃបុណ្យគ្រីស្ទម៉ាស់ឆ្នាំ ២០១៦ អំឡុងពេលដែលស្វាមីខ្ញុំ និងខ្ញុំកំពុងបម្រើជាអ្នកផ្សព្វផ្សាយសាសនាសម្រាប់ព្រះវិហារបរិសុទ្ធនៅព្រះវិហារបរិសុទ្ធ ម៉ានីល ហ្វីលីពីន នោះខ្ញុំចង់ឲ្យព្រះគម្ពីរមរមនមួយក្បាលទៅនរណាម្នាក់ ។ នៅក្នុងគម្របខាងមុខនៃគម្ពីរនេះ ខ្ញុំបានសរសេរទីបន្ទាល់របស់ខ្ញុំ ហើយដាក់បញ្ចូលកាតមួយនៃរូបព្រះវិហារបរិសុទ្ធម៉ានីល ដែលមានព័ត៌មានស្ដីពីទីកន្លែងដើម្បីរៀនបន្ថែមទៀតអំពីសាសនាចក្រ ។ បន្ទាប់មក ខ្ញុំបានលុតជង្គង់អធិស្ឋាន ហើយទូលសូមព្រះអម្ចាស់ឲ្យដឹកនាំខ្ញុំទៅជួបនរណាម្នាក់ដែលទ្រង់បានរៀបចំ ។

ខ្ញុំបានចេញពីផ្ទះរបស់យើង ហើយឆ្លងថ្នល់ ។ មានបុរសពីរនាក់បានមកលេងសន្តិសុខម្នាក់ ដែលយាមនៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនាក្បែរនោះ ។ គាត់បានស្រែកថា « រីករាយបុណ្យគ្រីស្ទម៉ាស់ ! » ខ្ញុំទទួលការបំផុសគំនិតឲ្យដើរទៅរកពួកគេ ។

បន្ទាប់ពីខ្ញុំបានណែនាំខ្លួនឲ្យពួកគេស្គាល់ហើយ ខ្ញុំបានដឹងថា បុរសម្នាក់គឺជាអ្នកថែសួននៅមជ្ឈមណ្ឌលបំពាក់បំប៉នអ្នកផ្សព្វផ្សាយសាសនា ហើយបុរសម្នាក់ទៀតគឺជាកសិករ ។ ខ្ញុំដឹងថា ពួកគេទាំងពីរនាក់ជាសមាជិកសាសនាចក្រ ។

ខ្ញុំបានសួរ ប្រសិនបើពួកគេស្គាល់នរណាម្នាក់ដែលចាប់អារម្មណ៍ទទួលយកអំណោយបុណ្យគ្រីស្ទម៉ាស់មួយជាព្រះគម្ពីរមរមនមួយក្បាលដែរឬទេ ។ បុរសជាកសិករបានមើលដោយភ្ញាក់ផ្អើល ។ គាត់បាននិយាយថា គាត់មានមិត្តម្នាក់ដែលនឹងមកលេងបរិវេណព្រះវិហារបរិសុទ្ធជាមួយគាត់នៅពេលបន្តិចទៀត ។ គាត់ចង់ឲ្យព្រះគម្ពីរមរមនមួយក្បាលទៅមិត្តរបស់គាត់ ប៉ុន្តែគាត់ពុំអាចរកវាបាន ។ ដោយអារម្មណ៍ក្ដុកក្ដួល នោះខ្ញុំបានទាញយកព្រះគម្ពីរមរមនចេញពីកាបូបរបស់ខ្ញុំ ។ ខ្ញុំបានប្រាប់ពួកគេអំពីការអធិស្ឋានរបស់ខ្ញុំ ហើយបានជូនព្រះគម្ពីរនោះទៅគាត់ ។

ព្រះវិញ្ញាណបានរំជួលដួងចិត្តពួកយើងទាំងអស់គ្នា ហើយកសិករនោះបានបង្ហាញសេចក្ដីសង្ឃឹមថា មិត្តភក្ដិរបស់គាត់នឹងអានព្រះគម្ពីរមរមន ហើយទទួលយកដំណឹងល្អ ។ នៅពេលខ្ញុំបានដើរត្រឡប់ទៅផ្ទះខ្ញុំវិញ នោះខ្ញុំថ្លែងអំណរគុណដល់ព្រះអម្ចាស់ ហើយបានអធិស្ឋានថា មិត្តរបស់កសិករនោះនឹងរក្សាការតាំងចិត្តរបស់គាត់ដើម្បីទៅលេងបរិវេណព្រះវិហារបរិសុទ្ធ ។

ប្រហែលជា ១៥ នាទីក្រោយមក ខ្ញុំបានទទួលការហៅទូរសព្ទមកពីសន្តិសុខយាមទ្វារ អិម. ធី. ស៊ី. ។ មិត្តភក្ដិរបស់កសិករនោះបានមកដល់ ។ រំពេចនោះខ្ញុំបានចេញទៅជួបគាត់ ។ គាត់គឺជាមេបញ្ជាការបើកកប៉ាល់ពាណិជ្ជករដែលនឹងធ្វើដំណើរត្រឡប់ទៅសមុទ្រវិញក្នុងរយៈពេលពីរថ្ងៃទៀត ។ គាត់បានអរគុណខ្ញុំសម្រាប់ព្រះគម្ពីរមរមន ហើយនិយាយថា គាត់នឹងយកវាទៅលើកប៉ាល់ជាមួយគាត់ ។ ពីមុនគាត់លាខ្ញុំ ខ្ញុំបានសម្លឹងមើលចំកែវភ្នែករបស់គាត់ ហើយនិយាយថា « ព្រះគម្ពីរនេះគឺជាព្រះគម្ពីរពិត » ។ នៅពេលខ្ញុំនិយាយពាក្យនោះ ព្រះវិញ្ញាណបានបញ្ជាក់សេចក្ដីពិតនេះដល់ខ្ញុំ ។

*លោកមេបញ្ជាការនោះបានអរគុណខ្ញុំសម្រាប់ព្រះគម្ពីរមរមន ហើយនិយាយថា គាត់នឹងយកវាទៅលើកប៉ាល់ជាមួយគាត់ ។*

នៅបុណ្យគ្រីស្ទម៉ាសនោះខ្ញុំបានផ្ដល់អំណោយពិសេសមួយ ៖ គឺព្រះគម្ពីរមរមន និងទីបន្ទាល់របស់ខ្ញុំថា វាជាព្រះគម្ពីរពិត ។ ខ្ញុំក៏បានទទួលអំណោយពិសេសមួយផងដែរ ៖ ព្រះអម្ចាស់បានឆ្លើយតបការអធិស្ឋានរបស់ខ្ញុំ ហើយបានប្រទានពរដល់ខ្ញុំនូវឱកាសមួយដើម្បីចែកចាយដំណឹងល្អ ។ ■

**ខ្លោដែត ប៉ាយប៊ី បើត រដ្ឋវ៉ាស៊ីនតោ ស. រ. អា.**



រូបភាពដោយ អ៊ីកា ស៊ីស្ស





**ដោយ អិម យ៉ូសែប ប្រោហ្វ**
ទីប្រឹក្សាទីពីរក្នុងគណៈប្រធានយុវជនទូទៅ

# សំឡេងតូចរហៀងនៅក្នុងពេលធ្វើ ការសម្រេចចិត្តដ៏ធំ

**ប្រសិនបើអ្នកមានភាពសក្តិសម នោះព្រះវរបិតាសួគ៌នឹងពុំទុកឲ្យអ្នកធ្វើកំហុសដ៏ធ្ងន់ធ្ងរដោយពុំព្រមានអ្នកជាមុននោះទេ ។**



ក្នុងនាមជាប្រធានបេសកកម្មថ្មីម្នាក់នៅក្នុងរដ្ឋវស្លឹកឈើជ្រុះនាឆ្នាំ ២០១១ នោះខ្ញុំរំភើបចិត្តដើម្បីចេញទៅជួបអ្នកផ្សព្វផ្សាយសាសនារបស់យើង ។ អែមមីលីភរិយារបស់ខ្ញុំ និងខ្ញុំបានសម្រេចចិត្តទៅពិនិត្យមើលផ្ទះ និងសួរសុខទុក្ខពួកអ្នកផ្សព្វផ្សាយសាសនាគ្រប់គូនៅក្នុងបេសកកម្ម ។

នៅពេលយើងបានធ្វើដំណើរពីទីក្រុងហ្គូតេម៉ាឡា ទៅកាន់តំបន់ជនបទមួយទៀតរបស់យើងដែលមានឈ្មោះថាសូឡូឡា នោះយើងបានដឹងថា ក្រុមបាតុកម្មមួយបានបិទផ្លូវនៅខាងមុខពួកយើង ។ បាតុកម្មនៅហ្គូតេម៉ាឡាអាចចំណាយពេលរាប់ម៉ោង ហើយជាទូទៅគ្មានផ្លូវដែលអាចឆ្លងកាត់ផុតពីពួកគេឡើយ ។ ប៉ុន្តែនៅពេលយើងបានសួរអំពីផ្លូវវាងដែលអាចមាន នោះយើងបានដឹងអំពីផ្លូវមួយផ្សេងទៀត ។ ប៉ុន្តែផ្លូវនោះមានស្លាកព្រមានដូច្នេះ ៖

- វាពុំមែនជាផ្លូវល្អអស្ចារ្យទេ ។
- សូមប្រុងប្រយ័ត្នកុំបើកលើផ្លូវនេះនៅពេលងងឹត ។
- ជារឿយៗក្រុមចោរប្លន់មាននៅតាមផ្លូវនេះ ។

ដោយជាប្រធានបេសកកម្មថ្មី និងភរិយាដែលមានចិត្តមោះមុត នោះអែមមីលី និងខ្ញុំបានបើកឡានលើផ្លូវនោះ ។ បន្ទាប់ពីបើកឡានបានមួយរយៈមក យើងបានទៅដល់ចំណុចមួយនៅលើផ្លូវដីហុយ ដែលមើលទៅដូចជាផ្លូវជ្រាលចុះនៅខាងមុខយើង ។ អែមមីលីនិយាយលេងថា យើងគួរតែយកម៉ាស៊ីនថតរូបមក ហើយថតរូបនៅពេលយើងឡើងទៅដល់គែមផ្លូវ ។

ជាច្រើនឆ្នាំមុន កាលខ្ញុំជាអ្នកផ្សព្វផ្សាយសាសនាវ័យក្មេងនៅប្រទេសហ្គូតេម៉ាឡា ខ្ញុំបានដឹងថា មានស្លាកតូចមួយលើផ្លូវដែលមានន័យថា « ទៅមុខដោយប្រុងប្រយ័ត្ន » ។ វាអាចមានន័យថា « ឈប់ » ។ ខ្ញុំបានឃើញស្លាកមួយ ប៉ុន្តែពុំយល់ពីន័យរបស់វាឡើយ ។

មួយសន្ទុះក្រោយមក យើងបានឃើញថាឡានយើងបានធ្លាក់ចុះពីលើចំណោតកម្ពស់ ៦ ម៉ែត្រ ជាស្ពានដែលបានលិចទឹក ។ ខ្ញុំរៀបចំលោតចេញពីឡាននៅខាងខ្ញុំ ប៉ុន្តែអែមមីលីពុំអាចបើកទ្វារឡានរបស់គាត់ទេ ។ នៅពេលគាត់បានព្យាយាមឡើងលើកៅអី ហើយចេញមកតាមទ្វារឡានរបស់ខ្ញុំ នោះឡានយើងក៏ចាប់ផ្តើមឃ្លីងឃ្លោងៗ ។ ប្រាកដណាស់ វាគឺជាគ្រាមួយដែលពោរពេញដោយការភ័យខ្លាច ។

មានគំនិតជាច្រើនបានផុសឡើងនៅក្នុង

រូបភាពមកពី GETTY IMAGES



ចិត្តរបស់ខ្ញុំ ។ ខ្ញុំនឹកឃើញដល់ចំណងជើងអត្ថបទកាសែតដែលអាចសរសេរថា ៖ « ប្រធានបេសកកម្មថ្មីបើកឡានរំលងទំនប់មាត់ច្រាំងដែលគ្មានស្ពាន បណ្ដាលឲ្យភរិយាមានគ្រោះថ្នាក់ធ្ងន់ធ្ងរ » ឬ « ប្រធានបេសកកម្មថ្មី និងភរិយាបានបាត់ខ្លួនបន្ទាប់ពីត្រូវបានចោរប្លន់នៅតាមផ្លូវមួយដែលពួកគេពុំគួរធ្វើដំណើរទ្បើយ » ។

ដោយពុំដឹងថា ត្រូវធ្វើដូចម្ដេច នោះខ្ញុំបានឈប់មួយសន្ទុះនៅខាងក្រៅរថយន្ត ហើយអធិស្ឋានទូលសូមដល់ព្រះវរបិតាសួគ៌ « សូមជួយទូលបង្គំនៅក្នុងគ្រានៃការធ្វេសប្រហែសរបស់ទូលបង្គំ » ។ តើអ្នកអាចជឿដែរឬទេថា រំពេចនោះ មានឡានដឹកចេកដ៏ធំមួយបានបើកពីក្រោយយើង ? តែកុងឡាន និងអ្នកធ្វើដំណើរនោះបានឃើញពួកយើង ហើយបានមកសើចដាក់យើង និងសប្បាយរីករាយនឹងស្ថានភាពដ៏គ្រោះថ្នាក់នៃជនបរទេសដ៏រងេរងើ ។ ពួកគេបានចង្អុលទៅស្លាកនៅលើផ្លូវនោះ ។ តាមពិតទៅ វាគ្រាន់តែជាមែកស្លាកតូចមួយប៉ុណ្ណោះ ។

បន្ទាប់មក ជាពរជ័យដ៏ប្រកបដោយអព្ភូតហេតុរបស់យើង នោះពួកគេបានទម្លាក់ច្រវាក់ពីឡានរបស់ពួកគេ ជាច្រវាក់តែមួយគត់ដែលខ្ញុំបានឃើញក្នុងរយៈពេលបម្រើបីឆ្នាំនៅហ្គូតេម៉ាឡា ។ ពីមុនពួកគេចេញទៅ ពួកគេបានកាត់ដើមឈើមួយហើយទាញវាដាក់ទទឹងផ្លូវនោះ ។ ខ្ញុំគិតថា ពួកគេចង់ធ្វើឲ្យប្រាកដថា ពួកអាមេរិកខាងជើងដែលមក

បន្ទាប់ទៀតកាត់ផ្លូវនេះនឹងពុំធ្វើកំហុសដូចនេះទៀតឡើយ ។



**ស្តាប់តាមការបំផុសគំនិត និងការព្រមាន**

ខ្ញុំប្រាប់អ្នកនូវរឿងនេះដើម្បីចង្អុលបង្ហាញថា យើងត្រូវតែស្តាប់តាមការព្រមាន ការបំផុសគំនិត និងការណែនាំដែលបានប្រទានដល់ពួកយើង តាមរយៈសំឡេងនៃព្រះអម្ចាស់—ទោះបីជាសំឡេងខ្លាំង ឬតិចក្តី ។ សំឡេងនោះកើតឡើងក្នុងទម្រង់ជាច្រើន ៖ ខគម្ពីរ បទបញ្ញត្តិ ការខ្សឹបប្រាប់ពីព្រះវិញ្ញាណបរិសុទ្ធ ប្រសាសន៍របស់ពួកព្យាការីនៅរស់ និងដំបូន្មានពីឪពុកម្តាយ ថ្នាក់ដឹកនាំសាសនាចក្រ និងកល្យាណមិត្ត ។ តើយើងកំពុងស្តាប់ និងស្តាប់តាមការបំផុសគំនិត និងការព្រមានទាំងនេះដែរឬទេ ? ហេតុអ្វីវាសំខាន់ដើម្បីធ្វើដូច្នេះ ?

យើងអាននៅក្នុងសុភាសិតថា ៖

« ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ ។

ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងតម្រង់អស់ទាំងផ្លូវច្រករបស់ឯង ។

កុំឲ្យមើលខ្លួនថា មានប្រាជ្ញាឡើយ ចូរកោតខ្លាចដល់ព្រះយេហូវ៉ាវិញ ហើយចៀសចេញពីសេចក្តីអាក្រក់ទៅ » ( សុភាសិត ៣:៥–៧ ) ។

យើងត្រូវតែទុកចិត្តលើព្រះអម្ចាស់ដោយអស់ពីដួងចិត្តរបស់យើង ។ យើងត្រូវតែយល់ថា ចំណេះដឹងរបស់យើងមានភាពខ្វះខាតនូវអ្វីដែលល្អបំផុតសម្រាប់យើង និងអ្នកដទៃទៀត ។ ប្រសិនបើយើងពិតជាទុកចិត្តទ្រង់មែន ឱនេះជាការសន្យាដ៏អស្ចារ្យអ្វីម្ល៉េះដែលទ្រង់ប្រទានឲ្យ ៖ ទ្រង់នឹងដឹកនាំផ្លូវរបស់យើង ។

នៅក្នុងគ្រួសារយើង យើងមានពាក្យស្លោកមួយដែលក្លាយជាផ្នែកមួយដ៏សំខាន់នៃបេសកកម្មរបស់យើង ។ ប្រធាន វែសុល អិម ណិលសុន បានបង្រៀនគោលគំនិតនេះយូរមកហើយ ។ លោកបានថ្លែងដូច្នេះថា ៖ « ការគោរពប្រតិបត្តិនាំមកនូវភាពជោគជ័យ ការគោរពប្រតិបត្តិដោយឥតល្អៀង នាំមកនូវអព្ភូតហេតុ » ។[1]

ពាក្យស្លោករបស់គ្រួសារយើង និងបេសកកម្មរបស់យើងគឺ ៖ « ការគោរពប្រតិបត្តិនាំមកនូវភាពជោគជ័យ ប៉ុន្តែការគោរពប្រតិបត្តិដោយឥតល្អៀងនាំមកនូវអព្ភូតហេតុ » ។

ខ្ញុំពុំយល់ន័យទាំងស្រុងនូវនៃពាក្យគោរពប្រតិបត្តិដោយឥតល្អៀងឡើយ ប៉ុន្តែនេះជាអ្វីដែលខ្ញុំបានយល់ ។ វាពុំមែនមានន័យថា យើងគោរពប្រតិបត្តិយ៉ាងល្អឥតខ្ចោះក្នុងពេលនេះនៅក្នុងរឿងគ្រប់យ៉ាងនោះទេ ទោះបីជាយើងអាចល្អឥតខ្ចោះនៅក្នុងការគោរពតាមបទបញ្ញត្តិជាច្រើនរបស់ព្រះអម្ចាស់ក្តី ។ ប៉ុន្តែការប្រែចិត្តត្រូវតែជាផ្នែកសំខាន់មួយនៃការគោរពប្រតិបត្តិដោយឥតល្អៀង ។ ការគោរពប្រតិបត្តិដោយឥតល្អៀងតម្រូវឲ្យមានការតាំងចិត្តចំពោះការព្រមាន និងការបំផុសគំនិត ព្រមទាំងបទបញ្ញត្តិទាំងអស់ដែលព្រះវរបិតាសួគ៌ប្រទានដល់ពួកយើង ។

ជួនកាលយើងពុំយល់ពីមូលហេតុដែលព្រះវរបិតាសួគ៌សុំយើងនូវរឿងជាក់លាក់ឡើយ ។ គ្រាទាំងនោះអាចជាគ្រាមួយចំនួនដ៏លំបាកបំផុតដើម្បីគោរពប្រតិបត្តិដោយឥតល្អៀង ។ តើអ្នកចាំទេនៅពេលអ័ដាម មនុស្សម្នាក់ដ៏អស្ចារ្យបំផុតនៃមនុស្សទាំងអស់ត្រូវបានសួរថា ហេតុអ្វីលោកបានថ្វាយយញ្ញបូជា ៖ « ហើយជាច្រើនថ្ងៃកន្លងមក នោះមានទេវតាមួយពីព្រះអម្ចាស់បានលេចមកឲ្យអ័ដាមឃើញ ដោយសួរថា ៖ ហេតុអ្វីបានជាអ្នកថ្វាយយញ្ញបូជាទាំងឡាយដល់ព្រះអម្ចាស់ ? ហើយអ័ដាមបានទូលតបទៅលោកថា ៖ ខ្ញុំមិនដឹងទេ លើកលែងតែព្រះអម្ចាស់ទ្រង់បញ្ជាខ្ញុំប៉ុណ្ណោះ » ( ម៉ូសេ ៥:៦ ) ។

**ធ្វើតាមពួកព្យាការី**

អែមមីលីគឺជាគំរូដ៏អស្ចារ្យអំពីការគោរពប្រតិបត្តិដោយឥតល្អៀង ទោះបីនៅពេលគាត់ពុំបានយល់ក្តី ។ នៅអំឡុងសន្និសីទទូទៅខែតុលា ឆ្នាំ ២០០០ គាត់បានស្តាប់ឮការទូន្មានដូចតទៅនេះមកពីប្រធាន ហ្គរដុន ប៊ី. ហ៊ិងគ្លី ( ១៩១០–២០០៨ ) ៖ « យើងពុំលើកទឹកចិត្តឲ្យមានការចាក់សាក់ និង ‹ ការចាក់ខ្លួនផ្សេងៗក្រៅពីគោលបំណងនៃវេជ្ជសាស្ត្រឡើយ › ។ ប៉ុន្តែយើងពុំនិយាយអំពី ‹ ការចោះតូចពាក់ក្រវិលមួយគូនៅលើត្រចៀករបស់ស្ត្រី ›—គឺតែមួយគូប៉ុណ្ណោះ » ។[2]

ពេលភរិយាខ្ញុំបានទៅដល់ផ្ទះវិញ គាត់បាន

រូបគំនូរដោយ ស៊ីមុន ដ៊ូ ៖ រូបភាពព្រះគ្រីស្ទ ដោយ ហ៊ីនរិច ហូហ្វម៉ាន



ពន្យល់កូនស្រីទីពីររបស់យើងអំពីសារៈសំខាន់នៃការធ្វើតាមពួកព្យាការីទោះជារឿងអ្វីក៏ដោយ ។ ដូចគាត់បាននិយាយ ភរិយារបស់ខ្ញុំក៏បានគោរពតាមផងដែរ ។ គាត់បានដោះក្រវិលគូទីពីររបស់គាត់ចេញជាលើកចុងក្រោយ ។ ខ្ញុំជឿថា គាត់នៅតែពុំយល់ពីមូលហេតុនោះនៅឡើយ ប៉ុន្តែខ្ញុំដឹងអំពីមូលហេតុដែលវាសំខាន់ចំពោះគាត់ ។

ចំពោះពួកយើងមួយចំនួន រឿងនោះអាចមិនសំខាន់ឡើយ ដោយសារវាហាក់ដូចជារឿងតូចតាច ។ រឿងនោះពិតណាស់ ។ ប៉ុន្តែខ្ញុំពុំចាំពីបន្ទូលរបស់ព្រះអង្គសង្គ្រោះដែលថា « បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តិរបស់ខ្ញុំ ដែលឃើញថាសំខាន់ចុះ » ( សូមមើល យ៉ូហាន ១៤:១៥ ) ។

បងប្អូនប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំ សំឡេងដ៏ច្បាស់នៃការព្រមាន ដែលយើងត្រូវតែស្ដាប់តាមនោះចេញមកពីពួកសាវក និងពួកព្យាការីដែលព្រះអម្ចាស់បានជ្រើសរើស ។ វាអាចពុំមានប្រជាប្រិយតាមរយៈបទដ្ឋាននៃលោកិយឡើយ គឺដូចជារឿងតូចតាចដែលបានស្នើសុំដោយប្រធានហ៊ីងគ្លី ។ ប៉ុន្តែអ្នកអាច—អ្នកត្រូវតែ—ទុកចិត្តថា វាចេញមកពីព្រះវរបិតាសួគ៌ ។ វាអាចគ្រាន់តែជាមែកស្លាកតូចមួយប៉ុណ្ណោះ ឬវាអាចជាដើមឈើមួយទាំងមូលដែលដាក់នៅទទឹងលើផ្លូវ ។ ខ្ញុំសូមដាស់តឿនអ្នកឲ្យអាន ឬស្ដាប់សន្និសីទទូទៅជាមួយនឹងគំនិតនេះក្នុងចិត្ត ៖ តើមែកស្លាក ឬដើមឈើអ្វីដែលព្រះអម្ចាស់បានដាក់នៅលើផ្លូវរបស់ខ្ញុំ ?

### ទុកចិត្តលើព្រះអម្ចាស់

ពួកអ្នកមួយចំនួនអាចកំពុងគិតថា « មែនហើយ នោះជារឿងអស្ចារ្យណាស់ ។ ប៉ុន្តែតើអ្នកធ្វើដូចម្ដេច នៅពេលអ្នកកំពុងស្វែងរកការបំផុសគំនិតព្រះឱវាទ ការព្រមាន និងការណែនាំពីព្រះអម្ចាស់ ហើយអ្នកហាក់ដូចជាពុំទទួលចម្លើយនោះ ? »

ប្រហែលអ្នកមានកង្វល់នេះទាក់ទងនឹងការសម្រេចចិត្តដ៏សំខាន់នៅក្នុងជីវិតអ្នក ។ ចូរចាំអំពីការសន្យាឲ្យដាក់ទីពឹងលើព្រះអម្ចាស់ឲ្យអស់អំពីចិត្តអ្នក ហើយទ្រង់នឹងដឹកនាំផ្លូវរបស់អ្នក ។

ទាក់ទងនឹងព្រឹត្តិការណ៍សំខាន់ៗនៅក្នុងជីវិតរបស់យើង នោះយើងពិតជាចង់បានការណែនាំច្បាស់លាស់ ហើយថាវាពិបាកនឹងរកឃើញ ។ ប៉ុន្តែខ្ញុំបានយល់ច្បាស់ថា ប្រសិនបើខ្ញុំប្រែចិត្តគោរពប្រតិបត្តិដោយឥតល្អៀង ធ្វើតាមអ្នកដឹកនាំរបស់ខ្ញុំ ហើយធ្វើការសម្រេចចិត្តល្អៗផ្សេងទៀត—ឬនិយាយម្យ៉ាងទៀតថា ប្រសិនបើខ្ញុំមានភាពសក្តិសម—នោះព្រះវរបិតាសួគ៌នឹងពុំទុកឲ្យខ្ញុំធ្វើកំហុសធ្ងន់ធ្ងរដោយពុំព្រមានខ្ញុំជាមុននោះទេ ។ ហើយទ្រង់ក៏នឹងពុំអនុញ្ញាតអ្នកឲ្យធ្វើដែរ ។

ឱមិត្តវ័យក្មេងរបស់ខ្ញុំអើយ ព្រះវរបិតាសួគ៌គង់នៅទីនេះដើម្បីកុំឲ្យយើងធ្វើកំហុសធ្ងន់ធ្ងរ ប្រសិនបើយើងស្វែងរកការព្រមាន ការបំផុសគំនិតរបស់ទ្រង់ និងវិវរណៈមកពីគ្រប់ប្រភពដែលមានទាំងអស់—និងប្រសិនបើយើងស្ដាប់តាម និងអនុវត្តតាមអ្វីៗទាំងនោះ ។ យើងមានសិទ្ធិដើម្បីមានព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយយើងជានិច្ច ជាពិសេសនៅក្នុងគ្រាដ៏ចាំបាច់នៃជីវិត ។

នេះជាក្ដីសង្ឃឹមរបស់ខ្ញុំថា អ្នកនឹងរកឃើញដោយជោគជ័យនូវមែក និងដើមឈើនៃស្លាកព្រមាន ដែលព្រះវរបិតាសួគ៌បានដាក់នៅលើផ្លូវរបស់អ្នក ។

ខ្ញុំសូមថ្លែងទីបន្ទាល់ថា នៅពេលយើងស្ដាប់តាមសំឡេងនៃព្រះអម្ចាស់ នៅពេលយើងទទួលសំឡេងនោះពីប្រភពជាច្រើនរបស់វា ហើយព្យាយាមគោរពប្រតិបត្តិដោយឥតល្អៀង នោះយើងអាចមានជីវិតដែលបញ្ចប់ដោយ « ហើយពួកគេបានរស់នៅដោយរីករាយជារៀងដរាបតទៅ » ។ ការណ៍នោះអាចកើតឡើងបានតាមរយៈការរស់នៅតាមគោលលទ្ធិនៃព្រះគ្រីស្ទ និងការចុះ និងការរក្សាសេចក្ដីសញ្ញាពិសិដ្ឋទាំងឡាយប៉ុណ្ណោះ ។ ■

*ដកស្រង់ចេញពីសុន្ទរកថាដែលមានចំណងជើងថា « Heeding the Voice of the Lord » បានថ្លែងនៅសាកលវិទ្យាល័យព្រិកហាំ យ៉ង់–អៃដាហូ នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៧ ។*

កំណត់ចំណាំ

១. រ័សុល អិម ណិលសុន នៅក្នុង R. Scott Lloyd « Elder Nelson Delivers Spiritual Thanksgiving Feast to MTCs » ព័ត៌មានសាសនាចក្រវគ្គនៃគេហទំព័រ LDS.org ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៣ news.lds.org ។
២. ហ្គរដុន ប៊ី ហ៊ីងគ្លី « Great Shall Be the Peace of Thy Children » *Liahona* ខែ មករា ឆ្នាំ ២០០១ ទំព័រ ៦៨ ។

*ដកស្រង់មកពីសុន្ទរកថាដែលបានថ្លែងនៅថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០១៨ នៅក្នុងកម្មវិធី « រួមគ្នាតែមួយ » ការប្រារព្ធខួបលើកទី ៤០ ឆ្នាំនៃវិវរណៈឆ្នាំ ១៩៧៨ ស្ដីពីបព្វជិតភាព ។*

# រួមគ្នាតែមួយ






**ដោយប្រធាន ដាល្លិន អេក អូក**
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ


## បុព្វហេតុមួយនៃការសាទរ

**សម្រាប់ពួកបរិសុទ្ធថ្ងៃចុងក្រោយដែលជាយុវមជ្ឈិមវ័យនៅគ្រានោះ វិវរណៈឆ្នាំ** ១៩៧៨ ស្ដីពីបព្វជិតភាព គឺជាព្រឹត្តិការណ៍ដែលពួកគេនឹងចងចាំជាប់ជានិច្ច ។

I.

ព័ត៌មាននោះបានឮមកដល់ខ្ញុំតាមទូរសព្ទមួយដែលកម្រពាទ័ឡើង ។ កូនប្រុសខ្ញុំពីរនាក់ និងខ្ញុំកំពុងធ្វើការនៅឯទីធ្លានៅផ្ទះលើភ្នំរបស់យើង ដែលយើងបានសាងសង់ទុកជាកន្លែងមួយដើម្បីសម្រាកលំហែពីការទទួលខុសត្រូវដ៏ធ្ងន់របស់ខ្ញុំ ក្នុងនាមជាប្រធានសាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ ។ អែលឌើរ ប៊ិយដ៍ឃេ ផាកកឺ គឺជាអ្នកទូរសព្ទមក ។ លោកបានប្រាប់ខ្ញុំអំពីវិវរណៈស្ដីពីបព្វជិតភាព ដែលទើបតែបានប្រកាសរួច ។ យើងបានសន្ទនាគ្នាដោយអំណរ ហើយខ្ញុំបានដើរត្រឡប់ទៅធ្វើការវិញ ។ ខ្ញុំអង្គុយលើពំនូកដីដែលយើងបានលើក ហើយបក់ដៃហៅកូនប្រុសខ្ញុំឲ្យមក ។ នៅពេលខ្ញុំបានប្រាប់ពួកគេថា ឥឡូវនេះ ពួកសមាជិកសាសនាចក្រដែលជាបុរសសក្ដិសមទាំងអស់អាចត្រូវបានតែងតាំងឲ្យនូវបព្វជិតភាព នោះខ្ញុំបានយំដោយអំណរ ។

ហេតុអ្វីវិវរណៈស្ដីពីបព្វជិតភាពគឺជាឱកាសនៃអំណរបែបនេះ ? កាលនៅជាយុវជនកំពុងសិក្សា និងធ្វើការនៅក្នុងវិជ្ជាជីវៈផ្នែកច្បាប់ ខ្ញុំបានរស់នៅក្នុងតំបន់ភាគខាងលិចកណ្ដាល និងភាគខាងកើតនៃសហរដ្ឋអស់រយៈពេល ១៧ ឆ្នាំ ។ ខ្ញុំបានសង្កេតឃើញ និងចូលរួមឈឺចាប់ និងមានបទពិសោធន៍ដ៏លំបាកពីអស់អ្នកដែលរងទុក្ខដោយសារការរឹតត្បិតនេះ និងអស់អ្នកដែលបានសង្កេតមើលច្បាប់នេះ បានរិះគន់វា និងស្វែងរកហេតុផលជាច្រើន ។ បន្ទាប់មកខ្ញុំបានសិក្សាអំពីហេតុផលនានាដែលត្រូវបានផ្ដល់ឲ្យ ហើយពុំអាចទទួលអារម្មណ៍បញ្ជាក់អំពីសេចក្ដីពិតនៃច្បាប់នេះឡើយ ។ ជាផ្នែកមួយនៃការសិក្សាប្រកបដោយការអធិស្ឋានរបស់ខ្ញុំ នោះខ្ញុំបានដឹងថា ជាទូទៅព្រះអម្ចាស់កម្រនឹងប្រទានហេតុផលសម្រាប់បទបញ្ញត្តិ និងការណែនាំដែលទ្រង់បានប្រទានឲ្យអ្នកបម្រើទ្រង់ណាស់ ។ ខ្ញុំបានសម្រេចចិត្តបន្តស្មោះត្រង់ចំពោះអ្នកដឹកនាំដែលជាពួកព្យាការីរបស់យើង ហើយអធិស្ឋាន—ដូចដែលបានសន្យាតាំងពីដើមដំបូងនៃការរឹតត្បិតទាំងនេះ—ថាថ្ងៃនោះមកដល់ នៅពេលដែលមនុស្សទាំងអស់នឹងមានអំណរជាមួយពរជ័យនៃបព្វជិតភាព និងព្រះវិហារបរិសុទ្ធ ។ ឥឡូវនេះ ថ្ងៃនោះបានមកដល់គឺនៅថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ១៩៧៨ ហើយខ្ញុំបានយំដោយអំណរ ។











## II.

នៅពេលយើងបានពិចារណាអំពីអ្វីដែលបានកើតឡើង និងអ្វីដែលកំពុងកើតឡើងនៅក្នុងសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ និងនៅក្នុងជីវិតនៃសមាជិកសាសនាចក្រនេះ តាំងពីឆ្នាំ ១៩៧៨ មក នោះយើងទាំងអស់គ្នាមានបុព្វហេតុដើម្បីសាទរ ។

ទាក់ទងនឹងប្រតិបត្តិការនេះ សាសនាចក្រមានប្រតិកម្មយ៉ាងលឿនទៅនឹងវិវរណៈស្ដីពីបព្វជិតភាពនេះ ។ ពិធីបរិសុទ្ធ និងប័ណ្ណចូលព្រះវិហារបរិសុទ្ធបានកើតឡើងភ្លាម ។ ហេតុផលនានាដែលត្រូវបានផ្ដល់ឲ្យដើម្បីព្យាយាមពន្យល់អំពីការរឹតត្បិតពីមុនៗទៅលើសមាជិកពូជពង្សអាហ្វ្រិក—ទោះបីជាការរឹតត្បិតដែលបានបង្ហាញពីមុនដោយថ្នាក់ដឹកនាំសាសនាចក្រដែលគួរឲ្យគោរពក្ដី—ត្រូវបានជំរុញ និងប្រកាសថាឈប់អនុវត្តជាសាធារណៈទៀតហើយ ។ ព្រះអម្ចាស់បានមានបន្ទូលមកកាន់ព្យាការីរបស់ទ្រង់ ហើយសមាជិកសាសនាចក្រទ្រង់បានធ្វើតាម ។

ផ្ទុយទៅវិញ ការផ្លាស់ប្ដូរនានានៅក្នុងដួងចិត្ត និងការអនុវត្តនៃសមាជិកម្នាក់ៗពុំទាន់កើតមានភ្លាមៗ និងជាសាកលឡើយ ។ មនុស្សខ្លះបានទទួលយកឥទ្ធិពលនៃវិវរណៈនេះភ្លាមៗ និងដោយព្រះគុណ មនុស្សខ្លះទៀតបានទទួលវាដោយសន្សឹមៗ ហើយខ្លះទៀតនៅក្នុងជីវិតពួកគេផ្ទាល់ បានបន្តឥរិយាបថនៃការប្រកាន់ពូជសាសន៍ដែលជាការឈឺចាប់ជាខ្លាំង ដល់មនុស្សជាច្រើននៅទូទៅពិភពលោក រួមទាំងរយៈពេល ៤០ ឆ្នាំកន្លងទៅ ។ អ្នកខ្លះចង់ត្រឡប់ទៅមើល ដោយផ្ដោតចិត្តទុកដាក់ទៅលើការត្រួតពិនិត្យមើលពីអតីតកាលឡើងវិញ រួមទាំងស្វែងរកហេតុផលសម្រាប់ការរឹតត្បិតដែលឥឡូវនេះផុតសម័យទៅហើយនោះ ។ ប៉ុន្តែសមាជិកភាគច្រើននៅក្នុងសាសនាចក្រ រួមទាំងថ្នាក់ដឹកនាំរៀមច្បងនៃសាសនាចក្រ បានផ្ដោតចិត្តទុកដាក់លើឱកាសនានាអំពីអនាគត ជាជាងការខកចិត្តពីរឿងអតីតកាល ។ ពួកគាត់ភាគច្រើនបានទុកចិត្តលើប្រាជ្ញា និងពេលវេលារបស់ព្រះអម្ចាស់ ហើយបានទទួលការណែនាំពីព្យាការីរបស់ទ្រង់ ។ តាមរយៈការធ្វើដូច្នោះ យើងបានដឹងពីសារៈសំខាន់ដ៏អស់កល្បនៃការបង្រៀនរបស់ព្យាការីរបស់ទ្រង់ថា « នៅក្រោមព្រះនេត្រទ្រង់ មនុស្សណាក៏មានតម្លៃដូចជាមនុស្សណាដែរ » ( យ៉ាកុប ២:២១ ) ។ តាមរយៈការធ្វើដូច្នោះ យើងបានទទួលការជំរុញចិត្តថ្មីឲ្យបំពេញការត្រាស់បញ្ជាពីព្រះអម្ចាស់ព្រះយេស៊ូវគ្រីស្ទថា យើងត្រូវបង្រៀនដំណឹងល្អដ៏អស់កល្បជានិច្ចដល់មនុស្សទាំងអស់—ទៅដល់ « គ្រប់ទាំងសាសន៍ គ្រប់ពូជមនុស្ស គ្រប់ភាសា និងគ្រប់ទាំងប្រជាជន » ( គ. និង ស. ៤២:៥៨ ) ។



« មនុស្សម្នាក់គឺមានតម្លៃនៅក្នុងព្រះនេត្ររបស់ទ្រង់ដូចមនុស្សម្នាក់ទៀតផងដែរ » ។

## III.

ការធ្វើឲ្យខ្លួនយើងខ្វល់ខ្វាយនឹងអ្វីដែលពុំបានបើកសម្ដែង ឬជាមួយការពន្យល់ពីអតីតកាល ដោយអស់អ្នកដែលបានដំណើរការជាមួយនឹងការយល់ដឹងដែលមានកម្រិត អាចកើតឡើងតាមរយៈតែការប៉ាន់ស្មាន និងភាពស្មុគស្មាញប៉ុណ្ណោះ ។ ចំពោះអស់អ្នកដែលមានការខ្វល់ខ្វាយបែបនេះ យើងសូមបង្ហាញសេចក្ដីស្រឡាញ់របស់យើង និងការអញ្ជើញពិសេស







« យើងសូមអញ្ជើញ មនុស្សទាំងអស់ . . . ឲ្យធ្វើការជាមួយសង្គមស៊ីវិលដ៏ធំមហិមា ដោយលុបបំបាត់ចោលការលំអៀងគ្រប់បែបយ៉ាងទាំងអស់ ។

នេះ ។ សូមឲ្យយើងទាំងអស់គ្នាទន្ទឹងចាំមើលដោយសាមគ្គីភាពនៃសេចក្ដីជំនឿ និងការទុកចិត្តរបស់យើងលើការសន្យារបស់ព្រះអម្ចាស់ថា « ទ្រង់អញ្ជើញពួកគេទាំងអស់គ្នាឲ្យមករកទ្រង់ ហើយទទួលទាននូវសេចក្ដីល្អសប្បុរសរបស់ទ្រង់ ហើយទ្រង់ពុំបដិសេធអ្នកណាម្នាក់ ដែលមករកទ្រង់ឡើយ គឺទាំងខ្មៅ និងស ទាំងបាវគេ និងសេរី ទាំងប្រុស និងស្រី » ( នីហ្វៃទី ២ ២៦:៣៣ ) ។

នៅពេលយើងសម្លឹងទៅមើលអនាគតកាល ឥទ្ធិពលសំខាន់បំផុតមួយនៃវិវរណៈស្ដីពីបព្វជិតភាពគឺជាការហៅមកពីព្រះ ដើម្បីបោះបង់ចោលឥរិយាបថនៃការលំអៀង ទាស់នឹងក្រុមណាមួយនៃបុត្រាបុត្រីរបស់ព្រះ ។ ការប្រកាន់ពូជសាសន៍គឺប្រហែលជាប្រភពនៃភាពលំអៀងដ៏ពេញនិយមនាពេលសព្វថ្ងៃនេះ ហើយយើងទាំងអស់គ្នាត្រូវបានហៅឲ្យប្រែចិត្តពីរឿងនោះ ។ ប៉ុន្តែនៅទូទាំងប្រវត្តិសាស្ត្រ បុត្រាបុត្រីជាច្រើនក្រុមរបស់ព្រះត្រូវបាន ឬបានទទួលរងការបៀតបៀន ឬត្រូវបានដាក់នៅក្នុងស្ថានភាពដែលពុំគួរឲ្យពេញចិត្តដោយការលំអៀង ដូចជាអស់អ្នកដែលផ្អែកទៅលើជាតិពន្ធ ឬវប្បធម៌ ឬសញ្ជាតិ ឬការអប់រំ ឬស្ថានភាពសេដ្ឋកិច្ច ។

ក្នុងនាមជាអ្នកបម្រើរបស់ព្រះ ដែលមានចំណេះដឹង និងការទទួលខុសត្រូវចំពោះផែនការនៃសេចក្ដីសង្គ្រោះដ៏មហិមារបស់ទ្រង់ នោះយើងគួរតែពន្លឿនការរៀបចំឥរិយាបថ និងទង្វើរបស់យើង—ទាំងស្ថាប័ន និងផ្ទាល់ខ្លួន—ដើម្បីដាក់ការលំអៀងទាំងអស់របស់យើងទុកនៅមួយឡែក ។ ដូចប្រធាន រ័សុល អិម ណិលសុន បានមានប្រសាសន៍បន្ទាប់ពីការប្រជុំថ្មីនេះរបស់យើងជាមួយនឹងរដ្ឋមន្ត្រីជាតិនៃសមាគមន៍ជាតិសម្រាប់ការលើកកម្ពស់ពណ៌សម្បុរមនុស្ស ៖ « យើងទាំងអស់គ្នាសូមអញ្ជើញមនុស្ស អង្គការ និងរដ្ឋាភិបាល [ ទាំងអស់ ] ឲ្យធ្វើការជាមួយសង្គមស៊ីវិលដ៏ធំមហិមា ដោយលុបបំបាត់ចោលនូវការលំអៀងគ្រប់បែបយ៉ាងទាំងអស់ » ។[1]

ទោះបីជាយើងរួបរួមគ្នាដើម្បីលុបបំបាត់ចោលនូវឥរិយាបថ និងការអនុវត្តនៃការលំអៀងក្ដី យើងគួរតែចាំថា វាពុំមែនជាការលំអៀងដែលសាសនាចក្រទទូចឲ្យមានច្បាប់ជាក់លាក់ក្នុងគោលបំណងនៃតម្រូវការស្ដីពីភាពសក្តិសមសម្រាប់ព្រះអម្ចាស់ដើម្បីចូលរួមព្រះវិហារបរិសុទ្ធនោះទេ ។ ព្រះអម្ចាស់បានប្រកាសថា ការគោរពតាមសេចក្ដីសញ្ញា និងបទបញ្ញត្តិគឺជាតម្រូវការដ៏ចាំបាច់មួយដើម្បីរីករាយនឹងពរជ័យដ៏បរិសុទ្ធ ។ ការព្យាយាមដើម្បីលុបបំបាត់តម្រូវការមកពីព្រះសម្រាប់ជីវិតអស់កល្បជានិច្ច និងក្រុមគ្រួសារអស់កល្ប គឺដូចជាការព្យាយាមបង្កើតផែនការរបស់សាតាំងដែល « មនុស្សទាំងអស់នឹងត្រូវបានសង្គ្រោះ » ។ យើងដែលមានជីវិតរមែងស្លាប់នេះបានបដិសេធផែនការរបស់សាតាំងរួចទៅហើយនៅក្នុងជីវិតមុនឆាកជីវិតនេះ ។ យើងបានជ្រើសរើសយកផែនការរបស់ព្រះវរបិតាសួគ៌យើង ដែលប្រទាន

សេរីភាពដើម្បីជ្រើសរើស និងរក្សាសេចក្ដីសញ្ញា អស់កល្បជានិច្ច និងបទញ្ញាត្តិដែលអនុវត្តស្មើគ្នា ចំពោះមនុស្សទាំងអស់ ។ ភាពស្មើគ្នារបស់ព្រះអម្ចាស់ គឺមិនមែនជាលទ្ធផលស្មើគ្នាសម្រាប់មនុស្សទាំងអស់ នោះទេ ប៉ុន្តែជាឱកាសស្មើគ្នាចំពោះមនុស្សទាំងអស់ ។

## IV.

ការប្ដេជ្ញាចិត្តរបស់យើងនៅក្នុងកម្មវិធីរំឭកខួបនេះគឺ សាទរខួបលើកទី ៤០ ឆ្នាំនៃវិវរណៈស្ដីពីបព្វជិតភាព ដោយការទន្ទឹងរង់ចាំ ។ នៅពេលយើងធ្វើដូច្នេះ យើង បង្ហាញអំណរគុណជាពិសេសសម្រាប់សមាជិក ពូជពង្សពួកអាហ្វ្រិកដ៏អស្ចារ្យរបស់យើង ជាពិសេស សមាជិកអាហ្វ្រិកអាមេរិកកាំងរបស់យើង ដែលបាន តស៊ូដោយសេចក្ដីជំនឿ និងស្មោះត្រង់ ហែលឆ្លង កាត់រយៈពេលផ្លាស់ប្ដូរដ៏លំបាកនៃការសាបសូន្យ នូវភាពលំអៀង ។ ឥឡូវនេះ យើងចូលរួមជាមួយគ្នា នៅក្នុងការផ្ដោតចិត្តទុកដាក់របស់យើងលើឥទ្ធិពល ដ៏រុងរឿងបន្ទាប់ពីឆ្នាំ ១៩៧៨ នៃវិវរណៈនោះ នៅក្នុង ការផ្ដល់ពរដល់បុត្រាបុត្រីរបស់ព្រះទាំងអស់នៅលើ ពិភពលោក ។ ពួកព្យាការីដែលជាអ្នកដឹកនាំយើងបាន ប្រកាសនៅគ្រានោះថា ៖

« ឥឡូវនេះ ព្រះអម្ចាស់បានបើកសម្ដែងព្រះទ័យ ទ្រង់សម្រាប់ជាពរជ័យដល់បុត្រាបុត្រីទ្រង់ទាំងអស់ ទូទាំងពិភពលោក ដែលនឹងស្ដាប់តាមសំឡេងនៃអ្នក បម្រើដែលមានសិទ្ធិអំណាច ហើយរៀបចំពួកគេដើម្បី ទទួលគ្រប់ពរជ័យនៃដំណឹងល្អ » ។[២]



ឥឡូវនេះព្រះវិហារបរិសុទ្ធត្រូវបានសាងសង់ នៅក្នុងប្រទេសជាច្រើន សម្រាប់ជាពរជ័យដល់ បុត្រាបុត្រីរបស់ទ្រង់ទាំងសង្ខាងនៃវាំងនន ។ យើងរីករាយជាមួយគ្នានៅលើផែនដី និងនៅលើ ស្ថានសួគ៌ ។ នេះគឺជាផ្នែកនៃការរៀបចំរបស់យើង សម្រាប់ការយាងមកជាលើកទីពីររបស់ទ្រង់ ដែល បានប្រកាសតាមរយៈព្យាការីក្នុងព្រះគម្ពីរមរមនថា « ទ្រង់មិនដែលបញ្ឆោដល់អ្នកណាម្នាក់ថា គេ នឹងមិនគួរទទួលយកសេចក្ដីសង្គ្រោះរបស់ទ្រង់ នោះឡើយ » ( នីហ្វៃទី ២ ២៦:២៤ ) ហើយដែល បានប្រកាសតាមរយៈព្យាការីសម័យទំនើបថា « បើ សិនជាអ្នករាល់គ្នាមិនរួមគ្នាតែមួយទេ ឈ្មោះថាអ្នក រាល់គ្នាពុំមែនជារបស់ផងយើងឡើយ » ( គ. និង ស. ៣៨:២៧ ) ។ ■

កំណត់ចំណាំ

១. « First Presidency and NAACP Leaders Call for Greater Civility, Racial Harmony » ថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១៨ គេហទំព័រ mormonnewsroom.org ។
២. សេចក្ដីប្រកាសជាផ្លូវការទី ២

**យើងគួរតែពន្លឿន...ការទម្លាក់ចោលនូវការប្រកាន់ពូជសាសន៍ផ្ទាល់ខ្លួនទាំងអស់របស់យើងមួយអន្លើ ។**

# ការបង្កើតជាស្ពាន

ដោយប្រធាន រ័សុល អិម ណិលសុន

**ជាច្រើនសតវត្សរ៍កន្លងទៅ អ្នកច្បាប់ដ៏ចេះដឹងម្នាក់បានសួរព្រះអង្គសង្គ្រោះថា ៖**

« លោកគ្រូ ក្នុងបណ្ដាក្រឹត្យវិន័យ តើបញ្ញត្តិណាដែលយ៉ាងសំខាន់បំផុត ?

នោះព្រះយេស៊ូវឆ្លើយថា ត្រូវឲ្យស្រឡាញ់ព្រះអម្ចាស់ជាព្រះនៃឯងឲ្យអស់អំពីចិត្ត អស់អំពីព្រលឹង ហើយអស់អំពីគំនិតឯង ។

នេះជាបញ្ញត្តិយ៉ាងសំខាន់ទីមួយ ។

ហើយបញ្ញត្តិទីពីរក៏បែបដូចគ្នាគឺថា ត្រូវស្រឡាញ់អ្នកជិតខាងដូចខ្លួនឯង ។

បណ្ដាក្រឹត្យវិន័យ និងអស់ទាំងទំនាយហោរាទាំងប៉ុន្មាន ក៏សម្រេចនៅបទបញ្ញត្តិទាំងពីរប្រការនេះឯង » ។[១]

ជាថ្មីម្ដងទៀតនៅក្នុងឆ្នាំ ១៨៣១ ការណែនាំនេះត្រូវបានបើកសម្ដែងទៅកាន់ព្យាការី យ៉ូសែប ស្ម៊ីធ ពេលព្រះអម្ចាស់មានបន្ទូលថា « ហើយចូរបណ្ដោយឲ្យមនុស្សគ្រប់រូប គោរពបងប្អូនខ្លួន ដូចជាខ្លួនឯងផ្ទាល់ ហើយប្រព្រឹត្តដោយគុណធម៌ និងដោយបរិសុទ្ធភាពនៅចំពោះយើងចុះ ។

ហើយជាថ្មីទៀត យើងប្រាប់អ្នកថា ចូរបណ្ដោយឲ្យមនុស្សគ្រប់រូប គោរពបងប្អូនខ្លួន ដូចជាខ្លួនឯងផ្ទាល់ចុះ » ។[២]

នៅក្នុងពេលដ៏ត្រឹមត្រូវ និងជាថ្មីម្ដងទៀតនៅជំនាន់ចុងក្រោយនេះ ព្រះអម្ចាស់បានសង្កត់ធ្ងន់លើគោលលទ្ធិដ៏ចាំបាច់របស់ទ្រង់អំពីឱកាសស្មើគ្នាសម្រាប់បុត្រាបុត្រីរបស់ទ្រង់ ។ ហើយប្រធានអ៊ូកបានរំឭកយើងអំពីការបង្រៀននេះមកពីព្រះគម្ពីរមរមន ៖ « [ ព្រះអម្ចាស់ ] ពុំបដិសេធអ្នកណាម្នាក់ ដែលមករកទ្រង់ឡើយ គឺទាំងខ្មៅ និងស ទាំងបាវគេ និងសេរី ទាំងប្រុស និងស្រី . . . មនុស្សទាំងអស់គឺដូចគ្នានៅចំពោះព្រះ » ។[៣]

នៅគ្រប់ទ្វីប និងនៅទូទាំងកោះនៃសមុទ្រមនុស្សស្មោះត្រង់កំពុងប្រមូលផ្ដុំគ្នាទៅក្នុង សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ភាពខុសគ្នារវាងវប្បធម៌ ភាសា ភេទ ពូជាសាសន៍ និងសញ្ជាតិ ពុំសំខាន់ដូចជា អ្នក ស្មោះត្រង់ចូលទៅក្នុងផ្លូវនៃសេចក្ដីសញ្ញា និងចូលមកកាន់ព្រះអង្គ ប្រោសលោះជាទីស្រឡាញ់របស់យើងឡើយ ។

ទីបំផុត យើងដឹងថា មានតែការយល់ដឹងអំពីសេចក្ដីពិតនៃ ភាពជា ព្រះបិតារបស់ព្រះប៉ុណ្ណោះ ដែលអាចនាំមកនូវអំណរគុណពេញលេញ នៃភាពជាបងប្អូនប្រុសពិតប្រាកដរបស់បុរស និងភាពជាបងប្អូនស្រីពិតប្រាកដរបស់ស្ត្រី ។ ការយល់ដឹងនោះបំផុស គំនិតយើងជាមួយនឹងក្ដី អាណិត អាសូរ ឲ្យមានបំណងប្រាថ្នាបង្កើតជាស្ពាននៃការសហការគ្នាជំនួសឲ្យជញ្ជាំងនៃការបែងចែកវណ្ណៈរវាងគ្នានឹងគ្នា » ។

វាជាការអធិស្ឋាន និងការប្រសិទ្ធពររបស់ខ្ញុំដែលខ្ញុំសូមបន្សល់ទុកលើអស់អ្នកដែលកំពុងស្ដាប់ថា យើងអាចយកឈ្នះលើបន្ទុកនានានៃភាពលំអៀង ហើយដើរដោយទៀងត្រង់ជាមួយព្រះ—និងជាមួយគ្នា—នៅក្នុងភាពសុខសាន្ត និងសុខដុមដ៏ល្អឥតខ្ចោះ ។ ■



« ទាំងខ្មៅ និងស ទាំងបាវគេ និងសេរី ទាំងប្រុស និងស្រី . . . មនុស្សទាំងអស់គឺដូចគ្នានៅចំពោះព្រះ » ។

**កំណត់ចំណាំ**

១. ម៉ាថាយ ២២:៣៦–៤០ ។
២. គោលលទ្ធិ និង សេចក្ដីសញ្ញា ៣៨:២៤–២៥ ។
៣. នីហ្វៃទី ២ ២៦:៣៣ ។



# ការផ្ដល់ការងារបម្រើ

## ដូចព្រះអង្គសង្គ្រោះបានធ្វើ

*នៅពេលអ្នកធ្វើឲ្យអស់ពីសមត្ថភាពរបស់អ្នកដើម្បីជួយអ្នកដទៃ នោះព្រះអង្គសង្គ្រោះនឹងបើកភ្នែករបស់អ្នកឲ្យមើលឃើញដោយសេចក្ដី ស្រឡាញ់ និងក្ដីអាណិតអាសូរ ។*

**ដោយ អ៊ីរិក ប៊ី ម៉ដុក**
ទស្សនាវដ្ដីសាសនាចក្រ

យើងទាំងអស់គ្នាស្គាល់ មិត្តភក្ដិដែលជួបប្រទះនឹងការនឿយហត់ ឬនរណាម្នាក់ដែលឯកោ ឬត្រូវបានគេសើចចំអកនៅសាលារៀន ។ ប្រហែលអ្នកបានឮអំពីនរណាម្នាក់នៅក្នុងវួដ ឬសាខារបស់អ្នកឆ្លងកាត់ឧបសគ្គដ៏ធ្ងន់ធ្ងរមួយ ។ នៅក្នុងគ្រាដូច្នេះ តើអ្នកអាចធ្វើអ្វីខ្លះ ?

ជួនកាល វាជាការពិបាកដើម្បីដឹងអំពីរបៀបដែលអ្នកអាចជួយគេ ។ វាអាចហាក់ដូចជាស្រួលជាងដើម្បីរង់ចាំនរណាម្នាក់ទៀតឲ្យចាត់វិធានការ ប៉ុន្តែមានអ្វីៗជាច្រើនដែល *អ្នក* អាចធ្វើ ទោះបីជាគ្រាន់តែឲ្យអស់អ្នកដែលនៅជុំវិញយើងដឹងថា អ្នកយកចិត្តទុកដាក់ក្ដី ។ ឱកាសទាំងអស់នោះគឺនៅជុំវិញយើង ហើយគ្រប់ពេលយើងបង្ហាញសេចក្ដីស្រឡាញ់ កង្វល់ និងចំណាប់អារម្មណ៍សម្រាប់អ្នកដទៃ នោះអ្នកកំពុងផ្ដល់ *ការងារបម្រើ* ហើយ ។

### ការងារបម្រើផ្ទាល់ខ្លួន

*ការងារបម្រើ* ។ អ្នកប្រហែលជាធ្លាប់ឮពាក្យនោះច្រើននៅព្រះវិហារមួយរយៈពេលចុងក្រោយនេះ ។ កាលពីមុន ជាទូទៅយើងនិយាយអំពីព្រះអង្គសង្គ្រោះ ឬពួកព្យាការី និងពួកសាវកមានការងារបម្រើ ប៉ុន្តែអ្នកមានឆ្ងល់ទេថា ប្រសិនបើ *អ្នក* មានការងារបម្រើផ្ទាល់ខ្លួននោះ ?

ដើម្បីផ្ដល់ការងារបម្រើមានន័យថា ស្រឡាញ់ និងមើលថែដល់អ្នកដទៃ ហើយធ្វើកិច្ចការគ្រប់បែបយ៉ាងដែលព្រះអង្គសង្គ្រោះនឹងធ្វើ ប្រសិនបើទ្រង់កំពុងគង់នៅក្នុងចំណោមយើងសព្វថ្ងៃនេះ ។ ការងារបម្រើគឺជារបៀបមួយដើម្បីជួយអ្នកដទៃឲ្យទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ និងបំពេញសេចក្ដីត្រូវការខាងវិញ្ញាណ និងខាងសាច់ឈាមរបស់ពួកគេ ។

> *ផ្ដល់ការងារបម្រើ*
> *មានន័យថា ស្រឡាញ់ និងមើលថែអ្នកដទៃ ។*

ព្រះយេស៊ូវ « បានមកមិនមែនឲ្យគេបម្រើទ្រង់ទេ គឺនឹងបម្រើគេវិញ » ( ម៉ាថាយ ២០:២៨ ) ។ ទ្រង់បានផ្ដល់ការងារបម្រើនៅពេលទ្រង់ « បានយាងចុះឡើងធ្វើកិច្ចការល្អ » ( កិច្ចការ ១០:៣៨ ) ។ ក្នុងនាមជាសិស្សទ្រង់ យើងត្រូវបានសុំឲ្យធ្វើតាមគំរូរបស់ទ្រង់ ។ យើង *ពិតជា* មានការងារបម្រើផ្ទាល់ខ្លួន !

ប៉ុន្តែអ្នកពុំចាំបាច់រៀបចំគម្រោងបម្រើធំដុំដើម្បីផ្ដល់ការងារបម្រើនោះទេ ។ ប្រធាន អិម. រ័សុល បាឡឺដ ប្រធានស្ដីទីក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានមានប្រសាសន៍ថា ៖ « ឱកាសបម្រើខ្លះគឺមានលក្ខណៈជាផ្លូវការ—ដូចជានៅក្នុងគ្រួសាររបស់យើង ការហៅរបស់យើងក្នុងសាសនាចក្រ និងការចូលរួមរបស់យើងក្នុងការបម្រើដល់សហគមន៍ ។ . . .

[ ប៉ុន្តែ ] មានឱកាសជាច្រើនដើម្បីបម្រើគឺពុំមែនជាឱកាសដែលបង្ហាញជាផ្លូវការទេ—គ្មានការចាត់តាំង—ហើយវាកើតមានកាលយើងឈោងទៅជួយមនុស្សដទៃដែលយើងជួបនៅក្នុងដំណើរនៃជីវិតនេះ ។[១]

ជារឿយៗ ការផ្ដល់ការងារបម្រើដូចជាព្រះគ្រីស្ទកើតឡើងនៅក្នុងទង្វើតូចតាច ស្មោះសរដែលអ្នកធ្វើរៀងរាល់ថ្ងៃ ។

### ម្ដងម្នាក់ៗ

នៅពេលព្រះអង្គសង្គ្រោះបានបង្ហាញព្រះកាយដល់ពួកសាសន៍នីហ្វៃ នោះទ្រង់បានប្រាប់ពួកគេគ្រប់គ្នាឲ្យមក ហើយស្ទាបស្ទាមនៅចំហៀងទ្រង់ និងនៅលើ



ព្រះហស្ត និងព្រះបាទាទ្រង់ ។ « ហើយពួកគេបានធ្វើយ៉ាងនេះ គឺបានដើរទៅមុខ *ម្តងម្នាក់ៗ* រហូតដល់ *ទាំងអស់គ្នា* បានទៅ » ( នីហ្វៃទី ៣ ១១:១៥ ការគូសបញ្ជាក់បានបន្ថែម ) ។

បន្ទាប់មក ទ្រង់បានអញ្ជើញពួកគេឲ្យនាំមនុស្សគ្រប់គ្នាដែលឈឺ, ឈឺចាប់ ឬ « ត្រូវរងទុក្ខដោយហេតុណាផ្សេងទៀត . . . ហើយទ្រង់បានប្រោសឲ្យជាសះស្បើយ *គ្រប់ៗគ្នា* នៅពេលពួកគេត្រូវនាំមករកទ្រង់ » ( នីហ្វៃទី ៣ ១៧:៧, ៩ ការគូសបញ្ជាក់បានបន្ថែម ) ។ បន្ទាប់ពីនោះមក ទ្រង់ « បានយកកូនក្មេងរបស់ពួកគេ *ម្តងម្នាក់ៗ* ហើយបានប្រទានពរដល់ពួកវា ហើយបានអធិស្ឋានដល់ព្រះវរបិតាសម្រាប់ពួកគេ » ( នីហ្វៃទី ៣ ១៧:២១ ការគូសបញ្ជាក់បានបន្ថែម ) ។

នេះពុំមែនជាក្រុមមនុស្សតិចតួចឡើយ ។ ព្រះគម្ពីរប្រាប់យើងថា មានប្រហែលជា ២៥០០ នាក់បាននៅទីនោះ ( សូមមើល នីហ្វៃទី ៣ ១៧:២៥ ) ។ ប៉ុន្តែព្រះអង្គសង្គ្រោះ *នៅតែ* ឆ្លៀតពេលព្យាបាលលួងលោម លើកទឹកចិត្ត និងបង្ហាញសេចក្តីស្រឡាញ់ដល់បុគ្គលគ្រប់រូប ។

> ***សេចក្តីស្រឡាញ់***
> *ដែលព្រះយេស៊ូវបង្ហាញដល់បុគ្គលម្នាក់គឺជាអ្វីដែលហៅថាការងារបម្រើ ។*

អែលឌើរ រ៉ូណាល អេ រ៉ាសបាន ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀនថា ៖ « មានសារលិខិតដ៏បំផុសគំនិត និងទន់ភ្លន់ផ្ទាល់ខ្លួននៅត្រង់នេះ ។ ព្រះយេស៊ូវគ្រីស្ទបានធ្វើការងារបម្រើដល់មនុស្ស ហើយស្រឡាញ់ពួកគេ—ម្តងម្នាក់ៗ » ។[២] សេចក្តីស្រឡាញ់ដែលព្រះយេស៊ូវបង្ហាញដល់បុគ្គលម្នាក់គឺជាអ្វីដែលហៅថាការងារបម្រើ ។

## បើកភ្នែកដើម្បីមើលឲ្យឃើញ

ព្រះអង្គសង្គ្រោះបានជួយអស់អ្នកដែលនៅជុំវិញទ្រង់ ។ ជីន ប៊ី ប៊ីងហាំ ប្រធានសមាគមសង្គ្រោះទូទៅបានថ្លែងថា « ទ្រង់បានញញឹម មានបន្ទូល យាងជាមួយ ស្តាប់ ចំណាយពេល លើកទឹកចិត្ត បង្រៀន ប្រទានអាហារ និងអភ័យទោស ។ ទ្រង់បានបម្រើដល់គ្រួសារ និងមិត្តភក្តិ អ្នកជិតខាង និងមនុស្សប្លែកមុខ ហើយទ្រង់បានអញ្ជើញអ្នកដែលស្គាល់ និងមនុស្សជាទីស្រឡាញ់ឲ្យរីករាយនឹងពរជ័យដ៏បរិបូរនៃដំណឹងល្អរបស់ទ្រង់ » ។[៣]

ព្រះយេស៊ូវគ្រីស្ទបើកព្រះនេត្រដើម្បីមើលឃើញតម្រូវការរបស់មនុស្សគ្រប់គ្នាដែលនៅជុំវិញទ្រង់ ហើយទ្រង់បានឈោងទៅជួយពួកគេទាំងអស់គ្នា ! យើងអាចធ្វើតាមគំរូរបស់ទ្រង់ ហើយឈោងទៅជួយអស់អ្នកដែលត្រូវការជំនួយពីយើង ។

ប៉ុន្តែព្រះអង្គសង្គ្រោះគឺល្អឥតខ្ចោះ ។ តើយើងអាចមើលឃើញតម្រូវការរបស់មនុស្សដទៃ និងផ្តល់ការងារបម្រើដូចទ្រង់ធ្វើយ៉ាងដូចម្តេច ? ប្រធានបាឡឺដបានថ្លែងថា ៖ « នៅក្នុងការអធិស្ឋានរៀងរាល់ព្រឹករបស់អ្នក សូមទូលសូមព្រះវរបិតាសួគ៌ឲ្យដឹកនាំអ្នក ដើម្បីឲ្យស្គាល់ឱកាសបម្រើកូនចៅដ៏មានតម្លៃណាម្នាក់របស់ទ្រង់ ។ រួចហើយសូមឲ្យដួងចិត្តអ្នកពេញទៅដោយសេចក្តីជំនឿ និងសេចក្តីស្រឡាញ់ពេញមួយថ្ងៃ ហើយស្វែងរកដើម្បីជួយដល់នរណាម្នាក់ ។ . . . ប្រសិនបើអ្នកធ្វើដូច្នេះ នោះការញាណដឹងខាងវិញ្ញាណរបស់អ្នកនឹងពង្រីកឡើង ហើយអ្នកនឹងរកឃើញឱកាសនានាដើម្បីបម្រើ ដែលអ្នកនឹងពុំធ្លាប់ដឹងថា អាចធ្វើបានពីមុនឡើយ » ។[៤]

## ធ្វើតាមការបំផុសគំនិត

សូមគិតអំពីស្ថានភាពនេះ ៖ អ្នកឃើញមិត្តភក្តិរបស់អ្នកនៅសាលារៀន ហើយមើលទៅគាត់ហាក់ដូចជាបាក់ទឹកចិត្ត ។ អ្នកមានអារម្មណ៍ថា អ្នកគួរតែធ្វើអ្វីមួយសម្រាប់គាត់ ប៉ុន្តែអ្នកបារម្ភថា អ្នកអាចនឹងរំខាន ឬធ្វើឲ្យគាត់ខ្មាសគេ ឬខ្មាសអ្នក ។ បន្ទាប់មកអ្នកចាប់ផ្តើមបារម្ភថា តើវាជាការបំផុសគំនិតខាងវិញ្ញាណ ឬជាគំនិតរបស់អ្នកផ្ទាល់ ។

ជួនកាល វាពិបាកដើម្បីដឹងថា អ្នកកំពុងទទួលការបំផុសគំនិតខាងវិញ្ញាណ ដើម្បីផ្តល់ការងារបម្រើ ឬវាជាគំនិតផ្ទាល់ខ្លួនរបស់អ្នក ប៉ុន្តែមរមនបង្រៀនយើងអំពីរបៀបទទួលស្គាល់ការបំផុសគំនិតខាងវិញ្ញាណដូច្នេះ ៖ « អ្វីដែលមកពីព្រះ អញ្ជើញ ហើយញុះញង់ឲ្យធ្វើល្អឥតឈប់ឈរ ហេតុដូច្នោះហើយ អ្វីក៏

ថតរូបដោយ VONECIA CARSWELL/UNSPLASH

ដោយដែលអញ្ជើញ ហើយញុះញង់ឲ្យធ្វើល្អ ហើយឲ្យស្រឡាញ់ព្រះ ហើយឲ្យបម្រើទ្រង់ គឺផុសគំនិតមកពីព្រះ » ( ម៉ូរ៉ូណៃ ៧:១៣ ) ។

ប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ ) បានមានប្រសាសន៍ថា « ប្រសិនបើយើងជាអ្នកសង្កេត និងដឹង ហើយប្រសិនបើយើងអនុវត្តតាមការបំផុសគំនិតដែលកើតមានចំពោះយើង នោះយើងអាចសម្រេចនូវកិច្ចការល្អៗជាច្រើន » ។[5]

## ការងារបម្រើគឺសម្រាប់មនុស្សគ្រប់គ្នា

អំឡុងពេលសន្និសីទទូទៅខែមេសា ឆ្នាំ ២០១៨ ប្រធាន រ័សុល អិម ណិលសុន បានប្រកាសថា ៖ « ព្រះអម្ចាស់បានធ្វើការកែតម្រូវដ៏សំខាន់នូវរបៀបដែលយើងមើលថែគ្នាទៅវិញទៅមក ។ បងប្អូនប្រុសស្រី—ទាំងចាស់ទាំងក្មេង—នឹងបម្រើគ្នាតាមរបៀបថ្មី ហើយកាន់តែបរិសុទ្ធ » ។[6] ការកែតម្រូវនេះរួមមានឱកាសជាច្រើនដើម្បីបម្រើនៅក្នុងភាពជាដៃគូនៃការងារបម្រើ ប៉ុន្តែការងារបម្រើពុំមែនគ្រាន់តែជាអ្វីដែលយើងធ្វើនៅថ្ងៃអាទិត្យ ឬអំឡុងពេលសកម្មភាពម៉ូតឆលនោះទេ ។ វាពុំមែនគ្រាន់តែជាការទទួលខុសត្រូវដែលកើតមកជាមួយនឹងការហៅបម្រើពិតប្រាកដណាមួយនោះទេ ។ ការងារបម្រើគឺសម្រាប់មនុស្សគ្រប់គ្នា ។ ការងារបម្រើគឺសម្រាប់គ្រប់ពេលវេលាទាំងអស់ ។

ពេលយើងទទួលបុណ្យជ្រមុជទឹក នោះយើងសន្យាថា « យល់ព្រមទទួលបន្ទុកគ្នាទៅវិញទៅមក ដើម្បីឲ្យបន្ទុកនោះបានស្រាល មែនហើយ [ ព្រម ] ទួញយំជាមួយនឹងអ្នកណាដែលទួញយំ មែនហើយ

> ប្រសិនបើយើងអនុវត្តតាមការបំផុសគំនិតដែលកើតមានចំពោះយើង នោះយើងអាចសម្រេចនូវកិច្ចការល្អៗជាច្រើន ។

ហើយកម្សាន្តទុក្ខដល់អស់អ្នកណាដែលកំពុងត្រូវការកម្សាន្តទុក្ខ » ( ម៉ូសាយ ១៨:៨–៩ ) ។ ការផ្តល់ការងារបម្រើដល់អ្នកដទៃគឺជាផ្នែកមួយនៃអ្វីដែលយើងបានសន្យានឹងធ្វើ ។

បូនី អិល. អូស្ការសុន អតីតប្រធានយុវនារីទូទៅបានមានប្រសាសន៍ថា « ព្រះអម្ចាស់មានព្រះទ័យចង់ឲ្យអ្នកមើលទៅមិត្តជុំវិញខ្លួនអ្នក រួចហើយទៅផ្តល់ការងារបម្រើដូចជាទ្រង់នឹងធ្វើ » ។[7] នៅពេលអ្នកធ្វើដូច្នេះ ទ្រង់នឹងបើកភ្នែកអ្នកឲ្យមើលឃើញ ជាមួយនឹងសេចក្តីស្រឡាញ់ និងសេចក្តីអាណិតអាសូរអំពីរបៀបដើម្បីបម្រើអ្នកដទៃ ។ ទ្រង់នឹងពុំទុកអ្នកឲ្យទាយពីអ្វីដែលអ្នកគួរតែធ្វើឡើយ ។ ទ្រង់នឹងដឹកនាំអ្នកក្នុងរបៀបដែលអ្នកអាចផ្តល់ការងារបម្រើបានល្អបំផុតដល់ពួកគេ ។

## ការផ្តល់ការងារបម្រើនាំមកនូវពរជ័យ

ប្រធានណិលសុនបានមានប្រសាសន៍ថា « ក្នុងនាមជាអ្នកបម្រើ [ របស់ព្រះអម្ចាស់ ] យើងនឹងផ្តល់ការងារបម្រើដល់មនុស្សម្នាក់ៗដូចជាទ្រង់បានធ្វើ » ។[8] នេះពុំមែនគ្រាន់តែជាការផ្តល់ពរដល់អ្នកដទៃឡើយ វាថែមទាំងផ្តល់ពរដល់យើងផងដែរ ។

អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា ៖ « នៅពេលយើងផ្តល់ជំនួយ និងដួងចិត្តយើងទៅកាន់អ្នកដទៃនៅក្នុងសេចក្តីស្រឡាញ់ដូចជាព្រះគ្រីស្ទ នោះអ្វីមួយអស្ចារ្យនឹងកើតឡើងចំពោះយើង ។ វិញ្ញាណរបស់យើងផ្ទាល់នឹងបានជាសះស្បើយកាន់តែត្រូវបានដុះខាត់ និងកាន់តែរឹងមាំ ។ យើងប្រែកាន់តែរីករាយ កាន់តែមានភាពសុខសាន្ត និងកាន់តែទទួលបានការខ្សឹបប្រាប់ពីព្រះវិញ្ញាណបរិសុទ្ធ » ។[9]

ព្រះយេស៊ូវគ្រីស្ទបានបង្ហាញផ្លូវដល់អ្នកមានម្នាក់ គឺជាជីវិតដែលកាន់តែមានការបំពេញកាតព្វកិច្ច ។ ការផ្តល់ការងារបម្រើដូចទ្រង់ធ្វើនឹងនាំមកនូវសុភមង្គលពិតប្រាកដ ព្រមទាំងស្មារតីមួយនៃភាពសុខសាន្ត និងអំណរមកកាន់ជីវិតរបស់អ្នក ។ ■



កំណត់ចំណាំ
1. អិម រ័សុល បាឡឺដ « អំណោយទានដ៏មានតម្លៃមកពីព្រះ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០ ។
2. រ៉ូណាល អេ រ៉ាសបាន « One by One » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០០ ទំព័រ ២៩ ។
3. ជីន ប៊ី ប៊ីងហាំ « ការងារបម្រើដូចដែលព្រះអង្គសង្គ្រោះបានធ្វើ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១០៤ ។
4. អិម រ័សុល បាឡឺដ « Be Anxiously Engaged » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១២ ទំព័រ ៣១ ។
5. ថូម៉ាស អេស ម៉នសុន « Three Goals to Guide You » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៧ ទំព័រ ១២១ ។
6. រ័សុល អិម ណិលសុន « ចូរយើងខិតខំទៅ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ១១៨ ។
7. បូនី អិល អូស្ការសុន « សេចក្តីត្រូវការនៅចំពោះយើង » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ២៦ ។
8. រ័សុល អិម ណិលសុន « ការបម្រើដោយព្រះចេស្តា និងសិទ្ធិអំណាចពីព្រះ » *Liahona* ខែ ឧសភា ឆ្នាំ ២០១៨ ទំព័រ ៦៩ ។
9. ឌៀថើរ អេស្វ អុជដូហ្វ « You Are My Hands » *Liahona* ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៧៥ ។

របៀប

# ប្រាំពីរ

យ៉ាងដើម្បីទទួលអារម្មណ៍នៃវិញ្ញាណ

# បុណ្យគ្រីស្ទម៉ាស់

ការរីកចម្រើន និងកម្មវិធីបុណ្យទានគឺមានភាពរីករាយ ប៉ុន្តែការផ្តល់ការងារបម្រើដោយរីករាយគឺជាគន្លឹះ ដើម្បីមានវិញ្ញាណនៃបុណ្យគ្រីស្ទម៉ាស់ ។

**ដោយ ឆាឡុត ឡាកាបាល**
ទស្សនាវដ្ដីសាសនាចក្រ

រចនារូបភាពដោយ ម៉ៃយល មូឡាន

« វា ហាក់ដូចជាពុំមែនជាបុណ្យគ្រីស្ទម៉ាស់ទេ » ។ តើអ្នកធ្លាប់គិតដូច្នេះដែរឬទេ ? ប្រហែលអ្នកមានអារម្មណ៍ដូច្នេះក្នុងពេលនេះ ៖ ទោះបីអ្នកចាក់បទចម្រៀងបុណ្យគ្រីស្ទម៉ាស់លាន់រំពងប៉ុណ្ណា ឬអ្នកបរិភោគនំបុណ្យគ្រីស្ទម៉ាស់ច្រើនប៉ុណ្ណានោះទេ អ្នកពុំទទួលអារម្មណ៍នៃវិញ្ញាណបុណ្យគ្រីស្ទម៉ាស់ឡើយ ។

ប្រសិនបើអ្នកមានអារម្មណ៍បែបនេះ ឬប្រសិនបើអ្នកគ្រាន់តែស្វែងរកថាអារម្មណ៍នៃបុណ្យគ្រីស្ទម៉ាស់នឹងមានច្រើនបន្តិចនាឆ្នាំនេះ សូមបន្តអានទៅមុខទៀត !

ប្រធាន ដាវីឌ អូ ម៉ាកខេ ( ១៨៧៣–១៩៧០ ) បានថ្លែងយ៉ាងសាមញ្ញថា ៖ « វិញ្ញាណនៃបុណ្យគ្រីស្ទម៉ាស់ជាវិញ្ញាណនៃព្រះគ្រីស្ទ ដែលធ្វើឲ្យចិត្តយើងរីករាយក្នុងក្ដីស្រឡាញ់និងមិត្តភាពជាបងប្អូន ហើយវាបំផុសយើងឲ្យធ្វើការបម្រើដោយសប្បុរស » ។[១] បូនី អិល. អូស្ការសុន អតីតប្រធានយុវនារីទូទៅថ្លែងថា ៖ « របៀបដើម្បីពង្រឹងស្មារតីនៃបុណ្យគ្រីស្ទម៉ាស់ គឺត្រូវជួយដល់អ្នកជុំវិញខ្លួនយើងដោយចិត្តសប្បុរស ហើយលះបង់ខ្លួន » ។[២]

ការតុបតែងដើមគ្រីស្ទម៉ាស់ និងការផ្ដល់អំណោយគឺជារបៀបដើម្បីសាទរបុណ្យគ្រីស្ទម៉ាស់ ប៉ុន្តែគន្លឹះដើម្បីទទួលអារម្មណ៍នៃវិញ្ញាណបុណ្យគ្រីស្ទម៉ាស់គឺផ្ដល់ការងារបម្រើដល់អ្នកដទៃ ។ ( សូមមើលអត្ថបទមុនដែលមានចំណងជើងថា « ការផ្ដល់ការងារបម្រើដូចព្រះអង្គសង្គ្រោះបានធ្វើ » ដើម្បីរៀនបន្ថែមទៀតអំពីការផ្ដល់ការងារបម្រើ ) ។

ហើយនេះជាព័ត៌មានល្អ ! មានមធ្យោបាយអស្ចារ្យជាច្រើនដើម្បីផ្ដល់ការងារបម្រើដល់អ្នកដទៃនៅរដូវកាលបុណ្យគ្រីស្ទម៉ាស់ ។ សូមសាកល្បងមធ្យោបាយមួយចំនួននេះ ហើយមិនយូរឡើយអ្នកនឹងទទួលអារម្មណ៍កក់ក្ដៅពីព្រះវិញ្ញាណ ហើយទទួលអារម្មណ៍កាន់តែស្និទស្នាលជាមួយព្រះអង្គសង្គ្រោះ—វិញ្ញាណពិតប្រាកដនៃបុណ្យគ្រីស្ទម៉ាស់ !



## ១. សួរសុខទុក្ខអ្នកឯកោ

សូមគិតពីបុគ្គលដែលអ្នកស្គាល់ ដែលពុំមានគ្រួសារ និងមិត្តភក្តិចំណាយពេលជាមួយពួកគេក្នុងរដូវបុណ្យនេះ ។ សូមគិតពីការទៅសួរសុខទុក្ខនរណាម្នាក់ដែលចាស់ជរា ឬនរណាម្នាក់ដែលប្ដូរទៅរស់នៅក្បែរអ្នក ។ ការឈោងទៅជួយបុគ្គលម្នាក់ដែលឯកោអាចជារឿងមួយដ៏មានឥទ្ធិពល ។ អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានចង្អុលបង្ហាញថា ព្រះគ្រីស្ទ « បានផ្ដល់ការងារបម្រើដល់ ‹ បុគ្គលម្នាក់ៗ › » តាមរយៈការជួយមនុស្សម្ដងម្នាក់ៗ ។[៣] យើងអាចធ្វើដូច្នោះបានផងដែរ ។

## ២. ទៅច្រៀងចម្រៀងបុណ្យគ្រីស្ទម៉ាស់ ។

តើអ្នកដឹងទេថា ព្យាការីរបស់យើងចូលចិត្តចម្រៀងបុណ្យគ្រីស្ទម៉ាស់ ? ទោះបីការច្រៀង« ឃ្លាឃ្លោងខ្លីប្លែកៗអំពីតាណូអែល » ឬច្រៀងដោយគារវភាពនូវទំនុកតម្កើងដែលអ្នកចូលចិត្តអំពីព្រះអង្គសង្គ្រោះក្ដី ប្រធាន រ័សុល អិម ណិលសុនជឿថា ការចែកចាយតន្ត្រីជាមួយអ្នកដទៃគឺជារបៀបដ៏អស្ចារ្យមួយដើម្បី « ទទួលអារម្មណ៍ពិតនៃវិញ្ញាណដ៏ពិតប្រាកដនៃបុណ្យគ្រីស្ទម៉ាស់ » ។[៤]





## ៣. សូមក្រឡេកមើលជុំវិញអ្នក ពីមុនអ្នកមើលទូរសព្ទរបស់អ្នក ។

អ្នកពុំចាំបាច់ដាក់ទូរសព្ទអ្នកនៅក្នុងហោប៉ៅរបស់អ្នកពេញមួយថ្ងៃឡើយ ប៉ុន្តែការមានវត្តមាន និងផ្ដោតចិត្តលើមនុស្សដែលនៅជុំវិញយើង គឺជាមធ្យោបាយមួយដ៏អស្ចារ្យដើម្បីទទួលអារម្មណ៍ម្ដងទៀតនៃវិញ្ញាណបុណ្យគ្រីស្ទម៉ាស់ ។

សីស្ទើរអូស្ការសុនបានថ្លែងថា « ជំនួសឲ្យការលើកទូរសព្ទអ្នកមកមើលថា តើមិត្តភក្តិអ្នកកំពុងធ្វើអ្វី ចូរឈប់ ហើយមើលជុំវិញខ្លួនអ្នក រួចសួរខ្លួនឯងថា ‹ តើនរណាត្រូវការខ្ញុំនៅថ្ងៃនេះ ? › អ្នកអាចជាមនុស្សសំខាន់ដើម្បីឈោងទៅជួយ ហើយមានឥទ្ធិពលលើជីវិតរបស់មិត្តម្នាក់ ឬផ្ដល់ការលើកទឹកចិត្តដល់មិត្តម្នាក់ដែលកំពុងមានបញ្ហាស្វាត់ៗនោះ » ។[៥]

## ៤. ធ្វើកិច្ចការមួយចំនួនថែមទៀត ។

តើការសម្អាតផ្ទះ ការអង្គុយមើលក្មេងៗ ឬធ្វើការងារផ្ទះបន្ថែមផ្សេងទៀតពិតជាអាចជួយអ្នកឲ្យទទួលវិញ្ញាណបុណ្យគ្រីស្ទម៉ាស់មែនឬ ? ប្រសិនបើអ្នកធ្វើវាដោយឥរិយាបថត្រឹមត្រូវ នោះអ្នកនឹងទទួលអារម្មណ៍នោះពិតប្រាកដ ! នៅពេលអ្នកសម្អាត ឬរៀបចំឲ្យមានសណ្ដាប់ធ្នាប់ សូមគិតអំពីបុគ្គលដែលអ្នកកំពុងបម្រើ ។ សូមគិតថា តើគ្រួសារ ឬមិត្តរបស់អ្នកនឹងចូលចិត្តអំណាយនៃការខិតខំធ្វើការរបស់អ្នកខ្លាំងប៉ុណ្ណា !





## ៥. ចែកនំបុណ្យគ្រីស្ទម៉ាស់មួយចំនួន !

និយាយអំពីនំបុណ្យគ្រីស្ទម៉ាស់ទាំងនោះដែលអ្នកបានបរិភោគកាលពីដំបូង ហេតុអ្វីអ្នកមិនធ្វើនំបុណ្យគ្រីស្ទម៉ាស់ដែលអ្នកចូលចិត្តមួយចំនួន ? អ្នកគួរតែភ្លក់វាពីរបី ( ឬច្រើន ) ប៉ុន្តែគន្លឹះដើម្បីទទួលអារម្មណ៍នៃវិញ្ញាណបុណ្យគ្រីស្ទម៉ាស់នៅត្រង់នេះ គឺត្រូវចែកវាឲ្យអ្នកដទៃ ។



## ៦. ចែកចាយវីដេអូបុណ្យគ្រីស្ទម៉ាស់ ។

សូមចែកចាយសារលិខិតបុណ្យគ្រីស្ទម៉ាស់នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ។ សូមមើលសារលិខិតពួកមរមនស្តីពីបុណ្យគ្រីស្ទម៉ាស់សម្រាប់យោបល់មួយចំនួន ។ អ្នកអាចធ្វើឲ្យអ្នកដទៃទៀតរីករាយ តាមរយៈការចែកចាយវីដេអូបុណ្យគ្រីស្ទម៉ាស់របស់សាសនាចក្រនៅលើគេហទំព័រ Mormon.org ។ អ្នកអាចផ្ញើវាទៅមិត្តភក្តិ ឬចែកចាយវានៅលើទំព័ររបស់អ្នកផ្ទាល់ ។

## ៧. ចូរមានការច្នៃប្រឌិតអំពីវា ។

តើមានការបម្រើសម្ងាត់អ្វីខ្លះដែលអ្នកអាចធ្វើ ដែលមនុស្សដទៃទៀតពុំដឹងនោះ ? អ្នកអាចទុកគ្រឿងទេស ឬអំណោយនៅទ្វារមុខផ្ទះរបស់នរណាម្នាក់ ដាក់ការសរសេរដ៏ផ្អែមល្ហែមមួយនៅក្នុងហោប៉ៅអាវ ចូកព្រិល ឬបោសសម្អាតស្លឹកឈើដែលជ្រុះ—ប៉ុន្តែសូមប្រាកដថា គ្មាននរណាម្នាក់ដឹងថា អ្នកធ្វើកិច្ចការនោះឡើយ ! សូមចាំថា ៖ ចូរឲ្យអំពើទានរបស់អ្នកបានស្ងាត់កំបាំង ( សូមមើល ម៉ាថាយ ៦:៤ ) ។



## ការផ្តល់ការងារបម្រើនៅបុណ្យគ្រីស្ទម៉ាស់

ពន្លឺភ្លើងនៃបុណ្យគ្រីស្ទម៉ាស់ និងការតាំងបង្ហាញជាសាធារណៈយ៉ាងអឹកធឹកអាចនាំមកនូវភាពអស្ចារ្យ និងរីករាយដល់ថ្ងៃបុណ្យរបស់អ្នក ប៉ុន្តែដើម្បីទទួលអារម្មណ៍ពិតប្រាកដនៃវិញ្ញាណបុណ្យគ្រីស្ទម៉ាស់ នោះការផ្តល់ការងារបម្រើដោយរីករាយគឺជាគន្លឹះ ។

អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « ដើម្បីផ្តល់កិត្តិយសពិតចំពោះការយាងមកក្នុងពិភពលោកនេះ [ របស់ព្រះអម្ចាស់ ] យើងត្រូវធ្វើដូចជាទ្រង់បានធ្វើ ហើយឈោងទៅជួយដោយសេចក្តីមេត្តាករុណាដល់បងប្អូនយើង ។ ការណ៍នេះយើងអាចធ្វើរាល់ថ្ងៃដោយពាក្យសម្ដី និងទង្វើ ។ ចូរឲ្យកិច្ចការនេះក្លាយជាទំនៀមទម្លាប់បុណ្យគ្រីស្ទម៉ាស់របស់យើង មិនថាយើងនៅទីណាទេ—ចូរយើងមានចិត្តល្អថែមបន្តិចទៀត អភ័យទោសឲ្យបានច្រើនជាងមុន កុំសូវកាត់សេចក្តីគេ មានអំណរគុណច្រើនជាងមុន និងមានសេចក្តីសប្បុរសកាន់តែច្រើនក្នុងការចែកចាយភាពសម្បូរណ៍របស់យើងជាមួយនឹងជនខ្វះខាត » ។[៦] ■


កំណត់ចំណាំ

១. ដាវីឌ អូ ម៉ាកខេ *Gospel Ideals* ( ១៩៥៣), ៥៥១ ។
២. បូនី អិល. អូស្ការសុន « Christmas Is Christlike Love » ( ការប្រជុំធម្មនិដ្ឋានបុណ្យគ្រីស្ទម៉ាស់គណៈប្រធានទីមួយ ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៤ ) គេហទំព័រ broadcasts.lds.org ។
៣. គេហទំព័រហ្វេសប៊ុករបស់ ដេវីឌ អេ បែដណា វីដេអូដែលបានបង្ហោះនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៧ គេហទំព័រ facebook.com/lds.david.a.bednar/videos ។
៤. វ៉េសុល អិម ណិលសុន នៅក្នុង « Christmas Memories from Prophets and Apostles » *New Era* ខែ ធ្នូ ឆ្នាំ ២០១៥ ទំព័រ ១០ ។
៥. បូនី អិល អូស្ការសុន « សេចក្តីត្រូវការនៅចំពោះយើង » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ២៦ ។
៦. ឌៀថើរ អេស្វ អុជដូហ្វ « Scatter Your Crumbs » ( ការប្រជុំធម្មនិដ្ឋានបុណ្យគ្រីស្ទម៉ាស់គណៈប្រធានទីមួយ ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៧ ) គេហទំព័រ broadcasts.lds.org ។

### ការបន្ថែម

# អំណោយនៃព្រះវិញ្ញាណ

### ទៅលើបញ្ជីនៃបុណ្យគ្រីស្ទម៉ាស់របស់អ្នក

**ដោយ ដេវីឌ ឌីកសុន**
ទស្សនាវដ្ដីសាសនាចក្រ



ខ្ញុំតែងតែធ្វើនំសាំងវិចដ៏ឆ្ងាញ់ ។ រវាងនំដ៏មានរសជាតិនោះ និងការធ្វើម្ហូបជាច្រើនផ្សេងទៀត ខ្ញុំបានរក្សាខ្លួនខ្ញុំឲ្យមានភាពរស់រវើក និងសកម្មពេញមួយបេសកកម្មរបស់ខ្ញុំ និងបន្តរឹងមាំនៅក្នុងមជ្ឈិមវ័យ ។ ប៉ុន្តែក្រោយមក ខ្ញុំបានរៀបការ ហើយមានកូន ដែលពួកយើងទាំងអស់គ្នាមានចំណូលចិត្តផ្សេងៗគ្នា ។ ខ្ញុំត្រូវពង្រីកបញ្ជីម្ហូបរបស់ខ្ញុំ !

ប៉ុន្តែ នាយប់មួយជាវេនខ្ញុំត្រូវធ្វើម្ហូប ការចង់ធ្វើម្ហូបថ្មីគឺជាការដ៏លំបាកសម្រាប់ខ្ញុំ ។ ដំបូង ពេលវេលានៅពេលល្ងាចរបស់ខ្ញុំគឺជាទូទៅមានកំណត់ ។ ទោះបីខ្ញុំចង់ចំអិនអាហារច្រើនមុខក្ដី ខ្ញុំបានបន្តមានបញ្ហា ។ ខ្ញុំពុំអាចរកឃើញគ្រឿងផ្សំបានលឿនគ្រប់គ្រាន់ ឬយើងនឹងខ្វះគ្រឿងផ្សំមួយចំនួន ។ ជារឿយៗ ខ្ញុំផ្លាស់ប្ដូរផែនការអាហារពេលល្ងាចរបស់ខ្ញុំ ហើយជំនួសដោយការចំអិនអ្វីដែលលឿន និងងាយស្រួលវិញ ។

ប៉ុន្តែខ្ញុំចង់បន្តកែលម្អត្រង់ចំណុចនេះ ។ ដូច្នេះខ្ញុំបានសម្រេចចិត្តធ្វើអ្វីមួយដែលខ្ញុំពុំធ្លាប់បានធ្វើពីមុន ។ ខ្ញុំបានអធិស្ឋានទូលសូមអំណោយទានខាងវិញ្ញាណតាមឈ្មោះ ។

គំនូរព្រាងដោយ ជេស ថាលប៉ុត

## អំណោយទានមួយ ប៉ុន្តែមានមនុស្សជាច្រើនប្រើប្រាស់វា

ជាពិសេស ខ្ញុំបានអធិស្ឋានទូលសូមអំណោយទាននៃការរៀបចំ ។ មែនហើយ ការរៀបចំ ! យើងមានទូរដាក់គ្រឿងទេសហើយ ។ យើងក៏មានថតដាក់ឧបករណ៍ស្លរស្លុកផងដែរ ។ ប៉ុន្តែទោះបីមានអ្វីៗទាំងនោះក្តី ខ្ញុំហាក់ដូចជាចំណាយពេលច្រើនទៀតដើម្បីរកមើលគ្រឿងបរិក្ខារនានាជាជាងការចំអិនអាហារ ។

នៅពេលខ្ញុំបន្តអធិស្ឋានទូលសូមអំណោយទាននេះ ខ្ញុំបានចាប់ផ្តើមទទួលគំនិតជាក់លាក់ ។ ធ្នើរដាក់គ្រឿងទេសដែលនៅជាប់នឹងជញ្ជាំងទុកដាក់គ្រឿងទេស ហើយទុកវានៅជិតដៃ ។ បន្ទះដែកឆក់សម្រាប់ព្យួរកំបិត ( ក៏នៅជាប់នឹងជញ្ជាំង ) អាចដាក់កាំបិត និងឧបករណ៍ស្លរស្លុកផ្សេងទៀតដែលធ្វើពីដែក ។ នៅពេលបានប្រើប្រាស់គំនិតទាំងនេះ និងគំនិតផ្សេងទៀត នោះធ្វើឲ្យមានភាពខុសប្លែកដ៏ខ្លាំងនៅក្នុងការចំអិនអាហាររបស់ខ្ញុំ ។ ត្រូវការជីខ្លះឬ ? ម្សៅអំបិលខ្ទឹមសឬ ? ម្សៅ *ខ្ទឹមស* ឬ ? ខ្ញុំងាយនឹងរកវាឃើញឲ្យអ្នកណាស់ !

ប៉ុន្តែក្រោយមក មានអ្វីមួយដែលគួរឲ្យចង់សើចបានកើតឡើង ។ គំនិតតូចៗបានបន្តផុសឡើងក្នុងចិត្តខ្ញុំ ចំពោះមធ្យោបាយតូចតាចនានាដើម្បីរៀបចំចំណុចនានានៅក្នុងជីវិតខ្ញុំឲ្យបានប្រសើរឡើង ។ ឧទាហរណ៍ ធ្នើរបីជាន់ដែលធ្វើដោយដៃនៅក្នុងបន្ទប់បោកគក់ដែលខ្ញុំធ្វើ ពុំអាចនាំគ្រួសារខ្ញុំទៅកាន់ដែនដីសន្យាបានឡើយ ប៉ុន្តែសូម្បីតែនីហ្វៃក៏នឹងមានអំណរគុណចំពោះរបៀបដែលខ្ញុំបានធ្វើនេះដែរ — ប៉ុន្តែតាមរយៈការធ្វើតាមការបំផុសគំនិតដែលកើតមានចំពោះខ្ញុំម្តងមួយៗ នោះនឹងនាំខ្ញុំទៅដែនដីសន្យា ។

អំណោយទានខាងវិញ្ញាណនៃការរៀបចំ បានធ្វើឲ្យជីវិតរបស់ខ្ញុំ និងជីវិតគ្រួសារខ្ញុំបានប្រសើរឡើង ជាងអ្វីដែលខ្ញុំធ្លាប់ទស្សន៍ទាយទៅទៀត ។

ហើយវាបានមក ដោយសារខ្ញុំបានទូលសូម ។

## អំណោយទានច្រើន ប៉ុន្តែមានអ្នកសូមតែបន្តិចបន្តួច

សាវកប៉ុលបានបង្រៀនពួកកូរិនថូសអំពីអំណោយទានខាងវិញ្ញាណមួយចំនួនទៀតផ្សេងទៀតជាច្រើនដែលមាន ដូចជាជំនឿ ឬការព្យាបាល ( សូមមើល កូរិនថូសទី ១ ១២:៥–១១ ) ។ បន្ទាប់មក លោកបានបង្គាប់ពួកគេឲ្យ « សង្វាតឲ្យបានអំណោយទាន យ៉ាងវិសេសទៅចុះ » ( កូរិនថូសទី ១ ១២:៣១ ) ។

វាអាចពិបាកក្នុងការយល់ថា គំនិតដែលសង្វាតឲ្យបានអំណោយទានអាចជារឿង *ល្អ* ប៉ុន្តែនៅក្នុងករណីនេះវាអាចជារឿងល្អ ។ យើងត្រូវបានបង្គាប់ឲ្យស្វែងរកអំណោយទានខាងវិញ្ញាណមួយចំនួន ដែលយើងឃើញនៅក្នុងមនុស្សដទៃ ហើយទូលសូមព្រះឲ្យប្រទានពរដល់យើងនូវអំណោយទានដូចគ្នានេះ ។ សេចក្តីសង្ឃឹមរបស់យើងក្នុងការធ្វើដូច្នោះ គួរតែដើម្បីបម្រើអ្នកដទៃ និងស្ថាបនានគរព្រះឲ្យកាន់តែល្អប្រសើរឡើង ( សូមមើល គ. និង ស. ៤៦:២៦–២៩ ) ។

មានអំណោយទានជាច្រើន — មានច្រើនជាងដែលអ្នកឃើញនៅក្នុងព្រះគម្ពីរទៅទៀត ។ ការអត់ធ្មត់គឺជាអំណោយទានខាងវិញ្ញាណមួយ ។ ភាពសុទ្ធិដ្ឋិនិយមក៏ដូច្នោះដែរ ។ ព្រមទាំងការមានចិត្តក្លាហាន ។ និងការធ្វើជាអ្នកផ្សះផ្សាគេ ។ អែលឌើរ លែរី អរ ឡូរិន ក្នុងពួកចិតសិបនាក់បានបង្រៀនថា ៖ « ជួលកាល ខ្ញុំស្រមៃឃើញឃ្លាំងដ៏ធំមួយនៅលើស្ថានសួគ៌ ដែលពោរពេញទៅដោយអំណោយទានខាងវិញ្ញាណ ដែលមានសម្រាប់ពួកបរិសុទ្ធទាំងអស់ ដែលមានសេចក្តីជំនឿទូលសូមអំណោយទានទាំងនោះ ។ ជាអកុសល ពុំមានមនុស្សច្រើនទេដែលបានទូលសូម ដូច្នេះឃ្លាំងនោះមានលើសស្តុកជានិច្ច » ។[1]

អែលឌើរឡូរិនបានពិពណ៌នាអំពីមិត្តម្នាក់ដែលបានសម្រេចចិត្តអធិស្ឋានទូលសូមអំណោយទាននៃសេចក្តីសប្បុរស ។ គាត់បានតំណាលប្រាប់ពីបទពិសោធន៍របស់នាងថា ៖ « នាងបានសរសេរថា ៖ ‹ ខ្ញុំបានអធិស្ឋានទូលសូមជាពិសេសនូវការកើនឡើងនៃសេចក្តីសប្បុរសអស់រយៈពេលជាច្រើនខែ ។ . . . ការយល់ដឹងរបស់ខ្ញុំអំពីមនុស្សដទៃបានផ្លាស់ប្តូរដោយសន្សឹមៗ ។ . . . ខ្ញុំមិនត្រឹមតែបានចាប់ផ្តើមស្រឡាញ់មនុស្សដែលនៅជុំវិញខ្ញុំប៉ុណ្ណោះទេ ខ្ញុំថែមទាំងរីករាយជាមួយពួកគេផងដែរ ។ ពីមុន ខ្ញុំបានផ្តាច់ខ្លួននៅតែឯង ប៉ុន្តែឥឡូវខ្ញុំចាប់អារម្មណ៍លើមនុស្សគ្រប់គ្នាដោយស្មោះសរ » ។[2]

## តាំងរួចរាល់ និងការរង់ចាំនៃអំណោយទានរបស់អ្នក

អំណោយទានខាងវិញ្ញាណគឺមានតម្លៃច្រើនជាងអំណោយដែលអាចមើលឃើញផ្ទាល់ទៅទៀត ។ ប្រាកដណាស់ វាជាអំណោយទានដ៏ *ល្អបំផុត* ។ យើងត្រូវបានត្រាស់បង្គាប់នៅក្នុងព្រះគម្ពីរថា « ព្យាយាមស្វែងរកអំណោយទាននានាដែលវិសេសបំផុតចុះ » ( គ. និង ស. ៤៦:៨ ) ។

ទោះអ្វីក៏ដោយដែលអ្នកសង្ឃឹមថា បើកឃើញនៅព្រឹកនៃថ្ងៃបុណ្យគ្រីស្ទម៉ាស់ក្តី សូមព្យាយាម និងស្រមៃគិតអំពី « អំណោយទានដែលវិសេសបំផុត » ដែលទន្ទឹងរង់ចាំអ្នកផងដែរ ។ អំណោយទានទាំងនោះ « បានខ្ចប់ » រួចជាស្រេច ហើយត្រៀមរួចរាល់ដើម្បីផ្តល់ពរដល់អ្នក និងអស់អ្នកដែលនៅក្បែរអ្នក ។

ដូច្នេះសូមបន្តទៅមុខ ហើយទូលសូម ។ ■

**កំណត់ចំណាំ**

១. លែរី អរ ឡូរិន « តើនៅខ្វះអ្វីទៀត ? » ( ការប្រជុំធម្មនិដ្ឋានសាកលវិទ្យាល ព្រិកហាំ យ៉ង់ – អៃដាហូ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ ) គេហទំព័រ byui.edu/devotionalsandspeeches ។

២. លែរី អរ ឡូរិន « តើនៅខ្វះអ្វីទៀត ? »



# « ខ្ញុំពុំមានអារម្មណ៍ថាសក្តិសមដើម្បីទទួលបានសេចក្តីស្រឡាញ់ពីព្រះអង្គសង្គ្រោះឡើយ ។ តើខ្ញុំអាចយកឈ្នះលើអារម្មណ៍នេះ ហើយស្គាល់តម្លៃរបស់ខ្លួនឯងតាមរបៀបណា ? »

*« សេចក្តីស្រឡាញ់របស់ព្រះគឺមាននៅទីនោះសម្រាប់អ្នក ទោះបីអ្នកទទួលអារម្មណ៍ ឬមិនទទួលអារម្មណ៍ថា អ្នកសមនឹងទទួលសេចក្តីស្រឡាញ់នោះដែរ ឬអត់ក្តី ។ សេចក្តីស្រឡាញ់គឺមានវត្តមាននៅទីនោះជានិច្ច ។*

*« នៅពេលយើងស្វែងរកព្រះវរបិតាសួគ៌យើងតាមរយៈការអធិស្ឋានដោយចិត្តស្មោះសរ និងពិតប្រាកដ សិក្សាព្រះគម្ពីរដោយការលះបង់ នោះទីបន្ទាល់របស់យើងនឹងរឹងមាំ ហើយចាក់ឫសកាន់តែជ្រៅ ។ យើងនឹងដឹងអំពីសេចក្តីស្រឡាញ់របស់ព្រះដែលមានចំពោះយើង » ។*

ប្រធាន ថូម៉ាស អេស ម៉នសុន ( ១៩២៧–២០១៨ )
« We Never Walk Alone » *Liahona*
ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ១២៤ ។



អធិស្ឋានដើម្បីទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់របស់ទ្រង់ យើងទាំងអស់គ្នាគឺជាបុត្រាបុត្រីរបស់ព្រះវរបិតាសួគ៌យើង ។ សេចក្តីស្រឡាញ់របស់ទ្រង់ចំពោះយើងគឺគ្មានដែនកំណត់ ។ ប្រសិនបើយើងធ្លាប់មានអារម្មណ៍ថា យើងគ្មានភាពសក្តិសមនឹងសេចក្តីស្រឡាញ់របស់ទ្រង់ នោះយើងគួរតែអធិស្ឋានទៅកាន់ទ្រង់ ។ អធិស្ឋានដើម្បីទទួលអារម្មណ៍នៃសេចក្តីស្រឡាញ់របស់ទ្រង់ ។ អធិស្ឋានថា អ្នកនឹងទទួលអារម្មណ៍នៃភាពសក្តិសមចំពោះសេចក្តីស្រឡាញ់របស់ទ្រង់សម្រាប់អ្នក ហើយថាអ្នកអាចឃើញខ្លួនអ្នក ដូចទ្រង់ទតឃើញអ្នក ។ ទ្រង់នឹងឆ្លើយតបការអធិស្ឋានរបស់យើងដោយសេចក្តីសន្តោសប្រណីនៃសេចក្តីស្រឡាញ់ដ៏ឥតខ្ចោះរបស់ទ្រង់ជានិច្ច ទៅតាមពេលវេលា និងរបៀបរបស់ទ្រង់ ។ នៅពេលណាដែលខ្ញុំមានអារម្មណ៍បាក់ទឹកចិត្ត ឬឯកោ ការអធិស្ឋានទូលសូមសេចក្តីស្រឡាញ់របស់ទ្រង់បានលើកស្ទួយចិត្តខ្ញុំជានិច្ច ។

*ជូលី អិម អាយុ ១៦ ឆ្នាំ រដ្ឋវើជីញ៉ា ស.រ.អា.*



ខិតទៅជិតព្រះអង្គសង្គ្រោះ ថ្មីៗនេះ នៅក្នុងថ្នាក់ត្រៀមខ្លួនទៅបម្រើបេសកកម្ម យើងបានពិភាក្សាអំពីរបៀបដែលយើងអាចមើលឃើញសេចក្តីស្រឡាញ់របស់ព្រះដែលមានចំពោះយើង ។ យើងបានពិភាក្សានូវរឿងជាច្រើន ដែលយើងអាចធ្វើដើម្បីទទួលអារម្មណ៍កាន់តែផ្តល់តម្លៃលើខ្លួនឯង រឿងទាំងនោះរួមមាន ការបម្រើអ្នកជិតខាង ការអធិស្ឋានសូមជំនួយលើរឿងដែលសំខាន់ចំពោះអ្នក ការអានព្រះគម្ពីរ និងការធ្វើជាអ្នកផ្សព្វផ្សាយសាសនា ។ កិច្ចការទាំងអស់នេះមានបំណងនាំយើងឲ្យខិតកាន់តែជិតព្រះយេស៊ូវគ្រីស្ទ ហើយជួយយើងឲ្យមើលឃើញសក្តានុពលដើម្បីប្រែក្លាយដូចជាទ្រង់ ។

*សាន់ទីអាហ្គោ ស៊ី អាយុ ១៧ ឆ្នាំ រដ្ឋអារីហ្សូណា ស.រ.អា.*

# ខ្ញុំបានប្រែចិត្ត ប៉ុន្តែខ្ញុំនៅតែមានអារម្មណ៍ថាខុសឆ្គងយ៉ាងខ្លាំង ។ តើខ្ញុំអាចមានភាពសុខសាន្តដោយរបៀបណា ?

ដោយសារដង្វាយធួនដ៏ឥតដែនកំណត់របស់ព្រះយេស៊ូវគ្រីស្ទ នោះកំហុសឆ្គងរបស់អ្នកអាចត្រូវបានសម្អាតចេញ ប្រសិនបើអ្នកប្រែចិត្តទាំងស្រុង ។ ប៉ុន្តែជួនកាលមនុស្សនៅតែមានអារម្មណ៍នៃការខុសឆ្គងដោយនឹកឃើញអំពើបាបរបស់ពួកគេ ទោះបីជាពួកគេបានប្រែចិត្តហើយក្តី ។

កំហុសឆ្គង ឬ « សេចក្តីព្រួយដែលគាប់ព្រះហឫទ័យដល់ព្រះ » ( កូរិនថូសទី ២ ៧:១០ ) អាចមានប្រយោជន៍ ។ វាអាចផ្តោតគំនិតយើងទៅលើព្រះយេស៊ូវគ្រីស្ទ ហើយដឹកនាំយើងឲ្យប្រែចិត្ត និងផ្លាស់ប្តូរពិតប្រាកដ ។ ផ្ទុយទៅវិញ សេចក្តីខ្មាសគឺវាផ្តោតទៅលើគំនិតរបស់យើងលើខ្លួនឯង ហើយបង្អង់ការរីកចម្រើនរបស់យើង ។

ព្រះគម្ពីរមរមនផ្តល់គំរូល្អដល់យើងអំពីរបៀបដែលយើងអាចប្រែចិត្ត ហើយបន្ទាប់មករីករាយដោយសុខសាន្តនៅក្នុងព្រះយេស៊ូវគ្រីស្ទ ៖

- ដោយចងចាំអំពើបាបពីអតីតកាលរបស់លោក បានបណ្តាលឲ្យអាំម៉ូនសរសើរតម្កើងដល់ព្រះអង្គសង្គ្រោះ និងសេចក្តីមេត្តាករុណារបស់ទ្រង់ ដោយនាំគាត់ឲ្យមានអំណរ ជាជាងការរងទុក្ខ ( សូមមើល អាលម៉ា ២៦:១៧–២០ ) ។[១]
- បន្ទាប់ពីអាលម៉ា « បាននឹកគិត » អំពីព្រះយេស៊ូវគ្រីស្ទ និងដង្វាយធួនរបស់ទ្រង់ នោះលោក « ក៏អស់កើតទុក្ខដោយការនឹកឃើញអំពើបាប [ របស់លោក ] តទៀតទៅ » ( អាលម៉ា ៣៦:១៧–១៩ ) ។ ទោះបីលោកនឹកឃើញរឿងនោះក្តី វាពុំបានធ្វើឲ្យលោកឈឺចាប់ទេ ។[២]

កំណត់ចំណាំ

១. សូមមើល រីឆាដ ជី ស្កុត « Peace of Conscience and Peace of Mind » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០០៤ ទំព័រ ១៨ ។
២. សូមមើល ឌៀថើរ អេហ្វ អុជដូហ្វ « Point of Safe Return » *Liahona* ខែ ឧសភា ឆ្នាំ ២០០៧ ទំព័រ ១០១ ។



### គោរពតាមព្រះបញ្ញត្តិ

ជួនកាល ខ្ញុំមានអារម្មណ៍ថា ពុំសក្តិសមដើម្បីទទួលបានសេចក្តីស្រឡាញ់ពីព្រះអង្គសង្គ្រោះឡើយ ដោយសារខ្ញុំពុំបានគោរពប្រតិបត្តិតាមបទបញ្ញត្តិរបស់ព្រះអម្ចាស់បានទាំងស្រុងឡើយ ។ ខ្ញុំអាចយកឈ្នះលើអារម្មណ៍ទាំងនេះតាមរយៈការប្រែចិត្ត ជួនកាលដោយមានជំនួយពីប៊ីស្សពរបស់ខ្ញុំ ដែលបង្រៀនខ្ញុំថាព្រះអម្ចាស់ស្រឡាញ់បុត្រាបុត្រីទាំងអស់របស់ទ្រង់ ។

***ចាកឃ្វី ឌី អាយុ ១៥ ឆ្នាំ ទីក្រុងអាប៊ីដចាន ប្រទេសកូតឌីវ័រ***

### ការប្រែចិត្តគឺជាគន្លឹះ

យើងទាំងអស់គ្នាប្រព្រឹត្តអំពើបាប ហើយដោយសាររឿងនោះ យើងអាចមានអារម្មណ៍ពុំសក្តិសមចំពោះសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ។ ប៉ុន្តែទ្រង់បានថ្វាយព្រះជន្មទ្រង់សម្រាប់យើង — ទ្រង់បានបូជាសម្រាប់យើង ។ ទង្វើដែលមិនគិតពីខ្លួនឯងនោះបានធ្វើឡើង ដោយសារតែសេចក្តីស្រឡាញ់ ។ រឿងតែមួយគត់ដែលយើងចាំបាច់ត្រូវធ្វើដើម្បីទទួលអារម្មណ៍ថា សក្តិសមនឹងសេចក្តីស្រឡាញ់របស់ទ្រង់នោះគឺ ប្រើអំណាចនៃដង្វាយធួនរបស់ទ្រង់តាមរយៈការប្រែចិត្តពីអំពើបាបរបស់យើង ។ ការប្រែចិត្តគឺជាគន្លឹះនៅក្នុងការទទួលស្គាល់តម្លៃរបស់យើង និងសេចក្តីស្រឡាញ់របស់ព្រះអង្គសង្គ្រោះ ។

***ស៊ីស្ទើរ ខុសស្វែន អាយុ ២៣ ឆ្នាំ បេសកកម្មហ្វីលីពីន សេប៊ូ***

### ស្រឡាញ់មនុស្សដទៃ

របៀបមួយដើម្បីទទួលស្គាល់ភាពមានតម្លៃរបស់ខ្លួនគឺ ទទួលស្គាល់ភាពមានតម្លៃរបស់មនុស្សដែលនៅជុំវិញខ្លួនយើង ។ ការផ្តោតចិត្តទុកដាក់ទៅលើអ្នកដទៃជួយយើងឲ្យទទួលអារម្មណ៍ល្អអំពីខ្លួនយើង ដោយសារយើងកំពុងស្ថាបនាមនុស្សដទៃឡើង ។ វាគឺជាយុទ្ធសាស្ត្រឈ្នះៗ ! ពេលខ្ញុំមានការស្មុគស្មាញនឹងការមានទំនុកចិត្តលើខ្លួនឯង នោះខ្ញុំបានសម្រេចចិត្តថា ខ្ញុំនឹងបម្រើនរណាម្នាក់នៅជុំវិញខ្ញុំដែលត្រូវការជំនួយ ។ រៀងរាល់ថ្ងៃអស់រយៈពេលមួយខែ ខ្ញុំបានកោតសរសើរដល់មិត្តម្នាក់ដែលកំពុងមានបញ្ហា ។ ការផ្តោតចិត្តទុកដាក់លើអ្នកដទៃបានជួយខ្ញុំឲ្យមានអារម្មណ៍ថា សក្តិសម និងមានគេត្រូវការខ្ញុំ ។ ពេលយើងព្យាយាមស្រឡាញ់មនុស្សដទៃទោះបីគេជាមនុស្សបែបណាក្តី នោះវាប្រែកាន់តែងាយស្រួលដើម្បីមើលឃើញពីសេចក្តីស្រឡាញ់ដ៏ធំធេងដែលព្រះ មានសម្រាប់ពួកយើង ។ ការជួយមនុស្សដទៃឲ្យទទួលអារម្មណ៍សក្តិសមចំពោះសេចក្តីស្រឡាញ់ នឹងជួយយើងឲ្យមានអារម្មណ៍សក្តិសមនឹងសេចក្តីស្រឡាញ់ចំពោះខ្លួនឯង ។

***ដេមី ដបុលយូ អាយុ ១៥ ឆ្នាំ រដ្ឋមីនីសូតា ស.រ.អា.***

*ការឆ្លើយតបទាំងឡាយធ្វើឡើងក្នុងគោលបំណងទុកជាជំនួយ និងទស្សនវិស័យមិនមែនជាការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*

រូបថតមកពី BRYAN-MINEAR-316499/UNSPLASH

***តើអ្នកគិតដូចម្តេច ?***

## « តើខ្ញុំសម្រេចចិត្តបម្រើបេសកកម្មដោយរបៀបណា ? »

ប្រសិនបើអ្នកមានបំណងឆ្លើយនឹងសំណួរនេះ សូមបញ្ជូនចម្លើយរបស់អ្នក និងរូបថតមានគុណភាពច្បាស់មួយសន្លឹកឲ្យបានត្រឹមថ្ងៃទី១៥ ខែ មករា ឆ្នាំ ២០១៩ ទៅកាន់គេហទំព័រ liahona.lds.org ( សូមចុច « Submit an Article or Feedback » ) ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ ប្រសិនបើវាវែងពេក ឬមិនសូវច្បាស់លាស់ ។

# ការប្រសូតរបស់ព្រះអង្គសង្គ្រោះ

គឺជាអំណោយដែល

# អាចធ្វើឲ្យ ព្រះវរបិតាប្រទាន

« សេចក្ដីសុខសាន្តនាលោកិយនេះ និងជីវិតដ៏នៅអស់កល្បជានិច្ច នៅបរលោកនាយ » ដល់យើង [ គ. និង ស. ៥៩:២៣ ] ។

ប្រធាន ហិនរី ប៊ី អាវរិង
ទីប្រឹក្សាទីមួយក្នុងគណៈប្រធានទីមួយ
« អំណោយនៃភាពសុខសាន្ត » ( ការប្រជុំធម្មនិដ្ឋានបុណ្យគ្រីស្ទម៉ាសរបស់គណៈប្រធានទីមួយ ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៦ )



រូបថតមកពី GETTY IMAGES



# ចូលបម្រើក្នុង កងទ័ពយុវវ័យរបស់ព្រះអម្ចាស់ ដើម្បីជួយប្រមូលវង្សអ៊ីស្រាអែល

ខ្ញុំសូមអញ្ជើញប្អូនៗឲ្យរៀបចំខ្លួន ដោយធ្វើ . . . **កិច្ចការប្រាំយ៉ាង**ដែលនឹងផ្លាស់ប្ដូរប្អូនៗ ហើយជួយប្អូនៗផ្លាស់ប្ដូរពិភពលោក ។



**១.** តមកុំមើលប្រព័ន្ធផ្សព្វផ្សាយសង្គមរយៈពេលប្រាំពីរថ្ងៃ ។

**២.** **ធ្វើការលះបង់ពេលវេលា** មួយប្រចាំសប្ដាហ៍ថ្វាយព្រះអម្ចាស់ ។





**៣.** ចូរបន្តនៅលើផ្លូវនៃ**សេចក្ដីសញ្ញា** ។

**៤.** **សូមអធិស្ឋាន**ប្រចាំថ្ងៃដើម្បីឲ្យមនុស្សទាំងអស់អាចទទួលបានពរជ័យនៃដំណឹងល្អ ។





**៥.** ចូរឈរឲ្យខ្ពស់ឡើង ។ ចូរមានភាពខុសប្លែកពីគេ ។ **ចូរធ្វើជាពន្លឺ** ។

ប្រធាន រ័សុល អិម ណិលសុន « សង្ឃឹមអ៊ីស្រាអែល » ( ការប្រជុំធម្មនិដ្ឋានទូទាំងពិភពលោកសម្រាប់យុវវ័យ ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០១៨ ) ទំព័រ ១៧, ២០ ។

រចនារូបភាពមកពី GETTY IMAGES



# អំណោយបុណ្យគ្រីស្ទម៉ាស់របស់ខាល

**ដោយ ជូលៀន ថេននី ជូមែន**
ផ្អែកទៅលើដំណើររឿងពិត

« *ពេលមានកិច្ចការត្រូវធ្វើ ចូរធ្វើវាដោយញញឹម ។ ធ្វើការច្រើនជាងអ្វីដែលបានសូមឲ្យធ្វើ ហើយធ្វើវាឲ្យបានទ្វេរដង* » ( សៀវភៅចម្រៀងកុមារ *លេខ ១៦៧* ) ។

ខាលបានញីញ័រពេលគាត់ជិះកង់របស់គាត់បញ្ច្រាស់នឹងខ្យល់ ។ គាត់បានគិតថា « ខ្ញុំចង់ទៅដល់ផ្ទះឲ្យបានលឿនបំផុត ហើយទទួលបានភាពកក់ក្ដៅ ។ ហើយខ្ញុំទន្ទឹងចាំបើកអំណោយបុណ្យគ្រីស្ទម៉ាស់ ! » ។

គាត់ត្រូវក្រោកពីព្រលឹមខ្លាំងណាស់នាព្រឹកនោះដើម្បីយកកាសែតឲ្យគេ ។ គាត់បានជិះកង់របស់គាត់ឡើងទួលនៅតាមផ្លូវទៅផ្ទះរបស់គាត់ គាត់បានគិតអំពីនំសីណាម៉ុនសម្រាប់បុណ្យគ្រីស្ទម៉ាស់ដែលម្ដាយគាត់ធ្វើដោយផ្ទាល់ដៃ ។ នំនោះប្រាកដជាមានរសជាតិឆ្ងាញ់ណាស់ ។ គាត់ស្ទើរតែអាចភ្លក់ក្រេមស្ករដ៏ផ្អែមនោះ ។

ក្រេម ! ស្មារបស់ខាលបានធ្លាក់ចុះ ។ គាត់បានភ្លេចរីតទឹកដោះគោ និងកិច្ចការផ្សេងទៀតដែលគាត់ត្រូវធ្វើ ។ ទោះបីជានៅបុណ្យគ្រីស្ទម៉ាស់ក្ដី ។

ខាលបានចតកង់របស់គាត់នៅខាងមុខផ្ទះ ។ គាត់ និងប្អូនប្រុសរបស់គាត់បានប្រណាំងគ្នាទៅមើលថា តើនរណាអាចធ្វើផ្លូវពីក្រដាសហើយមុនគេ ។ គាត់ពុំបានឃើញកង់របស់ប្អូនប្រុសគាត់ឡើយ ដូច្នោះខាលបានឈ្នះ !



បញ្ហាតែមួយគត់ជាមួយនឹងការឈ្នះនោះគឺថា ឥឡូវនេះគាត់ត្រូវរង់ចាំប្អូនប្រុសរបស់គាត់ ពីមុនពួកគេអាចបើកអំណោយបាន ។ បន្ទាប់មក ពួកគេបានត្រូវចេញទៅក្រៅម្ដងទៀត ហើយធ្វើកិច្ចការមួយចំនួន ។ ខាលបានប្រាថ្នាថាគាត់អាចគ្រាន់តែស្នាក់នៅក្នុងផ្ទះ ហើយរីករាយនឹងបុណ្យគ្រីស្ទម៉ាស់ ។

ខាលបានគិតថា « ខ្ញុំត្រូវតែធ្វើកិច្ចការខ្ញុំឲ្យចប់ក្នុងពេលនេះសិន ។ នោះខ្ញុំនឹងពុំត្រឡប់មកក្រៅវិញនៅក្នុងអាកាសធាតុត្រជាក់ឡើយ » ។ គាត់បានប្រញាប់ទៅឯក្រោលគោ ។

គាត់បានចាប់យកធុងមួយ ហើយអង្គុយរីតទឹកដោះគោ ខាលបានសម្លឹងមើលជុំវិញខ្លួន ។ មានកិច្ចការផ្សេងទៀតទាំងអស់ត្រូវធ្វើឲ្យហើយ ។ ក្រោយមក គាត់មានគំនិតមួយ ។ ប្រសិនបើគាត់ធ្វើកិច្ចការទាំងអស់ដោយខ្លួនគាត់ នោះគាត់អាចធ្វើឲ្យគ្រួសារគាត់ភ្ញាក់ផ្អើល ហើយពួកគេអាចចំណាយពេលទាំងអស់នៃបុណ្យគ្រីស្ទម៉ាសជាមួយគ្នា ។ វានឹងក្លាយជាអំណោយបុណ្យគ្រីស្ទម៉ាស់ដ៏ល្អបំផុត !

ខាលបានប្រញាប់ ហើយរីតទឹកដោះគោ ។ បន្ទាប់មក គាត់បានសម្អាតក្រោលគោ ឲ្យចំណីមាន់ និងប្រមូលស៊ុត ។ គាត់បានញញឹម នៅពេលគាត់បានគិតអំពីក្ដីរំភើបដែលគ្រួសារគាត់នឹងមាន ។

ខាលបានត្រឡប់ទៅផ្ទះវិញ ។ គាត់បានលបមើលតាមទ្វារដើម្បីមើលថា តើមាននរណាម្នាក់នៅទីនោះដែរឬទេ ។ បន្ទាប់មក គាត់បានដើរលបៗទៅផ្ទះបាយ ។ គាត់ទើបតែបានដាក់ទឹកដោះគោ និងស៊ុតមាន់រួចនៅក្នុងទូទឹកកក ពេលម្ដាយគាត់បានដើរចូលមក ។

ម៉ាក់បាននិយាយដោយឱបគាត់ថា « អូ៎ កូនមកផ្ទះវិញហើយ ។ ពួកយើងបានឆ្ងល់ថា តើកូនបានទៅណា » ។

ម្ដាយគាត់បានជួយគាត់ដោះអាវរងាចេញ ។ ពេលបងប្អូនរបស់ខាលបានឃើញគាត់ ពួកគេបានស្រែកថា « ខាលមកដល់ផ្ទះហើយ ! ចូរយើងបើកអំណោយទៅ ! » គ្រប់គ្នាបានលូនជុំវិញដើមគ្រីស្ទម៉ាស់ ហើយរង់ចាំប៉ាចែកអំណោយ ។ ខាលចូលចិត្តមើលពួកគេចែករបស់របរឲ្យគ្នា ។

ប៉ាបាននិយាយថា « មែនហើយ ! ឥឡូវនេះ ដល់ពេលធ្វើការហើយ ។ ប៉ុន្តែដំបូង ប៉ាគិតថា យើងត្រូវញ៉ាំទឹកផ្លែឈើ និងនំសីណាម៉ុនសិន » ។

ប៉ាបានដើរទៅផ្ទះបាយ ហើយបើកទូទឹកកក ។ គាត់បានឈប់ ហើយសម្លឹងមើល ។

ប៉ាបាននិយាយថា « មើលនែ៎ ! ។ ដបទឹកដោះគោបានពេញហើយ ហើយស៊ុតមាន់ក៏បានប្រមូលរួចដែរ ! តើនរណាបានធ្វើកិច្ចការនោះ ? »

ប៉ាបានដើរត្រឡប់មកបន្ទប់ទទួលភ្ញៀវវិញ ។ ខាលបានព្យាយាមអស់ពីសមត្ថភាពរបស់គាត់ដើម្បីទប់មិនញញឹម ។

ប៉ាបាននិយាយ ជាមួយនឹងស្នាមញញឹមរបស់គាត់ផ្ទាល់ថា « ខាល តើកូនបានដឹងអ្វីខ្លះអំពីរឿងនេះទេ ? ហាក់ដូចជាកិច្ចការរបស់យើងបានធ្វើរួចហើយ » ។

ខាលបានស្រែកថា « រីករាយថ្ងៃបុណ្យគ្រីស្ទម៉ាស់ ! »

ប៉ាបានឱបខាល ។ « អរគុណកូន ។ នេះជាការចេះគិតគូរមួយល្អណាស់ ។ នេះប្រហែលជាបុណ្យគ្រីស្ទម៉ាស់ដ៏ល្អបំផុតរបស់យើង ! »

ខាលបានញញឹម ។ គាត់បានដឹងរួចទៅហើយថា នេះគឺជាបុណ្យគ្រីស្ទម៉ាស់ដ៏ល្អបំផុត *របស់គាត់* ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋខូឡូរ៉ាដូ ស.រ.អា. ។*

រូបថតដោយ ក្រេប៊ ញ៉ឹល

# ខាធី និង ឃ្វីនសី

**ដោយ អ៊ីវ៉ាន វ៉ាលិនថាញ និង ម៉ារីសា វីដឌីសុន**
ផ្អែកទៅលើដំណើររឿងពិត



*« មិត្រសំឡាញ់រមែងស្រឡាញ់គ្នានៅគ្រប់វេលា » ( សុភាសិត ១៧:១៧ ) ។*

ខាធីចូលចិត្តច្រៀង ។ នាងចូលចិត្តរាំ ។ ប៉ុន្តែនាងចូលចិត្តថ្ងៃអាទិត្យជាងអ្វីៗទាំងអស់ ! នោះគឺនៅពេលគាត់បានឃើញមិត្តរបស់គាត់ឈ្មោះឃ្វីនសី ។

ខាធីមានជំងឺរិបត្តក្រូម៉ូសូម ។ ជួនកាល នៅព្រះវិហារ គាត់ភាន់ច្រឡំ ហើយពុំដឹងថា ត្រូវធ្វើយ៉ាងណាទេ ។ ប៉ុន្តែគាត់បានដឹងថា ឃ្វីនសីនឹងនៅទីនោះដើម្បីជួយគាត់ ។

ឃ្វីនសីនឹងកាន់ដៃខាធី ហើយដើរជាមួយនាងទៅថ្នាក់អង្គការបឋមសិក្សា ។ ជួនកាលខាធីមានអារម្មណ៍ថា ទ្បេះទ្បាស់អំទ្បុងម៉ោងពេលវេលាចែកចាយ ហើយឃ្វីនសីនឹងឱបនាង ។ វាបានជួយខាធី ឲ្យស្ងប់ស្ងៀមជានិច្ច ។ បន្ទាប់ពីពេលវេលាចែកចាយចប់ ឃ្វីនសីបានជួយខាធីរកថ្នាក់របស់នាង ។ ខាធីចូលចិត្តឃ្វីនសី ។

ថ្ងៃមួយ ខាធីបានដឹងថា មានរឿងមួយដ៏ក្រៀមក្រំបានកើតឡើងនៅក្នុងគ្រួសាររបស់ឃ្វីនសី ។ បងប្រុសរបស់ឃ្វីនសីឈ្មោះខូរីបានស្លាប់ ! ខាធីបានដឹងថា មិត្តរបស់នាងនឹងកើតទុក្ខ ។ នាងបានដឹងថា ឃ្វីនសីស្រឡាញ់បងប្រុសនាងខ្លាំងណាស់ ។

ម៉ាក់បានប្រាប់ខាធីថា យប់នេះមានមនុស្សនឹងទៅអគារសាសនាចក្រ ដើម្បីបង្ហាញដល់គ្រួសារឃ្វីនសីថា ពួកគេមានគេស្រឡាញ់ ។ បន្ទាប់មក នៅថ្ងៃស្អែកគឺជាបុណ្យសពរបស់ខូរី ។

ម៉ាក់បានសួរខាធីថា « តើកូនចង់ទៅព្រះវិហារជាមួយប៉ា និងម៉ាក់យប់នេះដែរឬទេ ? »

ខាធីបានងក់ក្បាល ។ នាងចង់ប្រាប់ឃ្វីនសីថា នាងស្រឡាញ់ឃ្វីនសី !

ម៉ាក់បានជួយខាធីស្លៀកពាក់សម្លៀកបំពាក់ស្អាតបាត ។ បន្ទាប់មក ពួកគេបានបើកឡានទៅព្រះវិហារ ។

ពេលពួកគេទៅដល់ទីនោះ ខាធីបានឃើញមនុស្សជាច្រើន ។ នាងបានដឹងថា ពួកគេមួយចំនួនមកពីព្រះវិហារ ។ នាងបានឃើញប៊ីស្សពរបស់នាង ។ នាងបានឃើញគ្រូបង្រៀនថ្នាក់អង្គការបឋមសិក្សារបស់នាង ។ ប៉ុន្តែនាងពុំបានឃើញមិត្តរបស់នាងទេ ។

ខេធីបានសួរ « ម៉ាក់ តើឃ្វីនសីនៅឯណា ? »

ម៉ាក់ពុំដឹងទេ ។

ម៉ាក់បាននិយាយថា « ហេតុអ្វីយើងមិនសួរគេទៅ ? »

ជាទូទៅ ខាធីពុំចូលចិត្តនិយាយពេលមានមនុស្សច្រើននោះទេ ។ ប៉ុន្តែយប់នេះ នាងត្រូវតែរកឃ្វីនសី ។ ខាធីមានចិត្តក្លាហាន ។ នាងបានដើរសំដៅទៅរកប៊ីស្សព ។

នាងបានប្រាប់គាត់ថា « ឃ្វីនសីកើតទុក្ខ ខ្ញុំត្រូវរកឃ្វីនសី ! » ។

ប៊ីស្សពបានញញឹម ហើយបានចាប់ដៃខាធី ។ « អញ្ជឹង តោះទៅរកឃ្វីនសី » ។

រចនារូបភាពដោយ ខាធី ផេរី



ទាំងអស់គ្នា ទាំងប៊ីស្សព ម៉ាក់ និងខាធីបានដើរជុំវិញអគារ ។ ទីបំផុត ពួកគេបានរកឃើញនាង ! ឃ្វីនស៊ី កំពុងអង្គុយនៅកន្លែងកាច់ជ្រុងមួយ ។ គាត់មើលទៅដូចជាកើតទុក្ខក្រៀមក្រំណាស់ ។

ខាធីបានដើរទៅរកមិត្តនាង ហើយឱបនាង ។ គាត់បានគិតថា ឃ្វីនស៊ីនឹកបងប្រុសនាងខ្លាំងណាស់ ។

ខាធីបាននិយាយថា « ឃ្វីនស៊ីមិនជាអ្វីទេ ព្រះយេស៊ូវនឹងមើលថែខូរីហើយ » ។ នាងបានប៉ះសក់ឃ្វីនស៊ីដោយប្រុងប្រយ័ត្ន ដើម្បីប្រាកដថា វាថ្នមៗ ។

ឃ្វីនស៊ីបានចាប់ផ្ដើមយំ ។ ខាធីបានឱបនាងកាន់តែខ្លាំង ។

ខាធីបាននិយាយថា « ឃ្វីនស៊ីមិនអីទេ ។ ព្រះយេស៊ូវនឹងមើលថែខូរីហើយ » ។

ឃ្វីនស៊ីបានយំហើយយំទៀត ។ ខាធីបានបន្តឱបមិត្តរបស់នាង ។ មួយរយៈក្រោយមក ឃ្វីនស៊ីបានស្ងាត់បន្តិច ។ នាងនៅតែរដឹតរដកនៅឡើយ ប៉ុន្តែនាងពុំយំខ្លាំងដូចមុនទេ ។ នាងបានងើយមើលទៅខាធី ។

នាងបាននិយាយថា « អរគុណខាធី ។ ឯងនិយាយត្រូវហើយ ។ ព្រះយេស៊ូវនឹងមើលថែបងប្រុសរបស់ខ្ញុំហើយ » ។

ខាធីបានរីករាយថា នាងអាចជួយមិត្តរបស់នាងឲ្យមានអារម្មណ៍ធូរស្បើយវិញ ។ នាងស្រឡាញ់ឃ្វីនស៊ី ! ■

*អ្នកនិពន្ធរស់នៅរដ្ឋ យូថាហ៍ ស.រ.អា. ។*



**មិត្តដែលពិការ**

ពិការភាពមួយចំនួនធ្វើឲ្យរូបកាយមួយពិបាកធ្វើការ ។ ពិការភាពមួយចំនួនទៀតធ្វើឲ្យខួរក្បាលពិបាកធ្វើការ ។ មនុស្សមួយចំនួនមានពិការភាពដែលប៉ះពាល់ដល់ខួរក្បាល និងរូបកាយរបស់ពួកគេ ។ ទោះមានរឿងអ្វីក៏ដោយ *គ្រប់* ក្មេងទាំងអស់មានសារៈសំខាន់ និងជាបុត្រជាទីស្រឡាញ់របស់ព្រះ !

ប្រសិនបើអ្នកជួបនរណាម្នាក់ដែលពិការ ៖

## សូមកុំ . . .

សម្លឹងមើល ចង្អុល ឬខ្សឹបខ្សៀវគ្នាអំពីពួកគេ ។

ព្រងើយកន្តើយនឹងពួកគេ ។

សើចចំអកដល់ពួកគេ ។

ហៅពួកគេដោយពាក្យអាក្រក់ ។

## សូមធ្វើ . . .

និយាយសួស្ដី ហើយធ្វើល្អ ។

សួរសំណួរក្នុងរបៀបមួយគួរសម ។

ការពារពួកគេ ប្រសិនបើមានអ្នកដទៃធ្វើមិនល្អដាក់ពួកគេ ។

សូមចងចាំថា ពួកគេគឺជាបុត្ររបស់ព្រះ ដូចជាអ្នកផងដែរ !

# គារវភាពជាក្ដីស្នេហ៍





**ដោយ លូអាយប៉ូ ដបុលយូ អាយុ ១០ ឆ្នាំ**
**ទីក្រុង វីតូរីយ៉ា អូស្ត្រាលី**

នៅថ្ងៃសុក្រ គ្រូបង្រៀនរបស់ខ្ញុំបានសុំឲ្យខ្ញុំអានកំណាព្យមួយដែលខ្ញុំបានសរសេរ នៅមុខសិស្ស គ្រូបង្រៀន និងឳពុកម្ដាយទាំងអស់នៅក្នុងការជួបជុំមួយនៅសាលារបស់យើង ។ ខ្ញុំមានចិត្តរីករាយណាស់ ដូច្នោះខ្ញុំបានឆ្លើយ « យល់ព្រម ! » ប៉ុន្តែខ្ញុំក៏ភ័យនឹងរឿងនេះផងដែរ ។

ពេលខ្ញុំកំពុងអង្គុយនៅលើវេទិការង់ចាំអានកំណាព្យរបស់ខ្ញុំ បេះដូងរបស់ខ្ញុំបានចាប់ផ្ដើមលោតលឿនណាស់ ។ ខ្ញុំមានអារម្មណ៍ភ័យអំពីការចែកចាយអ្វីដែលខ្ញុំបានសរសេរជាមួយមនុស្សជាច្រើន ។

បន្ទាប់មក មានគំនិតមួយបានផុសឡើងនៅក្នុងចិត្តរបស់ខ្ញុំ ។ ខ្ញុំបានគិតអំពីរបៀបដែលគ្រួសារខ្ញុំ និងខ្ញុំអានព្រះគម្ពីរមរមនជាមួយគ្នានៅពេលព្រឹក ពីមុនទៅសាលារៀន ។ គំនិតនៃការអានព្រះគម្ពីរជាមួយគ្រួសារខ្ញុំ បានធ្វើឲ្យខ្ញុំគិតអំពីព្រះវរបិតាសួគ៌ ។ ខ្ញុំបានគិតអំពីរបៀបដែលទ្រង់ស្រឡាញ់ខ្ញុំ ។ ខ្ញុំបានទទួលអារម្មណ៍ល្ហួងលោម ហើយពុំឯកោទៀតឡើយ ។ បេះដូងខ្ញុំឈប់លោតលឿន ហើយខ្ញុំមានអារម្មណ៍គារវភាព ។

នៅក្នុង *សៀវភៅចម្រៀងកុមារ* នៅទំព័រទី ១២ ទំនុកបទនេះចែងថា

*គារវភាពមិនគ្រាន់តែអង្គុយស្ងៀមស្ងាត់ទេ ៖*
*តែត្រូវគិតដល់បិតាសួគ៌ា*
*ខ្ញុំទទួលបានអារម្មណ៍មួយពេលគិតពីព្រះពរទ្រង់ ។*
*ខ្ញុំមានគារវភាពព្រោះជាក្ដីស្នេហ៍ ។*
*គារវភាពខ្ញុំបង្ហាញតាមសម្ដី និងទង្វើ ។*
*ផ្លូវដែលត្រូវដើរតាមភ្លឺត្រចះ ។*
*ពេលណាខ្ញុំមានគារវភាពខ្ញុំដឹងក្នុងចិត្ត*
*ព្រះបិតាព្រះគ្រីស្ទនៅជិតបង្កើយ ។*

ខ្ញុំមានអំណរគុណដែលខ្ញុំទទួលអារម្មណ៍នៃសេចក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ ពេលខ្ញុំមានអារម្មណ៍ភ័យនៅឯការប្រជុំនោះ ។ ហើយខ្ញុំមានអំណរគុណដែលដឹងថា ទ្រង់ស្រឡាញ់ខ្ញុំខ្លាំងណាស់ ។

ខ្ញុំដឹងថា នៅក្នុងស្ថានភាពលំបាកៗ ខ្ញុំអាចជ្រើសរើសមានគារវភាព ហើយគិតអំពីព្រះ ។ ■

រចនារូបភាពដោយ ឡារ៉ា ស្ទ្រែន



# បានសង្គ្រោះចេញពីភក់

**ដោយអែលឌើរ អាឌីលសុន**
**ឌី ប៉ោឡា ផារ៉ែលឡា**
ក្នុងពួកចិតសិបនាក់

« *ខ្ញុំចែកក្ដីស្នេហ៍ព្រះគ្រីស្ទ តាមការបម្រើអ្នកដទៃ* » ( សៀវភៅចម្រៀងកុមារ *លេខ ៤២* ) ។

គ្រួសារខ្ញុំបានរស់នៅទីក្រុង សៅ ផាឡូ ប្រទេសប្រេស៊ីល ។ នៅត្រើយម្ខាងទៀតនៃផ្លូវរបស់យើង មានព្រៃកោងកាងមួយ ។ ព្រៃកោងកាងមានទន្លេហូរកាត់ព្រៃនោះ ។ បាតខាងក្រោមនោះសុទ្ធតែជាភក់ ។

មនុស្សជាច្រើនបានសង់ផ្ទះនៅលើដីភក់នោះ ។ ពួកគេដាក់ឈើធំៗទៅក្នុងភក់ ។ បន្ទាប់មក ពួកគេបានសាងសង់ផ្ទះរបស់ពួកគេនៅផ្នែកខាងលើនៃឈើទាំងនោះ ។ ប៉ុន្តែពេលភ្លៀង ទឹកទន្លេបានជន់ឡើង ។ ទឹកនោះបានហូរចូលផ្ទះរបស់ពួកគេ ។ បន្ទាប់មកប្រជាជនគ្មានកន្លែងដេកនៅពេលយប់ទេ ។

នៅពេលមានរឿងនោះកើតឡើង ឪពុករបស់ខ្ញុំនឹងអញ្ជើញពួកគេទាំងអស់គ្នាមកក្នុងផ្ទះរបស់យើង ។ ជួនកាល មានមនុស្សដល់ទៅ ១៥ នាក់ ! គាត់បាននាំពួកគេទៅក្នុងបន្ទប់ទទួលភ្ញៀវ ហើយឲ្យភួយទៅពួកគេ ។ ម៉ាក់បានចំអិនម្ហូបឲ្យពួកគេបរិភោគ ។ បន្ទាប់មក ពួកគេបានសម្រាកនៅក្នុងផ្ទះយើង រហូតដល់ថ្ងៃបន្ទាប់ ។

រឿងនេះបានកើតឡើងយ៉ាងហោចណាស់បី ឬបួនដង ។ ខ្ញុំចាំពីការគិតថា « ពុំមានមនុស្សច្រើនទេ ដែលអនុញ្ញាតឲ្យមនុស្សមិនស្គាល់ចូលផ្ទះ » ។ ឪពុកខ្ញុំបានអនុញ្ញាតឲ្យមនុស្សដែលយើងពុំស្គាល់ដេកនៅក្នុងផ្ទះរបស់យើង ! ប៉ុន្តែក្រោយមកខ្ញុំបានគិតថា « ពួកគេគ្មានកន្លែងផ្សេងទៀតទៅឡើយ » ។

ឪពុកម្ដាយរបស់ខ្ញុំតែងធ្វើកិច្ចការដើម្បីជួយគេឯងជានិច្ច ។ ប៉ុន្តែការបម្រើរបស់ពួកគេគឺលើសពីការជួយ និងការផ្ដល់ឲ្យគេទៅទៀត ។ វាគឺជាការបង្ហាញសេចក្ដីស្រឡាញ់ដល់អ្នកជិតខាងយើង ទោះបីអ្នកជិតខាងយើងជាមនុស្សដែលយើងមិនស្គាល់ពួកគេច្បាស់ក្ដី ។

យើងគួរតែឈោងទៅជួយមនុស្សដែលខ្វះខាត ។ យើងគួរតែជួយពួកគេជាមួយអ្វីគ្រប់យ៉ាងដែលយើងអាចជួយបាន ។ យើងពុំគួរមានដែនកំណត់ចំពោះអ្វីដែលយើងអាចធ្វើដើម្បីជួយមនុស្សទេ ។ យើងអាចផ្ដល់ជម្រក និងធនធានដល់ពួកគេ ។ យើងអាចចែករំលែកពេលវេលាជាមួយពួកគេ ។ យើងអាចចែកចាយចំណេះដឹងយើងអំពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ជាពិសេសនៅរដូវកាលបុណ្យគ្រីស្ទម៉ាស់នេះ ។ ■



រចនារូបភាពដោយ អ័ដាម កូហ្វ៊ីដ



រចនារូបភាពដោយ អូប្រ៊ីយ ប្លែកហាម



« ព្រះយេស៊ូវគ្រីស្ទមានព្រះជន្មរស់ ហើយទ្រង់គឺជាព្រះអង្គសង្គ្រោះ និងព្រះប្រោសលោះនៃពិភពលោក ។ ទ្រង់បានប្រទានផ្លូវទៅកាន់សុភមង្គលពិត » ។

**ដោយ អែលឌើរ ឃ្វីនថិន អិល យុក**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

*« យើងធ្វើតាមព្រះយេស៊ូវគ្រីស្ទ » លីអាហូណា ខែ ឧសភា ឆ្នាំ ២០១០ ទំព័រ ៨៦ ។*

# ទំព័ររបស់យើង




ខ្ញុំមានចិត្តសប្បាយរីករាយដើម្បីចូលទៅក្នុងទឹកនៃពិធីបុណ្យជ្រមុជទឹក ហើយបានបញ្ជាក់ជាសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ ។ ព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើជាដៃគូដ៏ស្មោះត្រង់របស់ខ្ញុំ ប្រសិនបើខ្ញុំបន្តនៅបរិសុទ្ធ ហើយគោរពតាមបទបញ្ញត្តិ ។ ខ្ញុំដឹងថា ព្រះមានព្រះជន្មរស់ ទ្រង់ស្រឡាញ់យើង សាសនាចក្រនេះពិត ហើយព្រះគម្ពីរមរមនពិត ។

**ហូន អូ អាយុ ៨ ឆ្នាំ ទីក្រុងកាលី ប្រទេសកូឡុំប៊ី**





**« ខ្ញុំស្រឡាញ់ផែនការរបស់ព្រះវរបិតាសួគ៌ » ដោយ អ៊ីរៀនធុម ឌី និង « ខ្ញុំចង់ចែកចាយជាមួយមនុស្សគ្រប់គ្នា » ដោយ ជីរលៀន ធី លូស្សុន ហ្វីលីពីន**






*« ពួកអ្នកផ្សព្វផ្សាយសាសនារបស់ព្រះអម្ចាស់ »* **អ៊ីមីលីអូ អេ អាយុ ៩ ឆ្នាំ ទីក្រុង ហ្វ័ម៉ូសា ប្រទេសអាហ្សង់ទីន**

គ្រប់ថ្ងៃបុណ្យខួបកំណើតទាំងអស់គឺពិសេសណាស់ ប៉ុន្តែតាំងពីខ្ញុំនៅតូច ខ្ញុំបានរៀបចំខ្លួនខ្ញុំសម្រាប់ពិធីបុណ្យជ្រមុជទឹក ។ ឥឡូវនេះ ខ្ញុំបានទទួលបុណ្យជ្រមុជទឹក ខ្ញុំសប្បាយចិត្តណាស់ ។ ខ្ញុំដឹងថា ព្រះវរបិតាសួគ៌សព្វព្រះទ័យនឹងខ្ញុំ ហើយស្រឡាញ់ខ្ញុំ ។

**ដាន់ណា អីមអាយុ ៩ ឆ្នាំ ទីក្រុង ឈីម៉ាតេណាន់ហ្គោ ប្រទេសហ្គូតេម៉ាឡា**





# បងប្អូនប្រុសដែលបញ្ចាំងពន្លឺដល់ពិភពលោក

## ជម្រាបសួរ !
ពួកយើងឈ្មោះ ហូបើត និង ហេឌិន ។



**១**

**ហេឌិន ៖ ចម្រៀងបុណ្យគ្រីស្ទម៉ាស់**

ថ្នាក់រៀនខ្ញុំនៅសាលាមានការសម្ដែងអំពីប្រសូតកម្ម ហើយខ្ញុំបានលេងព្យាណូសម្រាប់កម្មវិធីទាំងមូល ។ ខ្ញុំបានបង្រៀនមនុស្សគ្រប់គ្នាឲ្យច្រៀងបទ « O Holy Night » ។

**២**

**ហេឌិន ៖ ការបង្រៀនអ្នកជិតខាង**

ខ្ញុំចូលចិត្តបង្រៀនអ្នកជិតខាងរបស់ខ្ញុំ នៅពេលយើងលេង ដោយសារខ្ញុំចង់បម្រើពួកគេ ។ នៅក្នុង ម៉ាថាយ ៥:១៦ ព្រះយេស៊ូវបង្រៀនយើងថា ចូរឲ្យយើងបញ្ចាំងពន្លឺយើងចេញទៅ ។ ពេលខ្ញុំធ្វើល្អដូច្នេះ ខ្ញុំមានអារម្មណ៍រីករាយ ។



**៣**

**ហូបើត ៖ ការជួយអ្នកស្រេកឃ្លាន**

អំឡុងពេលចេញលេងនៅសាលារៀន ខ្ញុំឃើញមនុស្សដែលស្រេកឃ្លាន ហើយគ្មានអ្វីបរិភោគ ។ ខ្ញុំបានចែកអាហារសម្រន់របស់ខ្ញុំ ហើយបានជួយពួកគេឲ្យមានអារម្មណ៍ធូរស្បើយ ។ បន្ទាប់ពីចែកនំនោះរួច ខ្ញុំមានអារម្មណ៍រីករាយ ។

យើងរស់នៅក្នុងប្រទេសហ្គាណា ។ ទីក្រុងរបស់យើងឈ្មោះអាក្រា គឺវានៅក្បែរមហាសមុទ្រអត្លង់ទិច ។ ប្រទេសយើងក៏មានព្រះវិហារបរិសុទ្ធដ៏ស្រស់ស្អាតផងដែរ ។



## ៤

**ហូបើត ៖ ការលេងព្យាណូខ្យល់**

នៅព្រះវិហារខ្ញុំលេងព្យាណូខ្យល់សម្រាប់ឲ្យសមាជិកច្រៀង ។ ពេលខ្ញុំធ្វើល្អដូច្នេះ ខ្ញុំមានអារម្មណ៍រីករាយ ។



## ៥

**ចូរយើងបញ្ចាំងពន្លឺដល់ពិភពលោក**

នៅក្នុងព្រះគម្ពីរចែងថា ព្រះយេស៊ូវគឺជាពន្លឺ និងជាជីវិតនៃពិភពលោក ។ ដូច្នេះចូរយើងបញ្ចាំងពន្លឺដល់ពិភពលោក !



**សូមអរគុណដែលប្អូនៗបានផ្ញើរូបផ្កាយរបស់ប្អូនមកកាន់ *លីអាហូណា* !**

ឆ្នាំនេះ ប្អូនៗបានបំពេញមេឃរបស់យើងជាមួយនឹងរូបផ្កាយ និងរឿងរាប់ពាន់ស្តីពីការបម្រើប្រកបដោយក្តីស្រឡាញ់របស់ប្អូនៗ ។ ប្រាកដណាស់ ប្អូនៗពិតជាបានបញ្ចាំងពន្លឺរបស់ប្អូនៗមែន !

# យ៉ូណាស និងត្រីបាឡែន

ដោយ គីម វេប រីដ



ព្រះបានមានបន្ទូលប្រាប់ឲ្យយ៉ូណាសទៅបេសកកម្មមួយ ។ គាត់ត្រូវទៅទីក្រុងមួយឈ្មោះនីនីវេ ហើយប្រាប់ប្រជាជននោះឲ្យប្រែចិត្ត ។ ប៉ុន្តែយ៉ូណាសពុំចង់ទៅទីនោះទេ ។ គាត់បានជិះសំពៅទៅទីក្រុងមួយផ្សេងទៀត ។



មានព្យុះដ៏ធំមួយបានកើតឡើង ។ ពួកនាវិកបានភិតភ័យថា សំពៅរបស់ពួកគេនឹងលិច !

រចនារូបភាពដោយ អាប៊ីល ស្កុត



យ៉ូណាសបានដឹងថា ព្រះបានចាត់ព្យុះនេះមក ដោយសារយ៉ូណាសបានរត់គេចពីទ្រង់ ។ លោកបានប្រាប់ឲ្យពួកនាវិកឲ្យបោះគាត់ចេញពីសំពៅ ដើម្បីឲ្យព្យុះនោះឈប់ ។



ព្រះបានចាត់ត្រីបាឡែនមួយឲ្យមកសង្គ្រោះយ៉ូណាស ។ គាត់នៅក្នុងពោះត្រីបាឡែននោះអស់រយៈពេលបីថ្ងៃ ។ យ៉ូណាសបានអធិស្ឋាន ។ គាត់បានសម្រេចចិត្តថា ប្រែចិត្ត ហើយធ្វើតាមព្រះ ។ ព្រះបានប្រាប់ត្រីបាឡែននោះក្អួតយ៉ូណាសចេញដាក់លើដីគោក ។



យ៉ូណាសបានទៅទីក្រុងនីនីវេ ។ លោកបានបង្រៀនប្រជាជននៅទីនោះ ។ ហើយប្រជាជននៅទីក្រុងនីនីវេបានស្ដាប់ ! ពួកគេបានចាប់ផ្ដើមធ្វើតាមព្រះម្ដងទៀត ។



នៅពេលខ្ញុំធ្វើការជ្រើសរើសខុស ខ្ញុំអាចប្រែចិត្ត ហើយសាកល្បងម្ដងទៀត ។ ព្រះស្រឡាញ់យ៉ូណាស ហើយព្រះស្រឡាញ់ខ្ញុំ ! ■

*ដកស្រង់មកពី យ៉ូណាស ១–៤ ។*

# « ខ្ញុំមកប្រាប់ដំណឹងល្អដល់អ្នករាល់គ្នា ពីសេចក្ដីអំណរយ៉ាងអស្ចារ្យ » ។

—លូកា ២:១០



រចនារូបភាពដោយ អាប៊ែល ស្មុត



**ដោយ អែលឌើរ ប្រ៊ូស អរ ម៉ាក់ខនគី**
**( ១៩១៥–១៩៨៥ )**
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# ការស្គាល់ព្រះគ្រីស្ទតាមរយៈយ៉ូសែប ស្ម៊ីធ

*មានមនុស្សម្នាក់ដែលមានចំណេះដឹងអំពីព្រះគ្រីស្ទ និងសេចក្ដីសង្គ្រោះដែលកើតមានឡើងក្នុងជំនាន់របស់យើង ។*



យើងបង្រៀន និងថ្លែងទីបន្ទាល់ថា សេចក្ដីសង្គ្រោះមាននៅក្នុងព្រះគ្រីស្ទ ។ ទ្រង់គឺជាព្រះអម្ចាស់របស់យើង ជាព្រះរបស់យើងជាស្ដេចរបស់យើង ។ យើងថ្វាយបង្គំព្រះវរបិតានៅក្នុងព្រះនាមទ្រង់ ដូចជាពួកព្យាការីដ៏បរិសុទ្ធទាំងអស់ ព្រមទាំងពួកបរិសុទ្ធទាំងអស់គ្រប់ជំនាន់ ។

យើងរីករាយក្នុងទ្រង់ និងនៅក្នុងការពលិកម្មដ៏ធួនរបស់ទ្រង់ ។ ព្រះនាមរបស់ទ្រង់គឺនៅលើអស់ទាំងឈ្មោះទាំងអស់ ហើយគ្រប់ជង្គង់នឹងលុតនៅចំពោះទ្រង់ ហើយគ្រប់អណ្ដាតនឹងសារភាពថា ទ្រង់គឺជាព្រះអម្ចាស់នៃមនុស្សទាំងអស់ ប្រសិនបើគ្មានទ្រង់ នោះពុំមានជីវិតអមតៈ និងជីវិតអស់កល្បជានិច្ចឡើយ ។

ប៉ុន្តែឥឡូវនេះ ខ្ញុំនិយាយអំពីបុគ្គលម្នាក់ទៀត គឺមនុស្សម្នាក់ដែលមានចំណេះដឹងអំពីព្រះគ្រីស្ទ និងសេចក្ដីសង្គ្រោះដែលកើតមានឡើងក្នុងជំនាន់របស់យើង ។ . . .

ខ្ញុំនឹងនិយាយអំពី យ៉ូសែប ស្ម៊ីធ ជុញ្ញ័រ ជាព្យាការីដ៏អស្ចារ្យនៃការស្ដារឡើងវិញ ជាបុគ្គលម្នាក់ដែលស្ដាប់ឮសំឡេងសួគ៌ាមុនគេនៅក្នុងសម័យកាន់កាប់ត្រួតត្រានេះ ជាបុគ្គលម្នាក់ដែលជាឧបករណ៍ដែលស្ថាបនានគររបស់ព្រះម្ដងទៀតនៅក្នុងចំណោមមនុស្ស ។ . . .

នៅនានិទាឃរដូវឆ្នាំ ១៨២០ [ ព្រះជាព្រះវរបិតា និង ព្រះរាជបុត្រាទ្រង់គឺព្រះយេស៊ូវគ្រីស្ទ ] បានហែកវាំងននៃសេចក្ដីងងឹត ដែលគ្របដណ្ដប់លើផែនដីអស់រយៈពេលរាប់ជំនាន់ ។ . . . ពួកទ្រង់បានយាងចុះមកពីដំណាក់សេឡេស្ទាលរបស់ពួកទ្រង់ ដើម្បីទៅព្រៃពិសិដ្ឋនៅក្បែរទីក្រុង ប៉ាលម៉ៃរ៉ា រដ្ឋ នូវ យ៉ោក ។ ដោយហៅឈ្មោះយុវជនយ៉ូសែប បន្ទាប់មកពួកទ្រង់បានប្រាប់លោកថា . . . លោកនឹងត្រូវក្លាយជាឧបករណ៍នៅក្នុងព្រះហស្តពួកទ្រង់ ក្នុងការស្ដារឡើងវិញនូវភាពពោរពេញនៃដំណឹងល្អរបស់ពួកទ្រង់ ។ . . .

មនុស្សទាំងអស់អាចសួរខ្លួនពួកគេអំពីកន្លែងដែលពួកគេឈរ ដោយធៀបទៅនឹងយ៉ូសែប ស្ម៊ីធ និងបេសកកម្មមកពីព្រះរបស់លោក ។ តើពួកគេសួររកឈ្មោះរបស់លោក ហើយស្វែងរកថា តើសេចក្ដីសង្គ្រោះបានរកឃើញតែតាមរយៈដំណឹងល្អនៃព្រះគ្រីស្ទ ដូចបានបើកសម្ដែងទៅកាន់ព្យាការីថ្ងៃចុងក្រោយរបស់ទ្រង់ឬ . . . ? សំណួរដ៏អស្ចារ្យដែលមនុស្សទាំងអស់នៅក្នុងជំនាន់របស់យើងត្រូវឆ្លើយ—ហើយដាក់ខ្លួនពួកគេទៅក្នុងគ្រោះថ្នាក់នៃការបាត់បង់សេចក្ដីសង្គ្រោះផ្ទាល់ខ្លួន—គឺ ៖ តើយ៉ូសែប ស្ម៊ីធ ត្រូវបានព្រះហៅមែនឬ ? . . .

. . . ចូរកុំឲ្យមានការយល់ច្រឡំឡើយ ។ យើងគឺសាក្សីអំពីព្រះគ្រីស្ទ ។ ទ្រង់គឺជាព្រះអង្គសង្គ្រោះរបស់យើង ។ . . . ប៉ុន្តែយើងក៏ជាសាក្សីអំពីយ៉ូសែប ស្ម៊ីធ ជាបុគ្គលដែលធ្វើឲ្យយើងស្គាល់ព្រះគ្រីស្ទ ហើយជាអ្នកធ្វើការស្របច្បាប់ ដែលបានទទួលអំណាចដើម្បីចងភ្ជាប់នៅលើផែនដី និងផ្សារភ្ជាប់នៅលើស្ថានសួគ៌ ដែលមនុស្សទាំងអស់ចាប់ពីជំនាន់របស់លោកមក អាចគ្រងសេចក្ដីសង្គ្រោះទុកជាមរតក ។ ■

*ដកស្រង់មកពី « Joseph Smith—The Mighty Prophet of the Restoration »* Ensign *ខែ ឧសភា ឆ្នាំ ១៩៧៦ ទំព័រ ៩៤–៩៦ ។ អក្សរធំបានអនុលោមតាមបទដ្ឋាន ។*

រូបភាពដោយ GETTY IMAGES



សំពត់ក្រាលប្រសូតកម្ម
ដោយ ជូឌី វ៉ាន់ហ្គេមិន

« ដ្បិតនៅថ្ងៃនេះ មានព្រះអង្គសង្គ្រោះមួយអង្គប្រសូតដល់អ្នករាល់គ្នា នៅក្រុងហ្លួងដាវីឌគឺជាព្រះគ្រីស្ទដ៏ជាព្រះអម្ចាស់ ។
« ហើយនេះជាទីសម្គាល់ដល់អ្នករាល់គ្នា គឺអ្នករាល់គ្នានឹងឃើញព្រះឱរសមួយ រុំនឹងសំពត់ផ្ដេកនៅក្នុងស្នូក ។ . . .
« សួស្ដីដល់ព្រះនៅស្ថានដ៏ខ្ពស់បំផុត ហើយសេចក្ដីសុខសាន្តនៅផែនដីនៅកណ្ដាលមនុស្ស ដែលជាទីគាប់ព្រះហឫទ័យដល់ទ្រង់ » ( លូកា ២:១១–១២, ១៤ ) ។

ដកស្រង់ចេញពីពិធីបុណ្យនៃប្រសូតកម្មដែលបានប្រារព្ធឡើងនៅក្នុងទីក្រុងហ្គេណេសវីល រដ្ឋចចចា ស. រ. អា. ។

យុវមជ្ឈិមវ័យ

## តើមានការសម្រេចចិត្តធំៗត្រូវធ្វើឬ ?

*អ្នកអាចទុកចិត្តនាវិកដ៏ល្អឥតខ្ចោះដើម្បីជួយដឹកនាំអ្នក ។*

៤២




ការប្រារព្ធកម្មវិធី « រួមគ្នាតែមួយ »
ការទន្ទឹងចាំមើលនៅក្នុងសាមគ្គីភាព
៤៦, ៥១

យុវវ័យ
ការបំពេញការងារបម្រើផ្ទាល់របស់អ្នក
៥២

បុណ្យគ្រីស្ទម៉ាស់
របៀបប្រាំពីរយ៉ាងដើម្បីចែកចាយអំណោយ
៥៦

សូមបន្ថែមចំណុចនេះទៅលើបញ្ជីនៃបុណ្យគ្រីស្ទម៉ាស់របស់អ្នក
៦០



CAMBODIAN
4 02147 97258 3


សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ